សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Science Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការប្រតិបត្តិមតកសាសន៍

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ ភិក្ខុ **ឌីម ឌន**
លោក **ប៊ុនថា និមិត្ត**

ណែនាំដោយ
លោក **គង់ សុភ័ក្ត្រ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Science Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការប្រតិបត្តិមតកសាសន៍

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ ភិក្ខុ **ជីម ជន**
លោក **ម៉ុនថា និមិត្ត**

ណែនាំដោយ
លោក **គង់ សុភ័ក្ត្រ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **ជីម ជន** និង **ម៉ុនថា និមិត្ត** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែក នីតិសាស្ត្រ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០២២-២០២៣ បានសរសេរសារណាក្នុងគោលបំណងបញ្ចប់ការសិក្សា ក្រោមប្រធានបទ ស្តីពី "**ការប្រតិបត្តិមតកសាសន៍**" ។

សូមសម្តែងនូវគារវកិច្ចគោរពដឹងគុណដ៏ខ្ពង់ខ្ពស់ជាអនេកប្បការជូនចំពោះ៖

- លោកឪពុក៖ **ជី ជីម** និង អ្នកម្តាយ៖ **ឈាង ញឿន**
- លោកឪពុក៖ **ស៊ឺន ម៉ុនថា** និង អ្នកម្តាយ៖ **ថង ចន្ធ្នា**

ដែលបានផ្តល់កំណើត និងបានខិតខំពុះពារគ្រប់ឧបសគ្គក្នុងការចិញ្ចឹមបីបាច់ ថែរក្សា យកចិត្តទុកដាក់អប់រំទូន្មាន ប្រៀនប្រដៅ និងបានផ្គត់ផ្គង់កូនគ្រប់សព្វបែបយ៉ាងទាំងសម្ភារសម្រាប់ប្រើប្រាស់រៀនសូត្រ និងបញ្ញាស្មារតីដល់កូន ជាពិសេសលោកទាំងទ្វេបានខិតខំជំរុញឱ្យកូនបានសិក្សារៀនសូត្ររហូតមកដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ។ គុណូបការៈដែលលោកទាំងទ្វេបានខិតខំជំរុញផ្តល់ និងលះបង់នេះ វាជាវត្ថុដ៏មានតម្លៃបំផុតដែលមិនអាចកាត់ថ្លៃបាន និងមិនអាចប្រៀបផ្ទឹមបានឡើយ។ ហើយគ្មានថ្ងៃណាដែលកូនអាចតបស្នងសងគុណលោកវិញអស់ឡើយ។

យើងខ្ញុំក៏សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅផងដែរ ជូនចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ សាស្ត្រាចារ្យរង សាស្ត្រាចារ្យជំនួយ គណៈគ្រប់គ្រងសាលា លោក លោកស្រី និងបុគ្គលិកការិយាល័យស្រាវជ្រាវ ការិយាល័យសិក្សា នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្តក្នុងកិច្ចការដឹកនាំ គ្រប់គ្រង ជាពិសេសបង្ហាត់បង្រៀន ផ្តល់ដំបូន្មាន ក៏ដូចជាបទពិសោធន៍ល្អៗជាច្រើនដែលជាទ្រព្យដ៏គាប់ប្រសើរ និងមានតម្លៃឥតគណនាសម្រាប់និស្សិតគ្រប់រូប ដើម្បីជាស្ពានចម្លងទៅថ្ងៃអនាគតដ៏ភ្លឺស្វាង។

ជាពិសេសលោក **គង់ សុភ័ក្ត្រ** ដែលជាគ្រូណែនាំក្នុងការសរសេរសារណារបស់យើងខ្ញុំទាំងពីរ ហើយលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការពន្យល់ ចង្អុលបង្ហាញ និងផ្តល់ជាគំនិតយោបល់ ពិនិត្យមើលនូវខ្លឹមសារ ផ្តល់ជាអនុសាសន៍ ក្នុងការកែសម្រួល និងផ្តល់ជាឯកសារពាក់ព័ន្ធផ្សេងៗទៀត ដើម្បីឱ្យសារណាយើងខ្ញុំទាំងពីរកាន់តែល្អប្រសើរ និងទទួលបានជោគជ័យ។

ជាទីបញ្ចប់យើងខ្ញុំសូមសម្តែងនូវការដឹងគុណ និងថ្លែងអំណរគុណចំពោះ **លោកអ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ សាស្ត្រាចារ្យរង សាស្ត្រាចារ្យជំនួយ លោក លោកស្រី បុគ្គលិកទាំងអស់ មិត្តរួមថ្នាក់ និងមិត្តរួមជំនាន់ទាំងអស់** សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាមុខវិជ្ជានានានៃថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេលបួនឆ្នាំ និងជាពិសេសក្រោយពីសិក្សាលើក្រមរដ្ឋប្បវេណីមក បានឱ្យយើងខ្ញុំគិតថា ក្រមរដ្ឋប្បវេណី គឺជារឿងដែលគួរតែសិក្សាស្វែងយល់ឱ្យបានច្បាស់លាស់ក្នុងនាមជាប្រជាពលរដ្ឋដ៏ល្អក្នុងសង្គម ព្រោះក្រមរដ្ឋប្បវេណីមិនត្រឹមតែជាបទដ្ឋានសម្រាប់ធ្វើការសម្រេចសេចក្ដីប៉ុណ្ណោះទេ គឺជាបទដ្ឋានសម្រាប់បង្ហាញពីសកម្មភាពដែលបុគ្គលមានសិទ្ធិធ្វើ និងមិនមានសិទ្ធិធ្វើផងដែរ ហើយគំនិតមួយនេះបានធ្វើឱ្យយើងខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំងលើក្រមរដ្ឋប្បវេណី។ ស្របពេលដែលយើងខ្ញុំបានទទួលសិទ្ធិសរសេរសារណាដើម្បីបញ្ចប់ការសិក្សា យើងខ្ញុំក៏បានពិភាក្សាគ្នា ហើយក៏បានសម្រេចជ្រើសរើសយកប្រធានបទ "**ការប្រតិបត្តិមតកសាសន៍**" មកសរសេរសារណាបញ្ចប់ការសិក្សា។ មូលហេតុដែលយើងខ្ញុំសម្រេចចិត្ត លើកយកប្រធានបទមួយនេះមកសរសេរសារណា គឺដើម្បីឱ្យមិត្តនិស្សិត អ្នកអាន ក៏ដូចជាអ្នកសិក្សា ដែលមានបំណងចង់ធ្វើការស្វែងយល់អំពីការប្រតិបត្តិមតកសាសន៍នេះ អាចសិក្សាស្វែងយល់បន្ថែមដោយសារតែប្រធានបទមួយនេះថ្មី និងមានការអនុវត្តតិចតួចបំផុតនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្នគិតចាប់ពីពេលដែលក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រូវបានប្រកាសឱ្យប្រើ។

ដោយហេតុថា ចំណេះដឹង និងបទពិសោធន៍ ចំពោះការសិក្សាស្រាវជ្រាវនូវមានកម្រិតនៅឡើយ ដូចនេះយើងខ្ញុំជឿជាក់ថា កំហុសដែលកើតមានឡើងដោយអចេតនាមួយចំនួន ដែលមានដូចជា កំហុសអក្ខរាវិរុទ្ធ ខ្លឹមសារ អត្ថន័យ និងភាពខ្វះចន្លោះមិនគ្រប់ជ្រុងជ្រោយតាមខ្លឹមសារច្បាប់នឹងកើតមានក្នុងសារណានេះជាក់ជាពុំខាន។ យើងខ្ញុំរីករាយទទួលនូវមតិរិះគន់ក្នុងន័យស្ថាបនា ដើម្បីកែលំអនូវរាល់កំហុសឆ្គង និងចំណុចខ្វះខាតទាំងឡាយដោយក្ដីសោមនស្សរីករាយ និងទទួលយកដោយមេត្រីភាព ពីសំណាក់សម្ដេច ឯកឧត្តម លោកជំទាវ សាស្ត្រាចារ្យ លោក លោកស្រី និងមិត្តអ្នកអានទាំងឡាយ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា សារណាបញ្ចប់ការសិក្សាមួយនេះនឹងអាចផ្ដល់ជូនពុទ្ធិជាមូលដ្ឋាន និងវិភាគទានមួយចំនួនទាក់ទងនឹងការប្រតិបត្តិមតកសាសន៍ ដើម្បីជាប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវបន្តទៀត។ ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំទាំងពីរសូមជូនពរដល់អស់លោក លោកស្រី ដែលបានកំពុងអានសៀវភៅនេះ សូមជួបប្រទះតែពុទ្ធពរទាំង ៤ប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។ សូមអរគុណ !

ថ្ងៃចន្ទ ១០កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣
ជីម ជន ប៊ុនថា និមិត្ត

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ **១**

**ជំពូកទី១**

**ការបង្កើតមតកសាសន៍**

**១.១.លក្ខខណ្ឌគ្រឹះនៃការបង្កើតមតកសាសន៍** ........ **៤**

១.១.១. សមត្ថភាពនាពេលធ្វើមតកសាសន៍ ........ **៤**

១.១.១.១.បុគ្គលជានីតិជន ........ **៥**

១.១.១.២.ជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមហិតូបត្ថម្ភ ........ **៥**

១.១.១.៣.បុគ្គលជាអនីតិជនដែលទទួលបានអត្តាធីនភាព ........ **៦**

១.១.២.ការបង្ហាញឆន្ទៈរបស់មតកជន ........ **៧**

១.១.២.១.ការភាន់ច្រឡំ ........ **៧**

១.១.២.២.ការឆបោក ........ **៨**

១.១.២.៣.ការគំរាមកំហែង ........ **៨**

១.១.២.៤.ព័ត៌មានមិនពិត ........ **៨**

១.១.២.៥.ការរំលោភបំពានលើស្ថានភាពពិត ........ **៨**

**១.២.លក្ខខណ្ឌទម្រង់ក្នុងការធ្វើមតកសាសន៍** ........ **៩**

១.២.១.មតកសាសន៍តាមទម្រង់ធម្មតា ........ **៩**

១.២.១.១.មតកសាសន៍ដោយលិខិតយថាភូត ........ **៩**

១.២.១.២.មតកសាសន៍ដោយលិខិតឯកជន ........ **១០**

១.២.១.៣.មតកសាសន៍ដោយលិខិតសម្ងាត់ ........ **១១**

១.២.២. មតកសាសន៍ក្នុងស្ថានភាពពិសេស ........ **១១**

១.២.២.១.មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ ........ **១២**

១.២.២.២.មតកសាសន៍ជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់ជីវិត ........ **១២**

១.២.២.៣.មតកសាសន៍ជនដែលត្រូវជាប់ឃុំឃាំង និងជនជាប់ក្នុងនាវា ឬយន្តហោះ ........ **១៣**

១.២.២.៤. មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍ ........ **១៤**

១.២.២.៥.មតកសាសន៍ជនជាតិខ្មែររស់នៅបរទេស ........ **១៥**

## ជំពូកទី២
## ការជ្រើសរើស និងតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍

**២.១.ការពិនិត្យបញ្ជាក់ និងការបើកលិខិតមតកសាសន៍** ...................... **១៦**
២.១.១.នីតិវិធីពិនិត្យបញ្ជាក់នៅតុលាការ ...................... **១៧**
២.១.១.១.សមត្ថកិច្ចតុលាការ ...................... **១៧**
២.១.១.២.ការកោះហៅសន្តតិជន ជាអាទិ៍ ...................... **១៨**
២.១.១.៣.ចំណុចសំខាន់ៗនៃការពិនិត្យបញ្ជាក់ ...................... **១៨**
**២.២.ការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍** ...................... **១៩**
២.២.១.ការជ្រើសរើសដោយមតកជន តតិយជន និងតុលាការ ...................... **១៩**
២.២.១.១.ការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍ដោយមតកជន ...................... **១៩**
២.២.១.២.ការប្រគល់អាណត្តិឱ្យតតិយជនដើម្បីជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍ ...................... **២០**
២.២.១.៣.ការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍ដោយផ្លូវតុលាការ ...................... **២១**
២.២.២.សហអ្នកប្រតិបត្តិមតកសាសន៍ ...................... **២១**
២.២.៣.បុគ្គលដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍ ...................... **២២**
**២.៣.តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍** ...................... **២២**
២.៣.១. ការដាក់ពាក្យសុំផ្តាច់ ឬលុបចោលការផ្តាច់មត៌ក ...................... **២៣**
២.៣.២.ការដាក់ពាក្យបណ្តឹងទៅតុលាការ និងឋានៈជាភាគីនៃបណ្តឹង ...................... **២៣**
២.៣.៣.ការស្រាវជ្រាវមត៌ក ...................... **២៤**
២.៣.៤.ការធ្វើបញ្ជីសារពើភ័ណ្ឌ ...................... **២៥**
២.៣.៥.ការគ្រប់គ្រងមត៌ក និងប្រតិបត្តិតាមខ្លឹមសារនៃមតកសាសន៍ ...................... **២៥**
២.៣.៦.ការចុះបញ្ជីអចលនវត្ថុឱ្យទៅអច្ច័យទានកំណត់ ...................... **២៦**
២.៣.៧.ការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍បន្ត ...................... **២៦**
**២.៤.សោហ៊ុយ និងកម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍** ...................... **២៧**
២.៤.១.សោហ៊ុយក្នុងការប្រតិបត្តិមតកសាសន៍ ...................... **២៧**
២.៤.២.កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍ ...................... **២៧**
**២.៥. ការលាឈប់ និងការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍** ...................... **២៨**

## ជំពូកទី៣
## ការបែងចែកមត៌កករណីមតកសាសន៍មិនបានកំណត់ពីវិធីបែងចែក

**៣.១. ការគ្រប់គ្រងមត៌កមុនធ្វើការបែងចែក** ........ ២៩
៣.១.១.ការគ្រប់គ្រងដោយសន្តតិជន ........ ២៩
៣.១.២.ការគ្រប់គ្រងដោយអ្នកប្រតិបត្តិមតកសាសន៍ ........ ៣០
៣.១.៣.អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន ........ ៣០
**៣.២. ប្រភេទនៃការបែងចែកមត៌ក** ........ ៣១
៣.២.១.ការពិភាក្សាបែងចែកមត៌ករវាងសហសន្តតិជន ........ ៣១
៣.២.២.ការបែងចែកមត៌កដោយតុលាការ ........ ៣៣
**៣.៣.លំហូរនៃការបែងចែក** ........ ៣៤
៣.៣.១.ទំហំនៃសន្តតិជន ........ ៣៤
៣.៣.២.ទំហំនៃមត៌ក ........ ៣៤
៣.៣.៣.ការវាយតម្លៃមត៌ក ........ ៣៥
**៣.៤.ការវិនិច្ឆ័យអំពីវិធីបែងចែក** ........ ៣៥
៣.៤.១.វិធីនៃការបែងចែក ........ ៣៦
៣.៤.១.១.ការបែងចែកវត្ថុជាក់ស្តែង ........ ៣៦
៣.៤.១.២.ការបែងចែកតាមការសងជំនួស ........ ៣៦
៣.៤.១.៣.ការបែងចែកដោយប្តូរជាប្រាក់ ........ ៣៦
៣.៤.១.៤.ការបែងចែកដោយអវិភាគ ........ ៣៦
៣.៤.២.មូលដ្ឋាននៃការពិចារណានៅពេលបែងចែកមត៌ក ........ ៣៧
៣.៤.២.១.មូលដ្ឋាននៃការបែងចែក ........ ៣៧
៣.៤.២.២.សិទ្ធិអាទិភាពរបស់សហព័ទ្ធ ........ ៣៨
៣.៤.២.៣.សំណងនៃការកាតព្វកិច្ចរបស់មតកជន ........ ៣៩
៣.៤.២.៤.ទម្រង់នៃការផ្ទេរសិទ្ធិចំពោះវត្ថុជាមត៌ក ជាអាទិ៍ ........ ៣៩
៣.៤.៣.អានុភាពនៃការបែងចែក ........ ៤០
**សេចក្តីសន្និដ្ឋាន** ........ ៤២
**អនុសាសន៍** ........ ៤៤
**គន្ថនិទ្ទេស**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

មនុស្សគ្រប់រូបនៅក្នុងសង្គម ត្រូវបានទទួលឋានៈក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចនៅពេលចាប់កំណើត ហើយបាត់បង់អស់នូវសមត្ថភាពទទួលសិទ្ធិ នៅពេលទទួលមរណភាព។[1] ស្របតាមទស្សនៈពុទ្ធនិយម យល់ឃើញថា សត្វលោកទាំងឡាយរមែងវិលកើតវិលស្លាប់ មិនចេះអស់ មិនចេះហើយ។ កាលបើកើតមកឡើង ហើយរមែងតែងមានចាស់ ឈឺ ស្លាប់ ជារឿងធម្មតា។

ជាទូទៅបើទទួលមរណភាពហើយ បុគ្គលនឹងបាត់បង់សមត្ថភាពទទួលសិទ្ធិរបស់ខ្លួន ដែលមានន័យថា មិនអាចតាំងខ្លួនជាកម្មសិទ្ធិករ ឬជាម្ចាស់បំណុលបានទៀតទេ ដែលតម្រូវឱ្យមានការគិតគូរពីម្ចាស់សិទ្ធិថ្មីដែលត្រូវទទួលបន្តនូវសិទ្ធិ។ សន្តតិកម្ម ក្នុងន័យនៃច្បាប់ គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។[2]ជាគោលការណ៍របបសន្តតិកម្មនាពេលបច្ចុប្បន្ន គឺមានគោលការណ៍ធំៗចំនួនពីរគឺ គោលការណ៍ជម្រះបញ្ជី និងគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ។ របបសន្តតិកម្មតាមគោលការណ៍ជម្រះបញ្ជី គឺត្រូវធ្វើការជម្រះបញ្ជីទាំងអស់នូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន មុននឹងសន្តតិជនទទួលបន្តនូវទ្រព្យសម្បត្តិដែលជាមត៌ក ប៉ុន្តែនីតិវិធីមានលក្ខណៈស្មុគស្មាញ និងប្រើប្រាស់រយៈពេលយូរ។ ចំណែកឯគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិវិញ ជារបបសន្តតិកម្មដែលរាល់សិទ្ធិ និងករណីយកិច្ចរបស់មតកជននឹងត្រូវផ្ទេរបន្តដោយស្វ័យប្រវត្តិទៅសន្តតិជន ប្រសិនបើសន្តតិជនយល់ព្រមទទួលមត៌ក។ សន្តតិកម្ម ត្រូវបានចាប់ផ្តើមដោយមរណភាពរបស់មតកជន។[3] តាមរយៈមាត្រា ១១៤៥ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី បានធ្វើការបែងចែកសន្តតិកម្មជាពីរ គឺសន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ និងដោយផ្អែកតាមឆន្ទៈរបស់មតកជន។ សន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថា សន្តតិកម្មតាមច្បាប់ និងសន្តតិកម្មដោយផ្អែកលើឆន្ទៈរបស់មតកជនហៅថា សន្តតិកម្មមានបណ្តាំ។

សន្តតិកម្មដែលធ្វើឡើងតាមបណ្តាំ ឬឆន្ទៈរបស់មតកជនត្រូវធ្វើឡើងតាមទម្រង់ដែលបានកំណត់ដោយច្បាប់ បើមិនដូច្នោះទេ បណ្តាំ ឬមតកសាសន៍នឹងត្រូវក្លាយជាកម្មវត្ថុនៃមោឃភាព ឬពុំអាចអនុវត្តបានឡើយ។ នៅពេលដែលមតកជនទទួលមរណភាព មតកសាសន៍នឹងចាប់ផ្តើមមានអានុភាព ដែលទាមទារឱ្យអ្នកមានប្រយោជន៍ពាក់ព័ន្ធ យកមតកសាសន៍ទៅពិនិត្យបញ្ជាក់នៅតុលាការ ដើម្បីកុំឱ្យមានការកែប្រែខ្លឹមសារនៃបណ្តាំ លើកលែងតែមតកសាសន៍ដែលធ្វើឡើងដោយលិខិតយថាភូត។ នៅពេលដែលមតកសាសន៍ត្រូវបានពិនិត្យបញ្ជាក់នៅតុលាការហើយ នីតិវិធីនៃការអនុវត្តមតកសាសន៍នឹងចាប់ផ្តើមកើតមានឡើង ដែលនីតិវិធីមាន

[1] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៨។
[2] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ២០០៧, សទ្ទានុក្រម ផ្នែករដ្ឋប្បវេណី ទំព័រ២១, លេខ១៤៣។
[3] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៤៥ កថាខណ្ឌទី ១។

ភាពស្មុគស្មាញ ដែលញុំាងឱ្យប្រជាជនខ្មែរភាគច្រើនមិនសូវយល់ពីការប្រតិបត្តិមតកសាសន៍ឡើយ។ ហើយអ្វីដែលពួកយើងបានដឹង និងសង្កេតឃើញទៀតនៅពេលដែលបានបណ្តាំមិនបានកំណត់ពីវិធីបែងចែកឱ្យច្បាស់លាស់ ធ្វើឱ្យអ្នកប្រតិបត្តិមិនមានសមត្ថកិច្ចធ្វើការបែងចែកបានទេ ដែលញុំាងឱ្យការកំណត់ពីវិធីបែងចែកត្រូវធ្លាក់ទៅសហសន្តតិជនវិញដើម្បីពិភាក្សាគ្នាធ្វើការបែងចែក ហើយបើនៅតែមិនអាចបែងចែកបានទៀត ត្រូវដាក់ពាក្យសុំទៅតុលាការដើម្បីឱ្យតុលាការជាអ្នកធ្វើការបែងចែក។ ដោយហេតុថានីតិវិធីក្នុងការប្រតិបត្តិ មានភាពស្មុគស្មាញ ធ្វើឱ្យពួកគាត់ចាប់ផ្តើមមានជម្លោះជាមួយសន្តតិជនគ្នាឯង ដែលបានបង្កទៅជារឿងរ៉ាវរហូតឈានទៅផ្លូវប្តឹងផ្តល់ទៅតុលាការថែមទៀត បើទោះបីជាមានបណ្តាំដែលជាការបង្ហាញឆន្ទៈចុងក្រោយរបស់មតកជនក៏ដោយ។

ដោយមើលឃើញពីបញ្ហាដែលបានកើតឡើងនៅក្នុងសង្គមជាក់ស្តែង ករណីនេះបានធ្វើឱ្យការបង្ហាញឆន្ទៈចុងក្រោយរបស់មតកជន បែរជាពុំអាចបង្កើតអានុភាពតាមផ្លូវច្បាប់ និងអាចបង្កជាជម្លោះក្នុងសង្គមគ្រួសារថែមទៀតផង ហេតុនេះហើយបានជាពួកយើងខ្ញុំលើកយកប្រធានបទ "**ការប្រតិបត្តិមតកសាសន៍**" មកធ្វើការសិក្សាវែកញែក ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ ក្នុងការសិក្សាលើប្រធានបទខាងលើ យើងសូមធ្វើការសិក្សាតែទៅលើអ្វីទៅជាតួនាទីអ្នកប្រតិបត្តិមតកសាសន៍ និងនីតិវិធីនៃបែងចែកមត៌កចំពោះបណ្តាំដែលមិនបានកំណត់ពីវិធីបែងចែកតែប៉ុណ្ណោះ ដូច្នេះយើងខ្ញុំសូមធ្វើការបែងចែកជា ៣ (បី) ជំពូកធំៗ គឺ៖

- ជំពូកទី ១ **ការបង្កើតមតកសាសន៍**
- ជំពូកទី ២ **ការជ្រើសរើស និងតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍**
- ជំពូកទី ៣ **ការបែងចែកមត៌ក ករណីមតកសាសន៍មិនបានកំណត់ពីវិធីបែងចែក**

# ជំពូកទី១

# ការបង្កើតមតកសាសន៍

# ជំពូកទី១
# ការបង្កើតមតកសាសន៍

ការបង្កើតមតកសាសន៍ដូចគ្នានឹងកិច្ចគតិយុត្តដទៃទៀតដែរ ដើម្បីអាចបង្កើតបាននូវអានុភាពតាមផ្លូវច្បាប់ មតកសាសន៍ត្រូវគោរពជាចាំបាច់នូវលក្ខខណ្ឌនៃការបង្កើតលិខិតគតិយុត្តនោះ។ ជាគោលការណ៍ យើងអាចធ្វើការបែងចែកលក្ខខណ្ឌនេះជាពីរយ៉ាងគឺៈ លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។

ជាទូទៅចំពោះលិខិតគតិយុត្ត លក្ខខណ្ឌគ្រឹះដើរតួនាទីកំណត់ពីភាពចាំបាច់ទាំងឡាយនៃសុពលភាពផ្ទាល់របស់លិខិត។ ចំណែកឯការបំពានដោយមិនបានបំពេញឱ្យបានត្រឹមត្រូវនូវលក្ខខណ្ឌជាទម្រង់គ្រាន់តែប្រើជាលក្ខខណ្ឌភស្តុតាងសម្រាប់បញ្ជាក់ពីអត្ថិភាពពិតប្រាកដនៃលិខិតគតិយុត្តប៉ុណ្ណោះ។ ពោលគឺប្រសិនបើអ្នកបង្កើតលិខិតគតិយុត្តពុំបានគោរពតាមលក្ខខណ្ឌជាទម្រង់ទេ វាពុំមានន័យថាលិខិតដែលធ្វើឡើងនេះគ្មានសុពលភាពឡើយ ប៉ុន្តែក្នុងករណីមានការជំទាស់នឹងសុពលភាពរបស់លិខិត គេនឹងតម្រូវឱ្យអ្នកបង្កើតលិខិតបង្ហាញភស្តុតាង អំពីវត្តមានពិតប្រាកដនៃលិខិតគតិយុត្តដែលត្រូវគោរពត្រឹមត្រូវតាមលក្ខខណ្ឌជាមូលដ្ឋានគ្រឹះ។ ដូចនេះ វាមានន័យថាច្បាប់កំណត់លក្ខខណ្ឌគ្រឹះទុកដូចជាលក្ខខណ្ឌចាំបាច់ និងដាច់ខាតសម្រាប់គ្រប់ សុពលភាពរបស់លិខិតគតិយុត្តទាំងឡាយដែលត្រូវតែគោរពពេលបង្កើត។ រីឯលក្ខខណ្ឌជាទម្រង់ប្រើសម្រាប់គ្រាន់តែជាភស្តុតាងនៃសុពលភាព ក្រោយពេលបង្កើតប៉ុណ្ណោះ។

តើមតកសាសន៍ដែលគ្រាន់តែជាប្រភេទមួយនៃលិខិតគតិយុត្ត ចាំបាច់ត្រូវបំពេញឱ្យបានជាធម្មតានូវតាមគោលការណ៍ខាងលើ ដើម្បីឱ្យលិខិតមានសុពលភាព ឬយ៉ាងណា? ពិតណាស់ ដោយហេតុថាមតកសាសន៍ គឺជាកិច្ចសម្ដែងឆន្ទៈចុងក្រោយនៃមតកជនសំដៅការចាត់ចែងនូវមត៌ករបស់ខ្លួនទៅឱ្យទៅសន្តតិជន ឬអច្ច័យលាភីណាម្នាក់របស់ខ្លួន។ ដោយយោងទៅតាមស្មារតីនៃក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧ វាហាក់បីដូចជាលក្ខខណ្ឌគ្រឹះ និងទាំងលក្ខខណ្ឌទម្រង់ សុទ្ធសឹងជាលក្ខខណ្ឌនៃសុពលភាពរបស់មតកសាសន៍ទាំងអស់ពីព្រោះថា ការមិនគោរពតាមលក្ខខណ្ឌទាំងពីរសុទ្ធសឹងជាមូលហេតុផ្ទាល់នៃមោឃភាពរបស់មតកសាសន៍ដូចគ្នា។

ដើម្បីងាយស្រួលសិក្សាអំពីលក្ខខណ្ឌគ្រឹះក្នុងការបង្កើតលិខិតគតិយុត្ត ប្រភេទមតកសាសន៍តើធ្វើយ៉ាងដូចម្ដេចខ្លះ? ដូច្នេះហើយនៅក្នុងជំពូកនេះ យើងនឹងធ្វើការបែងចែកទិដ្ឋភាពដូចបានបញ្ជាក់ខាងលើគឺៈ លក្ខខណ្ឌគ្រឹះ(១.១.) និងលក្ខខណ្ឌទម្រង់(១.២.)។

## ១.១.លក្ខខណ្ឌគ្រឹះនៃការបង្កើតមតកសាសន៍

ជាគោលការណ៍ លិខិតគតិយុត្តឯកតោភាគីទាំងអស់ តែងតែស្ថិតនៅក្រោមលក្ខខណ្ឌជាមូលដ្ឋានដូចគ្នានឹងលក្ខខណ្ឌតម្រូវចំពោះកិច្ចសន្យាដែរគឺ លក្ខខណ្ឌគ្រឹះនៃឆន្ទៈ សមត្ថភាព កម្មវត្ថុ និងមូលហេតុ។[4] ហេតុនេះ តើលិខិតគតិយុត្តជាមតកសាសន៍ត្រូវស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវជាគ្រឹះ តាមគោលការណ៍ខាងលើដែរ ឬយ៉ាងណា? ចម្លើយគឺ គោលការណ៍ខាងលើនឹងត្រូវបានកាត់បន្ថយចំពោះលិខិតគតិយុត្តជាមតកសាសន៍។[5]

តាមពិតទៅ ការកាត់បន្ថយដែលបានលើកឡើងខាងលើ បានពីមូលហេតុដែលថា មតកសាសន៍ជាលិខិតកើតពីឆន្ទៈនៃបុគ្គលតែម្នាក់តែអាចបង្កើតអានុភាព (សិទ្ធិ និងករណីយកិច្ច) ឱ្យដល់បុគ្គលដទៃទៀត (សន្តតិជន ឬអច្ច័យលាភី) ហេតុនេះហើយទើបលក្ខខណ្ឌចាំបាច់គឺមានតែម្យ៉ាងប៉ុណ្ណោះ ដែលតម្រូវចំពោះសុពលភាពនៃលិខិតមតកសាសន៍[6] ពោលគឺភាពពិតប្រាកដនៃឆន្ទៈរបស់មតកជនតែម្តង។ លក្ខខណ្ឌគ្រឹះនៃការបង្កើតមតកសាសន៍នឹងធ្វើការសិក្សាទៅលើ សមត្ថភាពម្ចាស់បណ្តាំពេលធ្វើមតកសាសន៍ (១.១.១.) និងការបង្ហាញឆន្ទៈរបស់ម្ចាស់បណ្តាំដោយគ្មានវិការៈ (១.១.២.)។

### ១.១.១. សមត្ថភាពនាពេលធ្វើមតកសាសន៍

មតកសាសន៍ គឺជារបបមួយដែលបង្កើតឡើង ដើម្បីគោរពឆន្ទៈពិតរបស់ម្ចាស់បណ្តាំ។ ម្ចាស់បណ្តាំត្រូវមានសមត្ថភាពខាងឆន្ទៈ នៅពេលធ្វើមតកសាសន៍។ មានន័យថា ប្រសិនបើម្ចាស់បណ្តាំគ្មានសមត្ថភាពខាងឆន្ទៈពេលធ្វើមតកសាសន៍ ដោយសារតែស្រវឹងស្រាខ្លាំង ឬដោយសារមានជំងឺវង្វេងដោយភាពចាស់ជរា ជាអាទិ៍ មតកសាសន៍អាចក្លាយជាមោឃៈ។[7]ក្នុងករណីដែលបុគ្គលដែលបានអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្តាំ ត្រូវបញ្ជាក់អំពីការខ្វះសមត្ថភាពនោះ។

បុគ្គលដែលអាចធ្វើមតកសាសន៍បានជាមានដូចជា បុគ្គលជានីតិជន(១.១.១.១.) ជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមហិតូបត្ថម្ភ(១.១.១.២.) និងអនីតិជនដែលទទួលបានអត្តាធីនភាព(១.១.១.៣.)។

---

[4]សូមបញ្ជាក់ថា លក្ខខណ្ឌមូលហេតុនៃការបង្កើតលិខិតនេះ ត្រូវបានទទួលស្គាល់ជាលក្ខខណ្ឌគ្រឹះ នៅក្នុងនីតិវិជ្ជមានបារាំងប៉ុណ្ណោះ ប៉ុន្តែ នីតិវិជ្ជមានខ្មែរពុំចាត់ទុកលក្ខខណ្ឌនេះ ជាលក្ខខណ្ឌមួយនៃការបង្កើតរាល់លិខិតគតិយុត្តឡើយ។

[5]សូមមើលសៀវភៅរបស់ Jaques Flour ,Jean Jean Aubert, Eric Savaux មានចំណងជើងថា``Les obligations, 1.l' acte juridique´´ បោះពុម្ពលើកទី៨ នាឆ្នាំ២០០០ទំព័រ៣៦១។

[6] ជាការពិតណាស់ លក្ខខណ្ឌផ្សេងទៀតក៏អាចមានឥទ្ធិពលចំពោះសុពលភាពនៃមតកសាសន៍នេះផងដែរតួយ៉ាងដូចជាក្នុងករណីបើមតកសាសន៍ធ្វើឡើងសំដៅចាត់ចែងទ្រព្យរបស់អ្នកដទៃ ឬទ្រព្យជាផលនៃបទល្មើសព្រហ្មទណ្ឌជាដើមនោះមតកសាសន៍នោះ អាចនឹងត្រូវប្រកាសមោឃភាពដោយមូលហេតុកម្មវត្ថុខុសច្បាប់។ ប៉ុន្តែនៅទីនេះយើងសូមមិនធ្វើការពិចារណាចំពោះលក្ខខណ្ឌនៃទ្រព្យដោយធ្វើការសន្មត ថាទ្រព្យចាត់ចែងដោយមតកសាសន៍គឺ ស្របច្បាប់។

[7]គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ភាគ៦,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០) មាត្រា ១១៦៩។

#### ១.១.១.១.បុគ្គលជានីតិជន

ជាគោលការណ៍ បុគ្គលជានីតិជនអាចធ្វើនូវមតកសាសន៍បាន ហើយមានសមត្ថភាពឯករាជ្យខាងអំពើ ឬសកម្មភាពរបស់ខ្លួន។ នីតិជន គឺសំដៅលើជនដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅដូច ក្រមរដ្ឋប្បវេណីកំណត់ ដោយមានការយល់ឃើញថា បុគ្គលដែលមានវ័យ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពីរបស់ខ្លួនតាមផ្លូវច្បាប់។ [8] នីតិជនមានសិទ្ធិគ្រប់គ្រាន់ក្នុងធ្វើសកម្មភាព គ្រប់គ្រងទ្រព្យសម្បត្តិ ចាត់ចែងទ្រព្យសម្បត្តិ និងបង្កើតកិច្ចសន្យាផ្សេងៗ។ ចំពោះមតកសាសន៍ ជាប្រភេទសកម្មភាពឯកតោភាគី ដែលនីតិជន ឬមតកជនមានសិទ្ធិធ្វើក្នុងការផ្តល់នូវសិទ្ធិ និងករណីកិច្ចបន្តទៅឱ្យសន្តតិជន ឬអច្ច័យលាភីបាន។

#### ១.១.១.២.ជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមហិតូបត្ថម្ភ

ជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមហិតូបត្ថម្ភ ក៏អាចធ្វើមតកសាសន៍ដោយខ្លួនឯងបានដែរ ដោយមិនចាំបាច់មានការយល់ព្រមពីអាណាព្យាបាល ឬហិតូបត្ថមកៈឡើយហើយមតកសាសន៍ទាំងនោះមិនអាចលុបចោលបានទេ។ [9] ទោះជាយ៉ាងនេះក្តី ពួកគេត្រូវមានសមត្ថភាពធ្វើមតកសាសន៍នោះផងដែរ ហើយអ្វីដែលស្មុគស្មាញនោះគឺ ករណីរបស់ជននៅក្រោមអាណាព្យាបាលទូទៅ។ ជននៅក្រោមអាណាព្យាបាលទូទៅ តែងខ្វះសមត្ថភាពក្នុងការធ្វើមតកសាសន៍។ ប៉ុន្តែ ជននៅក្រោមអាណាព្យាបាលទូទៅ ក៏អាចមានសមត្ថភាពធ្វើមតកសាសន៍នៅពេលខ្លះដែរ ដោយសារតែស្ថានភាពរបស់ជននោះអាចនឹងប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ ដូច្នេះជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើមតកសាសន៍បាន តែនៅពេលជននោះជាសះស្បើយមួយរយៈឡើងវិញជាបណ្តោះអាសន្ននូវសមត្ថភាពប៉ុណ្ណោះ។ [10] ក្រោយធ្វើមតកសាសន៍ ជននោះអាចបាត់បង់នៅសមត្ថភាពក្នុងពេលឆាប់ៗម្តងទៀត ក៏ដោយវាមិនប៉ះពាល់ដល់សុពលភាពរបស់មតកសាសន៍នោះទេ។ នៅក្នុងការបង្ហាញភស្តុតាងអំពីការជាសះស្បើយមួយរយៈនូវសមត្ថភាពជាបណ្តោះអាសន្ននោះ នៅពេលធ្វើមតកសាសន៍ តម្រូវឱ្យមានវេជ្ជបណ្ឌិតយ៉ាងតិច ២(ពីរ) នាក់ដើម្បីពិនិត្យបញ្ជាក់ថាជននោះមានសមត្ថភាពគ្រប់គ្រាន់នៅពេលធ្វើបណ្តាំ។ វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិត មតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្តាំពុំបានស្ថិតក្នុងស្ថានភាពខ្វះ

[8] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧, ០៨ ធ្នូ ឆ្នាំ២០០៧, សន្ទានុក្រម ផ្នែករដ្ឋប្បវេណី ទំព័រ១០, លេខ៧០។

[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១១៦៨ កថាខណ្ឌទី ២។

[10] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ ៣, កែសម្រួលលើការបោះពុម្ពលើកទី១ (ភ្នំពេញ៖ ទីភ្នាក់ងារប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន, ឆ្នាំ២០១៧),ទំព័រ ៤៩ ។

សមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ។[11]

បើទោះបីជាជននៅក្រោមហិតូបត្ថម្ភ ជាជនដែលត្រូវបានកម្រិតសមត្ថភាពក៏ដោយ ក៏អាចធ្វើមតកសាសន៍បានដែរ។[12] ម្យ៉ាងទៀតក្រមរដ្ឋប្បវេណី ពុំបានកំណត់អំពីទម្រង់ណាមួយ ដើម្បីបំពេញបន្ថែមក្នុងករណីជននៅក្រោមហិតូបត្ថម្ភ ធ្វើមតកសាសន៍ ដូចករណីជននៅក្រោមអាណាព្យាបាលទូទៅទេ ពោលគឺមាត្រា ១១៦៩ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ មិនរាប់បញ្ចូលជននៅក្រោមហិតូបត្ថម្ភទេ ហេតុដូច្នេះ អាចបកស្រាយថា ជននៅក្រោមហិតូបត្ថម្ភ ជាជនដែលមានសមត្ថភាពនៅពេលធ្វើមតកសាសន៍ លើកលែងតែមានការអះអាងណាមួយថា ជននៅក្រោមហិតូបត្ថម្ភ បានធ្វើមតកសាសន៍ក្នុងកំឡុងពេលដែលខ្លួនមិនបានយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។

### ១.១.១.៣.បុគ្គលជាអនីតិជនដែលទទួលបានអត្តាធីនភាព

លក្ខខណ្ឌនៃអត្តាធីនភាព ក្នុងករណីដែលអនីតិជនបានដល់អាយុ ១៦ឆ្នាំ អាចទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់ជននោះបាន តាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជន។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា។[13] ម៉្យាងទៀត អនីតិជនបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ។[14] ក្នុងករណីដែលបានកំណត់ខាងលើនេះបើ ទោះបីភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាព មិនត្រូវរលត់ឡើយ។[15]

អានុភាពនៃអត្តាធីនភាព ចំពោះអនីតិជនដែលទទួលអត្តាធីនភាព ត្រូវចាត់ទុកថាបានដល់នូវនីតិភាព។[16] នៅពេលដែលអនីតិជនបានទទួលនូវអត្តាធីនភាព គាត់មានសិទ្ធិធ្វើសកម្មភាពដូចជានីតិជនដែរ។ អនីតិជនដែលបានទទួលអត្តាធីនភាព រួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬអំណាចមេបា អាចធ្វើមតកសាសន៍បាន។[17] ពោលគឺមានន័យថា អនីតិជនដែលទទួលបានអត្តាធីនភាពមានសិទ្ធិក្នុងការធ្វើបណ្តាំ ឬមតកសាសន៍ដូចគ្នានិងនីតិជនដែរ។

[11] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១១៧៦ កថាខណ្ឌទី ២។
[12] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១១៦៨។
[13] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ២១ កថាខណ្ឌទី ១។
[14] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ២១ កថាខណ្ឌទី ២។
[15] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ២១ កថាខណ្ឌទី ៣។
[16] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ២២។
[17] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១១៦៨ កថាខណ្ឌទី ១។

### ១.១.២.ការបង្ហាញឆន្ទៈរបស់មតកជន

ម្ចាស់បណ្ដាំធ្វើបណ្ដាំ គឺក្នុងគោលបំណងសម្ដែងនូវការសម្រេចចិត្តចុងក្រោយរបស់ខ្លួនដើម្បីផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់ខ្លួនឱ្យទៅសន្តតិជន និងដើម្បីកុំឱ្យកើតមានជម្លោះរវាងសហសន្តតិជន នៅពេលខ្លួនបានទទួលមរណភាព។ មតកសាសន៍ត្រូវបានទទួលស្គាល់ជាអានុភាពផ្លូវច្បាប់ ដោយមានការគោរពឆន្ទៈពិត និងចុងក្រោយរបស់ម្ចាស់បណ្ដាំ។[18]

សមត្ថភាពខាងឆន្ទៈ សំដៅដល់ស្ថានភាពដែលបុគ្គលអាចត្រិះរិះគិតពិចារណា ទៅលើអំពើណាមួយដែលខ្លួនធ្វើ ហើយបុគ្គលដែលបានធ្វើសកម្មភាព អាចមើលឃើញជាមុននូវលទ្ធផលផ្លូវច្បាប់ ដែលកើតចេញពីអំពើរបស់ខ្លួន។ ផ្អែកតាមមាត្រា ១៤ នៃក្រមរដ្ឋប្បវេណីបានចែងថា សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន។ ចំពោះការធ្វើមតកសាសន៍ក៏ដូចគ្នាដែរ ម្ចាស់បណ្ដាំត្រូវមានសមត្ថភាពខាងឆន្ទៈនៅពេលដែលខ្លួនធ្វើមតកសាសន៍។ បន្ថែមពីលើនេះ ការបង្ហាញឆន្ទៈរបស់មតកជន ត្រូវជៀសអំពីវិការៈក្នុងការបង្ហាញឆន្ទៈ។[19]

ទោះបីជាម្ចាស់បណ្ដាំ បានធ្វើមតកសាសន៍តាមកំណត់ច្បាប់ និងមានសមត្ថភាពខាងឆន្ទៈត្រឹមត្រូវក៏ដោយ មតកសាសន៍នឹងមិនបង្កើតសុពលភាពតាមច្បាប់នោះទេ ប្រសិនបើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈដោយការភាន់ច្រឡំ(១.១.២.១.) ការឆបោក(១.១.២.២.) ការគម្រាមកំហែង(១.១.២.៣.) ព័ត៌មានមិនពិត(១.១.២.៤.) ការរំលោភបំពានលើស្ថានភាព(១.១.២.៥.)។

#### ១.១.២.១.ការភាន់ច្រឡំ

ការភាន់ច្រឡំ គឺជាសកម្មភាពដែលម្ចាស់បណ្ដាំ បានបង្ហាញឆន្ទៈផ្ទុយពីគោលបំណងរបស់ខ្លួន។ ជាគោលការណ៍ច្បាប់ មិនមែនដោយសារតែការភាន់ច្រឡំរបស់ម្ចាស់បណ្ដាំតែម្ខាង អាចអះអាងអំពីវិការៈនៃការបង្ហាញឆន្ទៈ និងយកជាមូលហេតុដើម្បីលុបចោលមតកសាសន៍បានឡើយ។ ការភាន់ច្រឡំរបស់ម្ចាស់បណ្ដាំអាចយកធ្វើជាមូលហេតុនៃការលុបចោលមតកសាសន៍ គឺជាសកម្មភាពដែលម្ចាស់បណ្ដាំមានការភាន់ច្រឡំលើចំណុចសំខាន់ៗ នៃមតកសាសន៍ ហើយភាគីម្ខាងទៀតដែលជាសន្តតិជន ឬជាអច្ច័យលាភី ឬបុគ្គលដែលពាក់ព័ន្ធផលប្រយោជន៍តាមមតកសាសន៍ អាចដឹងអំពីការភាន់ច្រឡំនោះដែរ។[20] ការភាន់ច្រឡំអាចជាការភាន់ច្រឡំលើចំណុចទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការបែងចែក ឬលក្ខណៈនៃសន្តតិជន ឬអច្ច័យលាភីជាដើម។

---

[18] ក្រុមការងារនៃគ្រូបណ្ដុះបណ្ដាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណីភាគ ៣ ,បោះពុម្ពលើកទី១ (ភ្នំពេញ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន,២០១៣), ទំព័រ ៤៧។

[19] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ៣១២ កថាខណ្ឌទី ២។

[20] ក្រមរដ្ឋប្បវេណី,លេខ សន/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ៣៤៦។

**១.១.២.២.ការឆបោក**

ការឆបោក គឺជាទង្វើរបស់សន្តតិជន ឬអច្ច័យលាភី ឬអ្នកពាក់ព័ន្ធផលប្រយោជន៍តាមរយៈមតកសាសន៍ ឬតតិយជន មាននូវចេតនាទុច្ចរិត ដោយប្រើប្រាស់ឧបាយកលឆបោក ឬមធ្យោបាយណាមួយក្នុងគោលបំណងដើម្បីឱ្យម្ចាស់បណ្ដាំបង្ហាញឆន្ទៈទៅតាមអ្វីដែលខ្លួនចង់បាន។ ក្នុងករណីដែលម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់សន្តតិជន ឬអច្ច័យលាភី ឬអ្នកពាក់ព័ន្ធផលប្រយោជន៍តាមរយៈមតកសាសន៍ ម្ចាស់បណ្ដាំអាចលុបចោលនូវការបង្ហាញឆន្ទៈនោះដោយសារមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតជាសន្តតិជន ឬអច្ច័យលាភី ឬអ្នកពាក់ព័ន្ធផលប្រយោជន៍ បានដឹង ឬអាចដឹងអំពីការឆបោកនោះ។[21]

**១.១.២.៣.ការគំរាមកំហែង**

ការគំរាមកំហែង គឺជាស្ថានភាពមួយដែលម្ចាស់បណ្ដាំធ្វើការបង្ហាញឆន្ទៈ ដោយសារមានការគំរាមកំហែងអំពីសំណាក់សន្តតិជន ឬអច្ច័យលាភី ឬ អ្នកពាក់ព័ន្ធផលប្រយោជន៍ ឬតតិយជន។[22] ដោយឱ្យម្ចាស់បណ្ដាំធ្វើមតកសាសន៍ទៅតាមអ្វីដែលខ្លួនចង់បាន។ ការគំរាមកំហែង គឺអាចស្ដែងឡើងតាមរយៈពាក្យសម្ដី ឬអំពើហឹង្សា និងក្រោមរូបភាពផ្សេងៗទៀត។

**១.១.២.៤.ព័ត៌មានមិនពិត**

ព័ត៌មានមិនពិត គឺជាស្ថានភាពមួយដោយមាននៅបុគ្គលណាម្នាក់ ឬអាចជាសន្តតិជន ឬអច្ច័យលាភី ឬអ្នកពាក់ព័ន្ធផលប្រយោជន៍តាមរយៈមតកសាសន៍ ដោយបានបង្ហាញទៅភាគីម្ខាងទៀតដែលជាមតកជនខុសអំពីការពិត ហើយភាគីម្ខាងទៀតដែលជាមតកជនបានបង្ហាញឆន្ទៈ ដោយជឿជាក់ថាហេតុទាំងនោះជាការពិត។[23]

**១.១.២.៥.ការរំលោភបំពានលើស្ថានភាពពិត**

ការរំលោភបំពានលើស្ថានភាពពិត មានន័យថាភាគីម្ខាងបានប្រើប្រាស់មិនត្រឹមត្រូវនូវឋានៈរបស់ខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ទាំងខាងផ្នែកសេដ្ឋកិច្ច ឬផ្នែកសង្គម ឬបានប្រើប្រាស់ដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀតដែលផ្ទុយនឹងគោលការណ៍សមភាព ដែលភាគីម្ខាងមិនអាចប្រឆាំងតបបាន។[24] ការរំលោភបំពានលើស្ថានភាពដែលបានកើតឡើងនៅពេលធ្វើមតកសាសន៍ ដោយបុគ្គលមានផលប្រយោជន៍អាច

[21] ក្រមរដ្ឋប្បវេណី,លេខ សន/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ៣៤៧។

[22] ក្រមរដ្ឋប្បវេណី,លេខ សន/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ៣៥០។

[23] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ៣៤៨។

[24] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ៣៤៩។

ជាសន្តតិជន ឬអច្ច័យលាភី ឬ តតិយជនបានប្រើប្រាស់ឋានៈរបស់ខ្លួនមានអាទិភាពជាម្ចាស់បណ្តាំ ហើយដូចនេះមតកជនអាចលុបចោលមតកសាសន៍បានដោយហេតុថាមានវិការៈ។

## ១.២.លក្ខខណ្ឌទម្រង់ក្នុងការធ្វើមតកសាសន៍

មតកសាសន៍ ត្រូវធ្វើដោយផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ទើបអាចចាត់ទុកថាមានសុពលភាពតាមទម្រង់។[25]មតកសាសន៍ដែលធ្វើមិនត្រូវនឹងទម្រង់ណាមួយក្នុងបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ត្រូវចាត់ទុកជាមោឃៈ។[26] ប៉ុន្តែមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្តាំដូចគ្នានោះ។ នៅក្នុងករណីដែលមតកសាសន៍ ដែលគ្មានការចុះថ្ងៃខែឆ្នាំ មានចំនួនច្រើន ហើយបើមតកសាសន៍ទាំងនោះផ្ទុយនឹងគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក។[27]

ផ្អែកតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា មតកសាសន៍អាចធ្វើក្នុងស្ថានភាព ២ (ពីរ) យ៉ាងគឺ ទម្រង់មតកសាសន៍ក្នុងស្ថានភាពធម្មតា ឬទូទៅ(១.២.១.) និង មតកសាសន៍ស្ថិតក្នុងស្ថានភាពពិសេស(១.២.២.)។

### ១.២.១.មតកសាសន៍តាមទម្រង់ធម្មតា

ទម្រង់មតកសាសន៍ធម្មតាត្រូវបានបែងចែកជា ៣ (បី) ទម្រង់ដូចជាមតកសាសន៍ដោយលិខិតយថាភូត (១.២.១.១.) មតកសាសន៍ដោយលិខិតឯកជន(១.២.១.២.) មតកសាសន៍ដោយលិខិតសម្ងាត់ (១.២.១.៣.) ។

#### ១.២.១.១.មតកសាសន៍ដោយលិខិតយថាភូត

មតកសាសន៍ដោយលិខិតយថាភូត ជាលិខិតដែលធ្វើឡើងដោយសារការី ហើយត្រូវបានគេទទួលស្គាល់ថាជាប្រភេទលិខិតដែលអាចទុកចិត្តបានជាងគេ ដោយហេតុថាលិខិតនេះត្រូវបានធ្វើឡើងដោយអ្នកជំនាញពោលគឺ សារការី ដែលមតកសាសន៍ប្រភេទនេះត្រូវបានរក្សាទុកដោយសារការីតែម្តង។ សារការី ជាបុគ្គលដែលទទួលខុសត្រូវក្នុងការតាក់តែង និងមើលថែរក្សាលិខិតមតកសាសន៍នេះ រហូតដល់ម្ចាស់បណ្តាំទទួលមរណភាព និងបន្តអនុវត្តលិខិតបណ្តាំត្រូវបានបញ្ជាប់ជាស្ថាពរតាមផ្លូវច្បាប់។ ក្នុងករណីនេះសារការីដើរតួជាអ្នកប្រតិបត្តិមតកសាសន៍តែម្តង។

ដើម្បីធ្វើឱ្យមតកសាសន៍ដោយលិខិតយថាភូត មានសុពលភាពគតិយុត្ត ត្រូវតែធ្វើទៅតាមលក្ខខណ្ឌដែលមានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា។ លក្ខខណ្ឌនៃការបង្កើតមតកសាសន៍

[25] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧០ កថាខណ្ឌទី ១។

[26] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧១ កថាខណ្ឌទី ១។

[27] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧១ កថាខណ្ឌទី ២។

ប្រភេទលិខិតយថាភូត ម្ចាស់បណ្តាំត្រូវប្រាប់ដោយផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍នៅចំពោះមុខសារការី ដោយត្រូវមានវត្តមានសាក្សីយ៉ាងតិច ០២ (ពីរ) នាក់ ហើយសារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះជា លាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីស្តាប់។ បន្ទាប់ពីម្ចាស់បណ្តាំ និងសាក្សីបានទទួលស្គាល់ថាកំណត់ជាលាយលក្ខណ៍អក្សរត្រឹមត្រូវហើយ ជននីមួយៗត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និងលំនៅឋាន ហើយត្រូវចុះហត្ថលេខារៀងៗខ្លួន។ ប៉ុន្តែ បើម្ចាស់បណ្តាំមិនអាច សរសេរអក្សរ ឬមិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និងហត្ថលេខាដូចកំណត់ខាងលើដោយសរសេរឈ្មោះ អាយុ និងលំនៅឋានរបស់ខ្លួន ហើយត្រូវសរសេរបន្ថែមនូវហេតុនេះផង។ សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា។ [28]

បុគ្គលដែលមិនអាចក្លាយជាសាក្សី ឬអ្នកសង្កេតការណ៍នៅពេលធ្វើមតកសាសន៍មានដូចជា អនីតិជន ឬជននៅក្រោមអាណាព្យាបាលធម្មតា ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី សហព័ទ្ធ និងញាតិលោហិតខ្សែផ្ទាល់របស់មតកជន បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ ជាលិខិតយថាភូត ឬជាលិខិតមតកសាសន៍សម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និងនិយោជិតរបស់សារការី មិនអាចធ្វើជាសាក្សីបានឡើយ។[29]

### ១.២.១.២.មតកសាសន៍ដោយលិខិតឯកជន

មតកសាសន៍ដោយលិខិតឯកជន ជាលិខិតមតកសាសន៍ដែលម្ចាស់បណ្តាំជាអ្នកសរសេរផ្ទាល់នូវខ្លឹមសារ ពាក្យពេចន៍ទាំងមូលនៃមតកសាសន៍ព្រមទាំងចុះថ្ងៃ ខែ ឆ្នាំ និងហត្ថលេខាដោយផ្ទាល់ឯង។[30] មូលហេតុតម្រូវធ្វើការ ចុះហត្ថលេខា និងចុះថ្ងៃខែឆ្នាំដោយខ្លួនឯងផ្ទាល់ គឺដើម្បីមានភាពងាយស្រួល ករណីមានបញ្ហាទាក់ទិននឹងសុក្រឹត្យភាពនៃលិខិតមតកសាសន៍កើតឡើង គេមិនអាចទាមទារហៅសាមីខ្លួនដែលបានទទួលមរណភាពមកបញ្ជាក់ពីសេចក្តីថ្លែងការណ៍នោះទេ។ ករណីដែលលិខិតមតកសាសន៍ដោយលិខិតឯកជន ធ្វើឡើងដោយឱ្យអ្នកដទៃជាអ្នកសរសេរជំនួសម្ចាស់បណ្តាំ ឬដែលដោយប្រើម៉ាស៊ីន ដូចជាអង្គុលីលេខ ជាអាទិ៍នឹងត្រូវចាត់ទុកជាមោឃៈ។[31] ចំពោះករណីដែលម្ចាស់បណ្តាំចង់បន្ថែម ការលុប ឬការកែប្រែផ្សេងទៀតនៅក្នុងមតកសាសន៍ ម្ចាស់បណ្តាំត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់អំពីការផ្លាស់ប្តូរនោះ ហើយចាំបាច់ត្រូវចុះហត្ថលេខាដើម្បីជាការបញ្ជាក់ និងអាចជាភស្តុតាងក្នុងការផ្ទៀងផ្ទាត់នៅពេលក្រោយ ថាតើការផ្លាស់ប្តូរត្រូវបានធ្វើឡើង

[28] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៣ កថាខណ្ឌទី ២។

[29] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧២។

[30] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៤ កថាខណ្ឌទី ១។

[31] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៤ កថាខណ្ឌទី១ វាយខណ្ឌទី ២។

ដោយម្ចាស់បណ្តាំពិតប្រាកដដែរ ឬទេ? ការតម្រូវឱ្យចុះហត្ថលេខាបញ្ជាក់នេះ ដើម្បីបញ្ចៀសករណីដែលមានជនដទៃ ឬសន្តតិជន ឬជនមានផលប្រយោជន៍ដទៃទៀតធ្វើការផ្លាស់ប្តូរខ្លឹមសារនៃលិខិតបណ្តាំ។

**១.២.១.៣.មតកសាសន៍ដោយលិខិតសម្ងាត់**

មតកសាសន៍ដោយលិខិតសម្ងាត់ ជាវិធីមួយដែលសារការីបញ្ជាក់ថាមានមតកសាសន៍ ប៉ុន្តែអ្វីៗក្នុងមតកសាសន៍នោះ ត្រូវបានរក្សាជាការសម្ងាត់។ ម្ចាស់បណ្តាំ ត្រូវចុះហត្ថលេខាក្នុងលិខិតដោយខ្លួនឯងផ្ទាល់។ ប៉ុន្តែ ម្ចាស់បណ្តាំត្រូវសុំឱ្យអ្នកណាម្នាក់ សរសេរខ្លឹមសារលើមតកសាសន៍ ឬអាចប្រើប្រាស់កុំព្យូទ័របាន។ ម្ចាស់បណ្តាំត្រូវដាក់លិខិតបណ្តាំនោះក្នុងស្រោមសំបុត្របិទជិត ព្រមទាំងសរសេរសញ្ញាសម្គាល់លើមាត់សំបុត្រ ដើម្បីឱ្យដឹងនៅពេលគេបើកស្រោមសំបុត្រ ហើយត្រូវដាក់នៅចំពោះមុខសារការីម្នាក់ និងសាក្សីពីរនាក់ ដោយថ្លែងការណ៍ថា នេះគឺជាមតកសាសន៍ ជាអាទិ៍។ ប្រសិនបើម្ចាស់បណ្តាំមិនអាចនិយាយបាន គាត់ត្រូវប្រើភាសាសញ្ញា ឬត្រូវសរសេរ ។[32] សារការី ម្ចាស់បណ្តាំ និងសាក្សី ត្រូវចុះហត្ថលេខាលើលិខិតបិទជិតនោះ។ បើទោះបីជាមិនស្របនឹងលក្ខខណ្ឌនៃមតកសាសន៍ដោយលិខិតសម្ងាត់ក៏ដោយ ក៏អាចមានសុពលភាពជាមតកសាសន៍ដោយលិខិតឯកជនដែរ ដរាបណាមតកសាសន៍នោះអនុលោមតាមបញ្ញត្តិស្តីពីលិខិតមតកសាសន៍ដោយលិខិតឯកជន។[33]

**១.២.២. មតកសាសន៍ក្នុងស្ថានភាពពិសេស**

បន្ទាប់ពីធ្វើការបកស្រាយទៅលើមតកសាសន៍ក្នុងទម្រង់ទូទៅ ឬធម្មតាមក ក្រមរដ្ឋប្បវេណីក៏បានបើកផ្លូវផងដែរ ចំពោះស្ថានភាពពិសេសមួយចំនួន ដែលអាចឱ្យម្ចាស់បណ្តាំអាចធ្វើមតកសាសន៍បានក្នុងស្ថានពិសេសចំនួន ៥ (ប្រាំ) ដូចជា៖ មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ (១.២.២.១.) មតកសាសន៍ជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់ជីវិត (១.២.២.២.) ជនដែលត្រូវជាប់ឃុំឃាំង និងជនជាប់ក្នុងនាវា ឬយន្តហោះ (១.២.២.៣.) មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍ (១.២.២.៤ ) មតកសាសន៍ជនជាតិខ្មែររស់នៅបរទេស (១.២.២.៥.)។ មតកសាសន៍ក្នុងស្ថានភាពពិសេសមិនមែនជាទម្រង់នៃមតកសាសន៍ខុសពីទម្រង់ធម្មតាទេ គ្រាន់តែជាស្ថានភាពដោយឡែកមួយដែលច្បាប់ជួយសម្រួលឱ្យម្ចាស់បណ្តាំអាចមានលទ្ធភាពក្នុងការធ្វើមតកសាសន៍។

**១.២.២.១.មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ**

បើទោះបីជាជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅត្រូវបានចាត់ទុកថាជាជនដែលត្រូវបានកម្រិតសមត្ថភាពក៏ដោយ ក៏ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់សិទ្ធិ ឱ្យធ្វើបណ្តាំផងដែរនៅ

[32] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៩ កថាខណ្ឌទី ១។

[33] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ ៣, កែសម្រួលលើការបោះពុម្ពលើកទី១ (ភ្នំពេញ៖ ទីភ្នាក់ងារប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន, ឆ្នាំ២០១៧),ទំព័រ ៥៣ ។

ពេលដែលជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅនោះបានជាសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិតយ៉ាងតិច ២ (ពីរ) នាក់។[34] វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍ថា នៅពេលដែលម្ចាស់បណ្ដាំបានធ្វើមតកសាសន៍ ម្ចាស់បណ្ដាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិត។ [35]

ប្រសិនជនស្ថិតក្រោមអាណាព្យាបាលទូទៅ ធ្វើមតកសាសន៍ដោយលិខិតឯកជន ឬលិខិតសម្ងាត់ ក្នុងករណីនេះ ចាំបាច់តម្រូវឱ្យមានវេជ្ជបណ្ឌិត ដើម្បីធ្វើជាសាក្សីនៅពេលសរសេរមតកសាសន៍ដោយផ្ទាល់ ឬនៅពេលដែលម្ចាស់បណ្ដាំបង្ហាញខ្លឹមសារនៃមតកសាសន៍ឱ្យទៅសារការី។ រីឯករណីដែលជននោះធ្វើមតកសាសន៍ជាលិខិតយថាភូត ចាំបាច់តម្រូវឱ្យមានវត្តមានសាក្សីផ្សេងទៀតក្រៅពីវេជ្ជបណ្ឌិតផងដែរ។ ផ្ទុយទៅវិញប្រសិនបើគ្មានវត្តមានរបស់វេជ្ជបណ្ឌិត នៅពេលធ្វើលិខិតមតកសាសន៍តាមគ្រប់ទម្រង់នៃលិខិតមតកសាសន៍ដូចបានកំណត់ក្នុងក្រមរដ្ឋប្បវេណីនោះទេ លិខិតមតកសាសន៍ទាំងនោះនឹងត្រូវចាត់ទុកជាមោឃៈ។ មានតែវេជ្ជបណ្ឌិតប៉ុណ្ណោះដែលអាចមានសមត្ថភាពក្នុងការវិនិច្ឆ័យពីស្ថានភាពស្មារតី របស់ម្ចាស់បណ្ដាំបាន។

### ១.២.២.២.មតកសាសន៍ជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់ជីវិត

ជនដែលកំពុងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារជំងឺ ឬហេតុផ្សេងទៀតមតកជនមានបំណងចង់ធ្វើលិខិតបណ្ដាំ ក៏អាចធ្វើបានដែរ ដោយតម្រូវឱ្យមានវត្តមានសាក្សីចំនួន៣ (បី)នាក់ ជាអ្នកបញ្ជាក់ក្នុងស្ថានភាពនាពេលនោះ។ មតកជនត្រូវប្រកាសអំពីខ្លឹមសារនៃមតកសាសន៍នោះដោយផ្ទាល់មាត់ចំពោះជនម្នាក់ ក្នុងចំណោមសាក្សីទាំងបី ហើយជនដែលទទួលបានការប្រកាសដោយផ្ទាល់មាត់ ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្ដាប់ ឬឱ្យមើលហើយក្រោយពេលដែលសាក្សីនីមួយៗ បានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗត្រូវចុះហត្ថលេខាលើលិខិតមតកសាសន៍។[36]

យ៉ាងណាមិញមតកសាសន៍ក្នុងស្ថានភាពជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់ជីវិត នឹងមិនមានអានុភាពឡើយ ប្រសិនបើសាក្សីណាម្នាក់ ឬបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ពុំបានដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍ ហើយពុំបានទទួលការ

[34] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៦ កថាខណ្ឌទី ១។

[35] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៦ កថាខណ្ឌទី ២។

[36] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៧ កថាខណ្ឌទី ១។

បញ្ជាក់ទេ។ [37] គួរបញ្ជាក់ផងដែរថា ទោះក្នុងកាលៈទេសៈនេះក៏ដោយ ជនដែលត្រូវហាមឃាត់មិនឱ្យក្លាយជាសាក្សី ឬធ្វើជាអ្នកសង្កេតការណ៍ កំឡុងពេលធ្វើលិខិតបណ្តាំក៏ត្រូវយកមកអានុវត្តដូចគ្នានឹងករណីខាងលើ គឺមិនអាចក្លាយជាសាក្សីបានឡើយ។

**១.២.២.៣.មតកសាសន៍ជនដែលត្រូវជាប់ឃុំឃាំង និងជនជាប់ក្នុងនាវា ឬយន្តហោះ**

ជនដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែកដោយសាលក្រម ឬសាលដីកា ឬដោយការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បានដោយត្រូវឱ្យមានវត្តមានរបស់នគរបាល ឬមន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និងសាក្សីយ៉ាងតិច ២(ពីរ) នាក់។ [38] ស្ថិតក្នុងស្ថានភាពបែបនេះគេក៏អាចធ្វើមតកសាសន៍តាមលិខិតយថាភូត ឬតាមលិខិតសំងាត់បានដែរ ដោយនគរបាល ឬមន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ ដើរតួនាទីជាសារការី។

បុគ្គលដែលនៅក្នុងនាវា ឬយន្តហោះ អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានមេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះម្នាក់ និងសាក្សីយ៉ាងតិច ២(ពីរ) នាក់។[39]បើទោះជាស្ថិតក្នុងស្ថានភាពបែបនេះ មតកជនមិនអាចស្វែងរកសារការីដើម្បីធ្វើលិខិតយថាភូត ឬលិខិតសម្ងាត់បានក៏ដោយ ក៏ក្រមរដ្ឋប្បវេណីបានបើកផ្លូវឱ្យមតកជនអាចធ្វើមតកសាសន៍ដោយលិខិតយថាភូត និងលិខិតឯកជនបានផងដែរ ដោយឱ្យ មេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះម្នាក់ដើរតួនាទីជាសារការីបាន។ [40] ចំពោះម្ចាស់បណ្តាំ ដែលមិនមានជំងឺ ឬមិនចេះសរសេរអក្សរ ក្នុងស្ថានភាពឃុំឃាំង ឬជាប់ក្នុងនាវា ឬយន្តហោះ អាចប្រាប់ផ្ទាល់មាត់ ទៅនគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះនោះបាន។[41]

មតកសាសន៍ ក្នុងស្ថានភាពដូចបានរៀបរាប់ខាងលើ គ្រាន់តែជាមតកសាសន៍ដែលធ្វើឡើងជាបណ្តោះអាសន្នប៉ុណ្ណោះ ដូច្នេះមតកសាសន៍នឹងបាត់បង់នូវអានុភាព ប្រសិនបើម្ចាស់បណ្តាំអាចរស់នៅរយៈពេល ៦ខែ ក្រោយពេលចេញពីកន្លែងឃុំឃាំង ឬក្រោយពេលចុះពីនាវា ឬយន្តហោះ ជាអាទិ៍។[42]

[37] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៧ កថាខណ្ឌទី ២។

[38] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៨ កថាខណ្ឌទី ១។

[39] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៨ កថាខណ្ឌទី ២។

[40] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ ៣, កែសម្រួលលើការបោះពុម្ពលើកទី១ (ភ្នំពេញ៖ ទីភ្នាក់ងារប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន, ឆ្នាំ២០១៧),ទំព័រ ៥៤ ។

[41] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៨ កថាខណ្ឌទី ៣។

[42] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៨ កថាខណ្ឌទី ៥។

### ១.២.២.៤. មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍

សម្រាប់ជនពិការផ្នែកណាមួយដូចជា៖ មិនអាចនិយាយបាន តែអាចមើលឃើញ ហើយមានបំណងចង់ធ្វើលិខិតបណ្តាំ តើគាត់ត្រូវធ្វើយ៉ាងដូចម្តេច? យ៉ាងណាមិញឃើញថាទោះបីជាជនពិការក៏ច្បាប់នៃព្រះរាជាណាចក្រកម្ពុជានៅតែការពារពួកគាត់ដូចបុគ្គលដទៃទៀតដែលមិនពិការដែរ។ ផ្អែកតាមគោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិគឺ រូបវន្តបុគ្គលគ្រប់រូបមានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន។[43]

មតកសាសន៍ នៃជនដែលមិនអាចនិយាយបាន ត្រូវបានធ្វើឡើងសម្រាប់បុគ្គលមិនអាចនិយាយបាន ដោយប្រើប្រាស់ការធ្វើកាយវិការជំនួសឱ្យការនិយាយ និងមានការបកប្រែពីអ្នកបកប្រែ ឬការសរសេរខ្លឹមសារនៃលិខិតបណ្តាំដោយដៃរបស់ម្ចាស់បណ្តាំផ្ទាល់។ ថ្វីបើម្ចាស់បណ្តាំជាជនដែលមិនអាចនិយាយបាន ប៉ុន្តែច្បាប់បានអនុញ្ញាតឱ្យប្រើប្រាស់ភាសាសញ្ញាតាមការបកប្រែរបស់អ្នកបកប្រែ ឬសរសេរដោយដៃខ្លួនឯងផ្ទាល់ចំពោះមុខសារការី ឬសាក្សី ដើម្បីជំនួសការនិយាយប្រាប់ពីសេចក្តីថ្លែងការណ៍។[44] ចំពោះករណីខាងលើត្រូវបានប្រើប្រាស់សម្រាប់ម្ចាស់បណ្តាំដែលអាចសរសេរអក្សរបាន និងយល់ដឹងពីអ្វីដែលខ្លួនបានសរសេរ។

ក្រោយពីបានសរសេរលិខិតបណ្តាំជាលាយលក្ខណ៍អក្សររួច សារការីត្រូវអានខ្លឹមសារអត្ថន័យនៅក្នុងបណ្តាំឱ្យម្ចាស់បណ្តាំ និងសាក្សីបានស្តាប់ ឬឱ្យអ្នកបកប្រែជាអ្នកធ្វើកាយវិការតាមភាសាសញ្ញាបង្ហាញដល់ម្ចាស់បណ្តាំ ឬសាក្សីដែលមិនអាចស្តាប់ឮ តែអាចមើលឃើញ។ ករណីសារការី និងជនផ្សេងទៀតត្រូវសរសេរអំពីហេតុទាំងនោះចូលក្នុងលិខិតមតកសាសន៍ផងដែរ។[45]

ក្នុងករណីនេះ អ្នកបកប្រែភាសាសញ្ញាជាបុគ្គលដ៏សំខាន់ក្នុងការធ្វើលិខិតមតកសាសន៍នោះឡើងប្រសិនបើគ្មានវត្តមានអ្នកបកប្រែភាសាសញ្ញាទេ លិខិតមតកសាសន៍នោះក៏មិនអាចធ្វើឡើងបានដែរ។ ទោះបីជាអាចធ្វើឡើងមកបាន ក៏មិនមានអានុភាពគ្រប់គ្រាន់ក្នុងការអនុវត្តន៍ដែរ ដោយសារតែសារការី និងសាក្សីមិនអាចយល់ពីភាសាសញ្ញារបស់ម្ចាស់បណ្តាំ ហើយម្ចាស់បណ្តាំក៏មិនអាចយល់ពីខ្លឹមសារដែលសារការីបានសរសេរដែរ។ ដើម្បីឱ្យលិខិតមតកសាសន៍នោះ មានអានុភាពគ្រប់គ្រាន់ទើបចាំបាច់តម្រូវឱ្យមានវត្តមានរបស់អ្នកបកប្រែភាសាសញ្ញាក្នុងការធ្វើលិខិតមតកសាសន៍របស់ជនដែលមិនអាចនិយាយបាន។ ហើយអ្នកបកប្រែសញ្ញានេះទៀតសោតត្រូវបានចាត់ជាសាក្សីដ៏សំខាន់ក្នុងការធ្វើមតកសាសន៍ប្រភេទនេះ។

[43] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៦។

[44] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៩ កថាខណ្ឌទី ១។

[45] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៩ កថាខណ្ឌទី ៣។

ចំពោះសាក្សីជាបុគ្គលមិនអាចស្ដាប់ឮ(ថ្លង់) តែអាចមើលឃើញ ក៏មិនខុសអ្វីពីម្ចាស់លិខិតមតកសាសន៍ដែលធ្វើឡើងដោយជនដែលមិនអាចនិយាយបានដែរ ដោយតម្រូវឱ្យមានអ្នកបកប្រែភាសាកាយវិការ ឬភាសាសញ្ញា ដើម្បីធ្វើកាយវិការឱ្យសាក្សីនោះបានយល់ពីខ្លឹមសារនៅក្នុងមតកសាសន៍។

**១.២.២.៥.មតកសាសន៍ជនជាតិខ្មែររស់នៅបរទេស**

ជនជាតិខ្មែរដែលមានបំណងចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត លិខិតសម្ងាត់អាចធ្វើនៅកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ ដែលកុងស៊ុលនោះត្រូវអនុវត្តមុខនាទីរបស់សារការី។[46]

ម្យ៉ាងវិញទៀត ជនជាតិខ្មែរដែលរស់នៅបរទេសក៏អាចប្រើប្រាស់វិធីសាស្ត្រផ្សេងទៀត ក្នុងការធ្វើលិខិតមតកសាសន៍ទៅតាមទម្រង់មតកសាសន៍នានា ដូចបានកំណត់ក្នុងច្បាប់របស់ប្រទេសដែលខ្លួនរស់នៅ ប៉ុន្តែត្រូវធ្វើនៅចំពោះមុខសារការីនៃប្រទេសដែលខ្លួនរស់នៅ។ ចំពោះការធ្វើលិខិតមតកសាសន៍នេះ ត្រូវធ្វើឡើងនៅចំពោះមុខសារការីដែលជាជនបរទេស និងត្រូវការប្រើប្រាស់ភាសានៃប្រទេសដែលខ្លួនបានរស់នៅក្នុងការសរសេរខ្លឹមសារនៃលិខិតមតកសាសន៍។ ការធ្វើបែបនេះ គឺដើម្បីអនុញ្ញាតឱ្យជនដែលមិនចេះភាសាបរទេសអាចមានលទ្ធភាពធ្វើមតកសាសន៍ជាលិខិតយថាភូត ឬលិខិតសម្ងាត់ជាភាសាខ្មែរបាន នៅកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្តតួនាទីជំនួសសារការី ដើម្បីឱ្យលិខិតមតកសាសន៍នោះមានអានុភាពគ្រប់គ្រាន់ក្នុងការយកមកអនុវត្ត ហើយវត្តមានរបស់កុងស៊ុលគឺមានភាពចាំបាច់ចំពោះការធ្វើលិខិតមតកសាសន៍របស់ម្ចាស់បណ្ដាំដែលរស់នៅបរទេស។[47]

---

[46] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨១។

[47] គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី, សេចក្ដីកំណត់ចំពោះមាត្រានីមួយៗ ភាគ ៦,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០) ,មាត្រា ១១៨១។

# ជំពូកទី២

# ការជ្រើសរើស និងតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍

# ជំពូកទី២
# ការជ្រើសរើស និងតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍

## ២.១.ការពិនិត្យបញ្ជាក់ និងការបើកលិខិតមតកសាសន៍

ការពិនិត្យបញ្ជាក់លិខិតមតកសាសន៍ ធ្វើឡើងដើម្បីឱ្យជនដែលមានពាក់ព័ន្ធនឹងផលប្រយោជន៍បញ្ជាក់ដឹងឮ និងដើម្បីកំណត់នូវខ្លឹមសារនៃមតកសាសន៍ ជៀសវាងកុំឱ្យមានការលួចកែប្រែក្រោយពេលបើកបណ្តាំ។ ដូច្នេះ ទោះជាមានបញ្ហាទាក់ទងនឹងទម្រង់ ឬខ្លឹមសារ នៃមតកសាសន៍ក៏ដោយ ក៏នីតិវិធីបញ្ជាក់ត្រូវបានអនុវត្តដែរ។[48] ក្រៅពីលិខិតមតកសាសន៍ដោយលិខិតយថាភូត មតកសាសន៍ទាំងអស់ត្រូវធ្វើការពិនិត្យបញ្ជាក់រួមទាំងមតកសាសន៍ដោយវិធីពិសេស។ ជាពិសេសត្រូវកត់សម្គាល់ថា មតកសាសន៍ដោយជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់ជីវិតត្រូវបានបញ្ជាក់ដោយតុលាការរួចហើយ ប៉ុន្តែ នៅតែតម្រូវឱ្យមានការពិនិត្យបញ្ជាក់ម្តងទៀតនៅពេលដែលបណ្តាំមានអានុភាព ពីព្រោះថាការពិនិត្យបញ្ជាក់បន្ទាប់ពីស្ថានភាពបន្ទាន់ដល់ជីវិតជាការបញ្ជាក់ទៅលើឆន្ទៈរបស់ម្ចាស់បណ្តាំថាពិតប្រាកដដែរឬទេ ហើយការពិនិត្យបញ្ជាក់នៅពេលបណ្តាំមានអានុភាព គឺបញ្ជាក់ទៅលើអត្ថិភាពនៃមតកសាសន៍។[49] មានតែលិខិតយថាភូតមួយតែប៉ុណ្ណោះ ដែលច្បាប់មិនតម្រូវឱ្យពិនិត្យបញ្ជាក់នៅតុលាការ។[50]

គោលបំណងនៃការពិនិត្យបញ្ជាក់មតកសាសន៍ គឺជាការរក្សាទុកនូវភស្តុតាង។ តាមរយៈការពិនិត្យបញ្ជាក់ តុលាការបានកត់ត្រាទុកនូវស្ថានភាពខាងក្រៅនៃមតកសាសន៍ ជៀសវាងការក្លែងបន្លំ ឬការផ្លាស់ប្តូរ។ ដូច្នេះ តុលាការនឹងកត់ត្រាទុកនូវមតកសាសន៍ដោយការថតចម្លង ការថតយករូបភាព និងការពណ៌នាស្ថានភាពខាងក្រៅនៃមតកសាសន៍ដោយផ្ទាល់មាត់។ ម្យ៉ាងវិញទៀត តុលាការនឹងមិនវិនិច្ឆ័យលើសុពលភាពរបស់បណ្តាំ ឬមតកសាសន៍ទេ។ ប្រសិនបើមានបុគ្គលណាម្នាក់ចង់លើកមតិប្រឆាំងលើសុពលភាពនៃមតកសាសន៍ បុគ្គលនោះត្រូវដាក់ពាក្យប្តឹងទៅតុលាការ។ ការបញ្ជាក់នូវសុពលភាពនៃមតកសាសន៍ មិនមែនជាគោលបំណងនៃការពិនិត្យបញ្ជាក់ទេ។[51]

អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ក្រោយពីបានដឹងពីការចាប់ផ្តើមសន្តតិកម្ម ត្រូវបង្ហាញឯកសារមតកសាសន៍ទៅកាន់តុលាការ ដោយគ្មានការយឺតយ៉ាវ ហើយតុលាការត្រូវពិនិត្យបញ្ជាក់។ ករណីគ្មានអ្នកថែ

[48] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ភាគ៦,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០) ,មាត្រា ១២១៣។

[49] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៧ កថាខណ្ឌទី ២ និងកថាខណ្ឌទី ៣។

[50] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៣ កថាខណ្ឌទី ២។

[51] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ ៣ បោះពុម្ពលើកទី១ (ភ្នំពេញ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន,២០១៣), ទំព័រ ៦៤។

រក្សាគ្រប់គ្រងលិខិតមតកសាសន៍ គេត្រូវធ្វើដូចខាងលើដែរ ក្រោយពេលសន្តតិជន ឬជនពាក់ព័ន្ធនឹងផលប្រយោជន៍ បានរកឃើញលិខិតមតកសាសន៍។[52] ប្រសិនបើសន្តតិជនបានរកឃើញមតកសាសន៍ដែលរហែក ហើយពួកគេគិតថាមតកសាសន៍ត្រូវបានលុបចោល ពួកគេនៅតែត្រូវប្រគល់មតកសាសន៍ទៅឱ្យតុលាការដើម្បីពិនិត្យបញ្ជាក់ ពីព្រោះតុលាការគឺជាអ្នកកំណត់ចុងក្រោយថា មតកសាសន៍ត្រូវបានលុបចោល ឬក៏អត់។

ប្រសិនបើមតកសាសន៍ត្រូវបានបិទដោយប្រថាប់ត្រា គេមិនត្រូវបើកមតកសាសន៍ទេ។ អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រា សន្តតិជន ឬជនពាក់ព័ន្ធនឹងផលប្រយោជន៍ ត្រូវប្រគល់លិខិតមតកសាសន៍ ទៅកាន់តុលាការ ដោយមិនត្រូវបើកមើលឡើយ។ ជាធម្មតា មតកសាសន៍ដែលបិទដោយប្រថាប់ត្រា គឺជាលិខិតមតកសាសន៍ដោយលិខិតសម្ងាត់។ ប៉ុន្តែ ម្ចាស់បណ្តាំក៏អាចបិទប្រថាប់ត្រានូវមតកសាសន៍ដោយលិខិតផ្ទាល់ខ្លួនផងដែរ។ ករណីនេះ គេមិនត្រូវបើកមើលមតកសាសន៍ដោយលិខិតផ្ទាល់ខ្លួនដែលបានបិទប្រថាប់ត្រាទេ។[53]

ជនដែលបានបើកលិខិតមតកសាសន៍ដោយមិនបានធ្វើការពិនិត្យបញ្ជាក់ ត្រូវពិន័យជាប្រាក់មិនលើសពី ១(មួយ) លានរៀល។[54] ប៉ុន្តែ ទោះបីមតកសាសន៍ត្រូវបើកនៅក្រៅតុលាការក៏ដោយ មតកសាសន៍ក៏នៅតែមានសុពលភាពដដែល។[55]

### ២.១.១.នីតិវិធីពិនិត្យបញ្ជាក់នៅតុលាការ

ការពិនិត្យបញ្ជាក់មតកសាសន៍ត្រូវកំណត់ពីសមត្ថកិច្ចរបស់តុលាការ ឱ្យបានច្បាស់លាស់ (២.១.១.១.) និងធ្វើការកោះហៅសន្តតិជន ជាអាទិ៍ឱ្យចូលរួមក្នុងការពិនិត្យបញ្ជាក់ (២.១.១.២.) ហើយតុលាការត្រូវធ្វើការកត់ត្រាចំណុចសំខាន់ៗនៃការពិនិត្យបញ្ជាក់ (២.១.១.៣.)។

#### ២.១.១.១.សមត្ថកិច្ចតុលាការ

សាលាដំបូងដែលមានសមត្ថកិច្ច គឺទីកន្លែងនៃការចាប់ផ្តើមសន្តតិកម្ម ហើយ កន្លែងចាប់ផ្តើមសន្តតិកម្មគឺជាអាស័យដ្ឋានរបស់មតកជននៅពេលទទួលមរណភាព។[56] ពោលគឺ សាលាដំបូងនៃអាស័យដ្ឋានរបស់មតកជននៅពេលទទួលមរណភាព ជាសាលាដំបូងដែលមានសមត្ថកិច្ច។

[52] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៣ កថាខណ្ឌទី ១។

[53] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ ៣ បោះពុម្ពលើកទី១ (ភ្នំពេញ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន,២០១៣), ទំព័រ ៦៥។

[54] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៣ កថាខណ្ឌទី ៤។

[55] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៣ កថាខណ្ឌទី ៥។

[56] ច្បាប់ស្តីពីនីតិវិធីរឿងនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣,០៨ សីហា ២០១០,មាត្រា ៤ ផ្នែក ៥ ចំណុច៥។

### ២.១.១.២.ការកោះហៅសន្តតិជន ជាអាទិ៍

ជាទូទៅ សន្តតិជនជាអ្នកដាក់ពាក្យសុំស្នើឱ្យតុលាការពិនិត្យបញ្ជាក់លើមតកសាសន៍ ប៉ុន្តែប្រសិនបើមានអ្នកគ្រប់គ្រង ថែរក្សាមត៌កជាតតិយជន អ្នកថែរក្សាត្រូវយកទៅឱ្យតុលាកាដើម្បីធ្វើការពិនិត្យបញ្ជាក់។ យោងតាមក្រមរដ្ឋប្បវេណី មិនតម្រូវថាឱ្យមានវត្តមានសន្តតិជន ឬអច្ច័យលាភីប៉ុន្មាននាក់ទើប ការពិនិត្យបញ្ជាក់អាចធ្វើទៅបានទេ មានន័យថាមានប៉ុន្មាននាក់ក៏បាន អត់ក៏បាន។ តែបើទោះបីជាយ៉ាងណាក៏ដោយតុលាការគួរតែអនុញ្ញាតឱ្យសន្តតិជន ឬអច្ច័យលាភីទាំងអស់ មានឱកាសចូលរួមនីតិវិធីពិនិត្យបញ្ជាក់ បើទោះបីជាគោលបំណងនៃការពិនិត្យបញ្ជាក់ មិនបញ្ជាក់ទៅលើសុពលភាពក៏ពិតមែន ប៉ុន្តែបើសិនជាសន្តតិជន ឬអ្នកមានពាក់ព័ន្ធផលប្រយោជន៍បានចូលរួម ហើយពួកគេមើលឃើញថាមតកសាសន៍មានភាពមិនប្រក្រតី ដូចជាខុសទម្រង់ជាដើម អាចដាក់ពាក្យប្តឹងប្រឆាំងលើសុពលភាពនៃមតកសាសន៍បាន ។ ដូច្នេះ តុលាការគួរគប្បីកំណត់ពេលវេលាសម្រាប់ការពិនិត្យបញ្ជាក់ ហើយកោះហៅសន្តតិជន ឬអច្ច័យលាភីទាំងអស់ឱ្យចូលរួម តែបើមិនអាចចូលរួមទាំងអស់ក៏នីតិវិធីនៃការពិនិត្យបញ្ជាក់អាចដំណើរការបានទៅជាធម្មតា។

ជាពិសេស ប្រសិនបើលិខិតមតកសាសន៍បិទដោយប្រថាប់ត្រា មតកសាសន៍នឹងត្រូវបើកនៅក្នុងតុលាការដោយមានវត្តមានរបស់ សន្តតិជន ឬអ្នកពាក់ព័ន្ធផលប្រយោជន៍ ឬអ្នកតំណាងរបស់ពួកគេ។[57] មានន័យថា កាលណាមតកសាសន៍បិទដោយប្រថាប់ត្រា តុលាការត្រូវកោះហៅសន្តតិជន និងអច្ច័យលាភីឱ្យចូលរួមក្នុងការបើកលិខិត ប៉ុន្តែ ជាធម្មតាតុលាការមិនស្គាល់អច្ច័យលាភីទេ ពីព្រោះមតកសាសន៍ត្រូវបានបិទដោយប្រថាប់ត្រាបាត់ទៅហើយ ដែលកត្តាដែលតុលាការមិនអាចធ្វើការកោះហៅអច្ច័យលាភីបានទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីមតកសាសន៍បិទដោយប្រថាប់ត្រា មិនមែនមានន័យថា គ្រប់សន្តតិជនទាំងអស់ត្រូវមានវត្តមានទាំងអស់ទេ បើសន្តតិជន ឬ អ្នកពាក់ព័ន្ធផលប្រយោជន៍ណាមិនបានចូលរួមក្នុងនីតិវិធិពិនិត្យបញ្ជាក់ក៏ដោយ បើសិនជារកឃើញថាបណ្តាំមានបញ្ហា ឬខុសទម្រង់ណាមួយពួកគេនៅតែអាចប្តឹងលើសុពលភាពនៃបណ្តាំបាន។[58]

### ២.១.១.៣.ចំណុចសំខាន់ៗនៃការពិនិត្យបញ្ជាក់

តុលាការត្រូវពិនិត្យមតកសាសន៍ ទោះបីជាមតកសាសន៍ហាក់បីដូចជាគ្មានសុពលភាព ឬត្រូវបានលុបចោលក្តី ក៏តុលាការត្រូវតែធ្វើការពិនិត្យបញ្ជាក់ដែរ បើមានការស្នើសុំពីសន្តតិជន ឬអ្នកដែលពាក់ព័ន្ធផលប្រយោជន៍ក្នុងបណ្តាំ។ តុលាការគប្បីកត់ត្រាចំណុចសំខាន់ៗដូចជា បុគ្គលណាដែលបានស្នើសុំពិនិត្យបញ្ជាក់

---

[57] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៣ កថាខណ្ឌទី ៣។

[58] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ ៣ បោះពុម្ពលើកទី១ (ភ្នំពេញ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន,២០១៣), ទំព័រ ៦៥។

កាលបរិច្ឆេទនៃដំណើរការនីតិវិធីពិនិត្យបញ្ជាក់ បុគ្គលដែលមានវត្តមាននៅពេលធ្វើនីតិវិធីពិនិត្យបញ្ជាក់ ស្ថានភាពខាងក្រៅនៃមតកសាសន៍ ដូចជា ចំនួនទំព័រ ប្រភេទគុណភាពក្រដាស់ ប្រភេទប៊ិច ហត្ថលេខា និង កាលបរិច្ឆេទ នៅក្នុងមតកសាសន៍ ថតរូបភាព និង ថតចម្លងមតកសាសន៍ជាដើម។

## ២.២.ការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍

ការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍ អាចធ្វើឡើងតាមរយៈការជ្រើសតាំងដោយមតកជន តតិយជន និងតុលាការ (២.២.១.) ហើយម្ចាស់បណ្ដាំ ឬតុលាការ អាចធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ច្រើននាក់បាន ឬសហអ្នកប្រតិបត្តិមតកសាសន៍ទៅតាមទំហំនៃមត៌ក។ ច្បាប់ក៏បានមហាឃាត់ជនមួយចំនួន មិនអាចក្លាយជាអ្នកប្រតិបត្តិផងដែរ ដូចជាជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ (២.២.២.) ជននៅក្រោមហិតូបត្ថម្ភ អនីតិជន និង ជនក្ស័យធនជាដើម(២.២.៣.) ។

### ២.២.១.ការជ្រើសរើសដោយមតកជន តតិយជន និងតុលាការ

ម្ចាស់បណ្ដាំអាចធ្វើមតកសាសន៍ ដោយកំណត់ជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍នៅក្នុងបណ្ដាំដោយខ្លួនឯង (២.២.១.១.) ឬប្រគល់អាណត្តិឱ្យតតិយជនជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬច្រើននាក់បាន។[59] ដូច្នេះ ប្រសិនបើមតកសាសន៍បានកំណត់អំពីការជ្រើសតាំង ឬប្រគល់អាណត្តិឱ្យតតិយជនជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនត្រូវផ្ដល់ដំណឹងទៅបុគ្គលដែលត្រូវបានជ្រើសតាំង ឬតតិយជនឱ្យបានឆាប់រហ័សបំផុត។ [60](២.២.១.២.) បើពុំមានការកំណត់អ្នកប្រតិបត្តិមតកសាសន៍ទេ តុលាការអាចធ្វើការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍បានផងដែរ តាមការទាមទាររបស់សន្តតិជន ឬអ្នកពាក់ព័ន្ធផលប្រយោជន៍បាន (២.២.១.៣.)។

#### ២.២.១.១.ការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍ដោយមតកជន

ម្ចាស់បណ្ដាំអាចធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍បាន ប៉ុន្តែ អ្នកដែលត្រូវបានកំណត់ឱ្យបំពេញមុខងារជាអ្នកប្រតិបត្តិមតកសាសន៍ ទទួលកាន់មុខងារ ឬយ៉ាងណា គឺត្រូវគោរពតាមឆន្ទៈរបស់ជនដែលបានកំណត់ថាជាអ្នកប្រតិបត្តិមតកសាសន៍។[61] មានន័យថាជនដែលត្រូវបានជ្រើសតាំងជាអ្នកប្រតិបត្តិមតកសាសន៍ មិនត្រូវបានបង្ខំឱ្យកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍ទេ។

[59] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨៦។

[60] ក្រុមការងារនៃគ្រូបណ្ដុះបណ្ដាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណីភាគ ៣ បោះពុម្ពលើកទី១ (ភ្នំពេញ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន,២០១៣), ទំព័រ ៦៦។

[61] គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី, សេចក្ដីកំណត់ចំពោះមាត្រានីមួយៗ ភាគ ៦,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០) ,មាត្រា ១២១៥។

ផ្ទុយទៅវិញ កាលណាជនដែលបានជ្រើសតាំងជាអ្នកប្រតិបត្តិ បានយល់ព្រមកាន់មុខងារហើយ គាត់ត្រូវអនុវត្តមុខងារភ្លាម។[62] គ្មានបញ្ញត្តិដែលចែងអំពីវិធីក្នុងការទទួលយកការកាន់មុខងារទេ ប៉ុន្តែ ជាធម្មតាអ្នកប្រតិបត្តិមកសាសន៍ត្រូវធ្វើការទទួលយកមុខងារ ជាអ្នកប្រតិបត្តិមតកសាសន៍ តាមយៈការបង្ហាញឆន្ទៈទៅកាន់សន្តតិជន។

ម្យ៉ាងទៀត ប្រសិនបើអ្នកប្រតិបត្តិមតកសាសន៍មិនបានបង្ហាញឆន្ទៈឱ្យបានច្បាស់លាស់ទេ សន្តតិជន ឬជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចកំណត់រយៈពេលសមរម្យណាមួយ ដោយធ្វើការដាស់តឿនទៅជនដែលត្រូវបានជ្រើសតាំងជាអ្នកប្រតិបត្តិមតកសាសន៍ ដោយទាមទារឱ្យគាត់ផ្តល់ចម្លើយជាក់លាក់មួយថា តើគាត់យល់ព្រមកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍ ឬយ៉ាងណា។ ប្រសិនបើគាត់មិនបានផ្តល់ចម្លើយជាក់លាក់មួយក្នុងពេលកំណត់ទេ ត្រូវចាត់ទុកថាគាត់បានលាឈប់ពីមុខងារ។[63]

**២.២.១.២.ការប្រគល់អាណត្តិឱ្យតតិយជនដើម្បីជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍**

ក្នុងការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ ម្ចាស់បណ្តាំក៏អាចប្រគល់អាណត្តិឱ្យតតិយជនណាម្នាក់ជាអ្នកកំណត់អ្នកប្រតិបត្តិមតកសាសាន៍បាន។ ករណីនេះ ជនដែលទទួលបានអាណត្តិ ត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍ ហើយត្រូវជូនដំណឹងទៅឱ្យសន្តតិជនដោយគ្មានការយឺតយ៉ាវ។ ម្យ៉ាងទៀត ប្រសិនបើម្ចាស់បណ្តាំមិនបានហាមឃាត់ទេ ជនដែលទទួលបានអាណត្តិអាចកំណត់យកខ្លួនឯងធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ក៏បានដែរ។[64] ទោះបីជាទទួលបានអាណត្តិពីម្ចាស់បណ្តាំឱ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ក៏ដោយ ក៏មិនមែនបានសេចក្តីថា ជនដែលទទួលបានអាណត្តិ មានករណីយកិច្ចត្រូវតែទទួលមុខងារដោយស្វ័យប្រវត្តិដែរ ពោលគឺគាត់អាចបដិសេធមិនទទួលអាណត្តិបាន។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បណ្តាំបានប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិមតកសាសន៍តាមមតកសាសន៍ ប្រសិនបើតតិយជនមិនបានលុបចោលនូវអាណត្តិវិញទេ មិនអាចយកនីតិវិធីផ្សេងណាមួយ ដើម្បីធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បានឡើយ ហេតុដូច្នេះហើយ ប្រសិនបើជនដែលទទួលបានអាណត្តិ មានបំណងលាឈប់ពីអាណត្តិត្រូវជូនដំណឹងទៅឱ្យសន្តតិជនដោយគ្មានការយឺតយ៉ាវ ហើយសន្តតិជន ឬ អ្នកដែលពាក់ព័ន្ធផលប្រយោជន៍អាចស្នើសុំទៅតុលាការឱ្យធ្វើការជ្រើសរើសអ្នកប្រតិបត្តិផ្សេងទៀតបាន ដោយមូលហេតុនៃការលាឈប់របស់តតិយជនដែលជាអ្នកទទួលអាណត្តិរបស់

[62] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៥។

[63] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៦ កថាខណ្ឌទី ១។

[64] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ភាគ ៦,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០) ,មាត្រា ១២១៤ កថាខណ្ឌទី១ វាក្យខណ្ឌទី ២ ។

មតកជន។[65] ចំពោះករណីតតិយជន ដែលត្រូវបានប្រគល់អាណត្តិឱ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ ពុំបាន កំណត់អ្នកប្រតិបត្តិមតកសាសន៍ឱ្យបានឆាប់រហ័ស នៅក្នុងអំឡុងពេលដែលសន្តតិជន ឬអ្នកពាក់ព័ន្ធផល ប្រយោជន៍បានកំណត់ពេលសមរម្យណាមួយទេ ត្រូវចាត់ទុកថាបានលាឈប់ពីអាណត្តិ ហើយសន្តតិជន ឬអ្នក ពាក់ព័ន្ធផលប្រយោជន៍អាចស្នើសុំឱ្យតុលាការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បាន ដោយមូលហេតុនៃការ មិនអនុវត្តមុខងាររបស់តតិយជនដែលជាអ្នកទទួលអាណត្តិ។[66]

### ២.២.១.៣.ការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍ដោយផ្លូវតុលាការ

ក្នុងករណីគ្មានអ្នកប្រតិបត្តិមតកសាសន៍ ឬអ្នកដែលបានជ្រើសតាំងបានបដិសេធមិនព្រមកាន់មុខងារ ជាអ្នកប្រតិបត្តិទេ តុលាការអាចធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ តាមការទាមទាររបស់សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍បាន។ ម្យ៉ាងទៀត ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍បានកាត់មុខ ងារហើយ តែក្រោយមកបានទទួលការអនុញ្ញាតពីតុលាការឱ្យលាឈប់ ឬទទួលមរណភាព តុលាការក៏អាចធ្វើ ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ជាថ្មីផងដែរ។[67]

### ២.២.២.សហអ្នកប្រតិបត្តិមតកសាសន៍

ម្ចាស់បណ្តាំ ឬតុលាការអាចធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ច្រើននាក់បាន។ តើករណីណា ខ្លះគួរមានសហអ្នកប្រតិបត្តិមតកសាសន៍? ចំពោះទ្រព្យសម្បត្តិដែលមានតម្លៃតិចម្ចាស់បណ្តាំ ឬតុលាការគប្បី ពិចារណាជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍ម្នាក់ជាការគ្រប់គ្រាន់ ដោយហេតុថាអ្នកប្រតិបត្តិមតកសាសន៍ ច្រើន កម្រៃដែលត្រូវចំណាយលើអ្នកប្រតិបត្តិមតកសាសន៍ក៏ច្រើនតាមនឹងដែរ ប៉ុន្តែប្រសិនបើបណ្តាំដែលមាន ទ្រព្យសម្បត្តិច្រើនដូចជាមានលុយក្នុងកុងធនាគារ ផ្ទះ និងដី នៅច្រើនកន្លែងទាំងក្នុងប្រទេស និងក្រៅប្រទេស ដែលអ្នកប្រតិបត្តិមតកសាសន៍តែម្នាក់ឯងមិនអាចប្រតិបត្តិ ឬរ៉ាប់រងតែម្នាក់ឯងបានទាន់ពេលឱ្យទៅសន្តតិជន ឬអ្នកពាក់ព័ន្ធផលប្រយោជន៍ទេ គប្បីមានអ្នកប្រតិបត្តិច្រើនរូបទៅតាមទំហំនៃការងារដើម្បីប្រយោជន៍របស់ សន្តតិជន និងអ្នកពាក់ព័ន្ធផលប្រយោជន៍។ ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍មានចំនួនច្រើននាក់ ការ អនុវត្តត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាល លើកលែងតែម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងនៅក្នុង

[65] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ភាគ៦,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០) ,មាត្រា ១២១៤។

[66] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៦ កថាខណ្ឌទី ២។

[67] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ភាគ ៦,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០) ,មាត្រា ១២១៨,និង មាត្រា ៣ នៃច្បាប់ស្តីពីនីតិវិធីនៃ រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង ឧបសម្ព័ន្ធ ផ្នែកទី ៥ ចំណុចទី៦។

មតកសាសន៍។[68] ការអនុវត្តសម្លេងលើសពីពាក់កណ្តាល មានន័យជាសម្លេងសេស ពោលគឺអ្នកប្រតិបត្តិមតកសាសន៍គប្បីមានចំនួនសេសដូចគ្នា ដើម្បីឱ្យសម្លេងអាចលើសពីពាក់កណ្តាលបាន ប៉ុន្តែច្បាប់ក៏មិនបានហាមឃាត់ម្ចាស់បណ្តាំមិនឱ្យកំណត់អ្នកប្រតិបត្តិជាចំនួនគូរដែរ ប៉ុន្តែម្ចាស់បណ្តាំគួរគប្បីកំណត់ក្នុងបណ្តាំថាឱ្យអ្នកប្រតិបត្តិរូបណាជាអ្នកមានសម្លេង ឧត្តមានុភាពដើម្បីអាចធ្វើការសម្រេចចុងក្រោយបាន។

អ្នកប្រតិបត្តិមតកសាសន៍នីមួយៗអាចធ្វើសកម្មភាពរក្សាទុកបាន មានន័យអ្នកប្រតិបត្តិមតកសាសន៍អាចទាមទារយកទ្រព្យសម្បត្តិដែលមានចែងក្នុងបណ្តាំរបស់មតកជនមកធ្វើការគ្រប់គ្រង ឬរក្សាទុកបាន បើទោះបីជាទ្រព្យបានស្ថិតក្នុងការគ្រប់គ្រងរបស់សន្តតិជន ឬតតិយជនក៏ដោយ ក៏អ្នកប្រតិបត្តិអាចស្នើសុំឱ្យប្រគល់ទ្រព្យឱ្យខ្លួនកាន់កាប់កំឡុងពេលប្រតិបត្តិបានដែរ ហើយករណីដែលមិនព្រមប្រគល់ដោយស្ម័គ្រចិត្តអាចដាក់ពាក្យបណ្តឹងទៅតុលាការ ដោយបង្គាប់ឱ្យជនទាំងនោះប្រគល់ទ្រព្យបាន។

### ២.២.៣.បុគ្គលដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍

ជាគោលការណ៍ បុគ្គលណាក៏ដោយអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានដែរ ដូចជា មិត្តភក្តិរបស់មតកជន សាច់ញាតិរបស់មតកជន ឬមេធាវី ជាដើម។ លើសពីនេះទៀត នីតិបុគ្គល សន្តតិជនម្នាក់ក្នុងចំណោមសន្តតិជនទាំងអស់ ឬអច្ច័យលាភី ក៏អាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានដែរ។[69] ប៉ុន្តែ សម្រាប់ជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ អនីតិជន និង ជនក្ស័យធន មិនអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានទេ។[70] មួយវិញទៀតសោត នីតិបុគ្គលក៏អាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍បានដែរ។

## ២.៣.តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍

វត្តមានរបស់អ្នកប្រតិបត្តិមតកសាសន៍ ពុំមានភាពដាច់ខាតទេ ក្នុងករណីដែលបណ្តាំពុំមានកំណត់ពីអ្នកប្រតិបត្តិមតកសាសន៍ ហើយសន្តតិជនយល់ឃើញថាកម្មវត្ថុនៃទ្រព្យសម្បត្តិក្នុងមតកសាសន៍តិចតួចពេក ឬពុំមានភាពស្មុគស្មាញ ពុំមានភាពចាំបាច់ក្នុងការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ទេ អាចធ្វើការប្រតិបត្តិដោយខ្លួនឯងបានក្នុងចំណោមសហសន្តតិជនតាមការស្នើសុំទៅតុលាការឱ្យ ធ្វើការជ្រើសតាំងខ្លួនជាអ្នកប្រតិបត្តិ។ ប៉ុន្តែ ប្រសិនបើម្ចាស់បណ្តាំបានជ្រើសអ្នកប្រតិបត្តិមតកសាសន៍ហើយអ្នកប្រតិបត្តិមតកសាសន៍បានយល់ព្រមកាន់មុខងារ សន្តតិជនពុំអាចបដិសេធវត្តមានអ្នកប្រតិបត្តិមតកសាសន៍បានឡើយ លើកលែងតែសហសន្តតិជនព្រមព្រៀងគ្នាមិនយកបណ្តាំមកអនុវត្ត ហើយធ្វើការបែងចែកតាមការព្រមព្រៀងវិញ។ នៅពេលដែលអ្នកប្រតិបត្តិ

[68] មេធាវី អ៊ីវ ប៉ូលី,នីតិរដ្ឋប្បវេណី៖(មេរៀនសង្ខេប)(ភ្នំពេញ,ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ទំព័រ ២៣។

[69] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ ៣ បោះពុម្ពលើកទី១ (ភ្នំពេញ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន,២០១៣), ទំព័រ ៦៨។

[70] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៧ ។

មតកសាសន៍បានយល់ព្រមកាន់មុខងារហើយ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវអនុវត្តភារកិច្ច ភ្លាមៗ។[71] ភារកិច្ចរបស់អ្នកប្រតិបត្តិមតកសាសន៍ អាចធ្វើទៅបានត្រឹមតែអ្វីដែលមានចែងក្នុងបណ្តាំប៉ុណ្ណោះ មិនមែនវិសាលភាពធ្វើលើសពីអ្វីដែលមានចែងក្នុងបណ្តាំទេ។

តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍មានច្រើនរួមមានការដាក់ពាក្យសុំផ្តាច់ ឬលុបចោលការផ្តាច់មត៌ក (២.៣.១) ការដាក់ពាក្យបណ្តឹងទៅតុលាការ (២.៣.២.) ការស្រាវជ្រាវមត៌ក (២.៣.៣.)ការធ្វើបញ្ជីសារពើភ័ណ្ឌ (២.៣.៤.) ការគ្រប់គ្រងមត៌ក និងប្រតិបត្តិតាមខ្លឹមសារនៃមតកសាសន៍(២.៣.៥.) ការចុះបញ្ជីអចលនវត្ថុឱ្យអច្ច័យទានកំណត់ (២.៣.៦.) ការជ្រើសរើសអ្នកប្រតិបត្តិបន្ត (២.៣.៧.)។ល។

### ២.៣.១. ការដាក់ពាក្យសុំផ្តាច់ ឬលុបចោលការផ្តាច់មត៌ក

ក្នុងករណីដែលបានកំណត់ក្នុងមតកសាសន៍អំពីការផ្តាច់មត៌កពីសន្តតិជន ឬលុបចោលការផ្តាច់មត៌កអ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការ នៃកន្លែងដែលចាប់ផ្តើមសន្តតិកម្ម។ [72] ក្នុងករណីដែលមតកសាសន៍បានកំណត់អំពីការផ្តាច់មត៌ក ឬការលុបចោលការផ្តាច់មត៌ក វត្តមានរបស់អ្នកប្រតិបត្តិមតកសាសន៍ត្រូវមានជាចាំបាច់ ព្រោះមានតែអ្នកប្រតិបត្តិមត៌កសាសនទេ ដែលជាអ្នកមានលក្ខណៈសម្បត្តិជាអ្នកដាក់ពាក្យសុំទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ករណីដែលមានការខូចខាតណាមួយកើតមានឡើងចំពោះសន្តតិជន អ្នកប្រតិបត្តិមតកសាសន៍ជាអ្នកទទួលខុសត្រូវ។[73]

ការដាក់ពាក្យសុំផ្តាច់មត៌ក ឬលុបចោលការផ្តាច់មត៌ក អ្នកប្រតិបត្តិមតកសាសន៍ត្រូវភ្ជាប់មកជាមួយនូវមតកសាសន៍ដែលមានអានុភាពអនុវត្ត ឯកសារបញ្ជាក់អត្តសញ្ញាណអ្នកប្រតិបត្តិមតកសាសន៍ សៀវភៅគ្រួសាររបស់មតកជន ភស្តុតាងគាំទ្រអង្គហេតុជាមូលហេតុនៃការទាមទារ។[74]

### ២.៣.២.ការដាក់ពាក្យបណ្តឹងទៅតុលាការ និងឋានៈជាភាគីនៃបណ្តឹង

ខ្លឹមសារនៃមតកសាសន៍មានកម្មវត្ថុមិនត្រឹមតែទ្រព្យសម្បត្តិទេ ម្ចាស់បណ្តាំអាចសរសេរចំណុចផ្សេងទៀតដូចជា ការផ្តល់ដំបូន្មាន ឬយោបល់ ដើម្បីឱ្យមានភាពសុខដុមរមនាដល់គ្រួសារ និងចំណុចផ្សេងទៀត។ នៅក្នុងករណីនេះ សន្តតិជនជាអាទិ៍ត្រូវគោរពទៅតាមមតកសាសន៍។[75] ពិសេសជាងនេះទៅទៀត ខ្លឹមសារនៃមតកសាសន៍ ម្ចាស់បណ្តាំអាចធ្វើការទទួលស្គាល់កូនតាមរយៈមតកសាសន៍បានផងដែរ ហើយអ្នកដែលមាន

[71] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១២១៥។

[72] ច្បាប់ស្តីពីនីតិវិធីរឿងនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣,០៨ សីហា ២០១០,ផ្នែក ៥ ចំណុច២។

[73] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១១៥២ និងមាត្រា ១១៥៤។

[74] សិស្សសារការីជំនាន់ទី២៖ លោក ស៊ិន ច័ន្ទផល្លុន,តារាងសង្ខេបនីតិវិធីប្រតិបត្តិមតកសាសន៍ និងការជម្រះមត៌កក្នុងករណីព្រមដោយកម្រិត,ដំណាក់កាលទី២៖ សកម្មភាពមុនពេលបែងចែក។

[75] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១១៨៧។

តួនាទីក្នុងការដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់កូន គឺជាអ្នកប្រតិបត្តិមតកសាសន៍ ដែលត្រូវដាក់ពាក្យបណ្ដឹងទៅតុលាការនៃទីកន្លែងដែលចាប់ផ្ដើមសន្តតិកម្ម។[76] ក្នុងករណីផ្សេងទៀត អ្នកប្រតិបត្តិមតកសាសន៍ក៏អាចមានតួនាទីដាក់ពាក្យសុំទៅតុលាការដើម្បីកំណត់ពីអ្នកណាព្យាបាលសម្រាប់អនីតិជន ចំពោះកូនមតកជនផងដែរ ប្រសិនបើអ្នកអាណាព្យាលចុងក្រោយបង្អស់របស់អនីតិជន ដែលជាម្ចាស់បណ្ដាំមានកំណត់ពីអ្នកអាណាព្យាបាលសម្រាប់អនីតិជនតាមមតកសាសន៍។[77]

ម្យ៉ាងវិញទៀតក្នុងករណីដែលមានបណ្ដឹងពាក់ព័ន្ធនឹងមតកសាសន៍ ជាគោលការណ៍នៅពេលដែលបណ្ដាំមានអានុភាព សិទ្ធិ និងករណីកិច្ច គឺធ្លាក់ទៅសន្តតិជនដោយស្វ័យប្រវត្តិ ដូច្នេះនៅពេលមានបណ្ដឹងតវ៉ាពាក់ព័ន្ធនឹងបណ្ដាំ សន្តតិជន ឬសហសន្តតិជនមានតួនាទីជាភាគីនៃបណ្ដឹង ប៉ុន្តែករណីដែលមានអ្នកប្រតិបត្តិមតកសាសន៍ គឺអ្នកប្រតិបត្តិមតកសាសន៍ត្រូវក្លាយជាភាគីនៃបណ្ដឹងវិញ។ មានន័យថាអ្នកប្រតិបត្តិមតកសាសន៍មានតួនាទីគ្រប់គ្រង និងចាត់ចែងបណ្ដាំ ហើយនៅដែលមានបណ្ដឹង ឬមានបញ្ហាណាមួយដែលនាំឱ្យខូចខាតដល់ទ្រព្យសម្បត្តិដែលមានចែងក្នុងបណ្ដាំ អ្នកប្រតិបត្តិត្រូវក្លាយទៅជាភាគីនៃបណ្ដាំក្នុងការការពារផលប្រយោជន៍របស់សហសន្តតិជន។

### **២.៣.៣.ការស្រាវជ្រាវមត៌ក**

ក្នុងករណីដែលមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំចាំបាច់ធ្វើការស្រាវជ្រាវមត៌កឡើយ ព្រោះវាជាកិច្ចការរបស់អ្នកប្រតិបត្តិមតកសាសន៍ក្នុងការស្រាវជ្រាវ និងធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិជាមត៌ក។ ក្នុងករណីមត៌កដែលមិនមានចែងក្នុងបណ្ដាំ សន្តតិជនអាចស្រាវជ្រាវអំពីមត៌ក ព្រមទាំងកាតព្វកិច្ចរបស់មតកជនមុនបង្ហាញឆន្ទៈយល់ព្រម ឬបោះបង់សន្តតិកម្ម។ ការស្រាវជ្រាវមត៌ក ពុំទាមទារទម្រង់ណាមួយឡើយ។

ជាទូទៅអ្នកប្រតិបត្តិមតកសាសន៍ ធ្វើការស្រាវជ្រាវតែទ្រព្យដែលមានចែងក្នុងបណ្ដាំ ដោយមិនគិតពីទ្រព្យអកម្ម ឬកាតព្វកិច្ចរបស់មតកជនឡើយ ប៉ុន្តែក្នុងករណីអ្នកប្រតិបត្តិមតកសាសន៍ធ្វើការស្រាវជ្រាវរកឃើញថា ទ្រព្យអកម្ម ឬកាតព្វកិច្ចរបស់មតកជនមានច្រើនជាងទ្រព្យសកម្ម អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើការជូនដំណឹងទៅសហសន្តតិជនឱ្យបានដឹង។ ចំពោះសហសន្តតិជនវិញ ក្នុងករណីដែលបានដឹងពីការជូនដំណឹងរបស់អ្នកប្រតិបត្តិមតកសាសន៍ ឬធ្វើការស្រាវជ្រាវមត៌កដែលមិនបានចែងក្នុងបណ្ដាំ ហើយរកឃើញទ្រព្យអកម្ម ឬកាតព្វកិច្ចមានច្រើនជាងទ្រព្យសកម្ម សហសន្តតិជននឹងពិភាក្សាគ្នាអំពីការជម្រះមត៌ក។

[76] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, នស/រកម/០៦១០/០០៨,១២ មិថុនា ២០១០,មាត្រា ៥ កថាខណ្ឌទី ១។

[77] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១០៦៨ កថាខណ្ឌទី ១។

### ២.៣.៤.ការធ្វើបញ្ជីសារពើភ័ណ្ឌ

អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ហើយប្រគល់បញ្ជីសារពើភ័ណ្ឌទៅឱ្យសន្តតិជនដោយគ្មានការយឺតយ៉ាវ ពោលគឺមានន័យថាក្រោយពីកាន់មុខងារហើយ ដំបូងបំផុត អ្នកប្រតិបត្តិមតកសាសន៍ត្រូវរៀបចំធ្វើបញ្ជីសារពើភ័ណ្ឌ ជាអាទិ៍ភ្លាម។[78]ក្នុងខ្លឹមសារនៃបញ្ជីសារពើភ័ណ្ឌ អ្នកប្រតិបត្តិមតកសាសន៍អាចយកខ្លឹមសារដែលមានរៀបរាប់នៅក្នុងបណ្ដាំមកបំពេញចូលក្នុងបញ្ជីសារពើភ័ណ្ឌដែលជាទ្រព្យសម្បត្តិ ហើយយកមកផ្ទៀងផ្ទាត់នឹងទ្រព្យសម្បត្តិដែលមានបច្ចុប្បន្នជាក់ស្ដែងដែលបានធ្វើការស្រាវជ្រាវ ថាតើទ្រព្យសម្បត្តិណាខ្លះនៅមានអត្ថិភាព ឬលែងមានអត្ថិភាពទៀតហើយ ព្រោះថាបណ្ដាំអាចមានរយៈពេលយូរ លទ្ធភាពក្នុងការចាត់ចែងចេញពីបេតិកភណ្ឌរបស់ម្ចាស់បណ្ដាំអាចមានភាគរយច្រើន។ ទម្រង់នៃបញ្ជីសារពើ ភ័ណ្ឌច្បាប់ពុំមានបញ្ញត្តិជាក់លាក់ទេ អ្នកប្រតិបត្តិមតកសាសន៍អាចរៀបចំតាមភាពជាក់ស្ដែងបាន។

សន្តតិជនអាចមានវត្តមាននៅពេលដែលមានអ្នកប្រតិបត្តិមតកសាសន៍ ធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិបាន។ [79] សំណួរសួរថា តើចាំបាច់ត្រូវមានអច្ច័យទានដែលជាតតិយជន ឬម្ចាស់បំណុលចូលរួមដែរឬទេ? ករណីនេះ គឺមិនចាំបាច់ទេ ព្រោះថាបើសន្តតិជនយល់ព្រមទទួលយកសន្តតិកម្មហើយនោះ សន្តតិជននឹងត្រៀមខ្លួនសម្រាប់សងបំណុលទៅម្ចាស់បំណុលហើយមិនមានភាពចាំបាច់ មានវត្តមាននៅពេលធ្វើបញ្ជីសារពើភ័ណ្ឌនោះទេ។ ការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យនៃទ្រព្យសម្បត្តិ ត្រូវយកមកអនុវត្តចំពោះតែទ្រព្យសម្បត្តិដែលកំណត់ជាក់លាក់តែប៉ុណ្ណោះ។

### ២.៣.៥.ការគ្រប់គ្រងមត៌ក និងប្រតិបត្តិតាមខ្លឹមសារនៃមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ ជាអ្នកតំណាងដោយអាណត្តិរបស់មតកជន ដែលមានករណីយកិច្ចចាត់ចែងការងារ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត ដោយផ្អែកតាមអត្ថន័យនៃអាណត្តិ។[80] ការប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត មានន័យថាអ្នកប្រតិបត្តិមតកសាសន៍ ត្រូវបំពេញករណីយកិច្ចដោយប្រុងប្រយ័ត្ន ប្រសិនបើមានការខូចខាតទ្រព្យដែលជាមត៌ក កើតចេញពីការមិនប្រុងប្រយ័ត្នរបស់អ្នកប្រតិបត្តិមតកសាសន៍ ត្រូវសងការខូចខាតទៅតាមតម្លៃនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃមត៌ក។ សកម្មភាពទាំងឡាយដែលអ្នកប្រតិបត្តិមតកសាសន៍បានធ្វើ ក្នុងអត្ថន័យជាការប្រតិបត្តិមតកសាសន៍ នាំឱ្យសន្តតិជនពុំអាចចាត់ចែងមត៌ក ឬធ្វើសកម្មភាពផ្សេងទៀតដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ។[81] ប្រសិនបើសន្តតិជន

[78] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១២១៩ កថាខណ្ឌទី ១។

[79] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១២១៩ កថាខណ្ឌទី ២។

[80] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ៦៤០ កថាខណ្ឌទី ១។

[81] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១២២១ កថាខណ្ឌទី ១។

បានចាត់ចែងមត៌ក ឬធ្វើសកម្មភាពផ្សេងទៀតដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍ សកម្មភាពទាំងនោះនឹងត្រូវមោឃៈ។

បើទោះបីជាសកម្មភាពរបស់អ្នកប្រតិបត្តិមតកសាសន៍ បានធ្វើឱ្យមានការកម្រិតដល់សិទ្ធិរបស់សន្តតិជនក៏ដោយ ប៉ុន្តែអ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិអំណាចអាចអនុវត្តមុខងាររបស់ខ្លួនត្រឹមតែអ្វីដែលមានចែងក្នុងបណ្តាំតែប៉ុណ្ណោះ ចំពោះទ្រព្យសម្បត្តិ ឬកាតព្វកិច្ចផ្សេងទៀតដែលមិនមានមែនចែងក្នុងបណ្តាំ អ្នកប្រតិបត្តិមតកសសន៍ ពុំមានសិទ្ធិក្នុងការប្រតិបត្តិឡើយ មានន័យថាអាចមានសិទ្ធិត្រឹមតែអ្វីដែលមានចែងក្នុងបណ្តាំប៉ុណ្ណោះ។

**២.៣.៦.ការចុះបញ្ជីអចលនវត្ថុឱ្យទៅអច្ច័យទានកំណត់**

ជាគោលការណ៍ការចុះបញ្ជីអចលនវត្ថុ គឺត្រូវធ្វើឡើងរវាងបុគ្គលដែលមានសិទ្ធិ និងបុគ្គលដែលមានកាតព្វកិច្ច ឬអាចហៅបានថាម្ចាស់បំណុល និងកូនបំណុល។ រីឯក្នុងរឿងសន្តតិកម្មវិញ អច្ច័យលាភី គឺជាម្ចាស់បំណុលរបស់មតកជន ប៉ុន្តែដោយសារតែមរណភាពរបស់មតកជន ធ្វើឱ្យកាតព្វកិច្ចក្នុងការផ្ទេរកម្មសិទ្ធិទៅឱ្យអច្ច័យលាភី ត្រូវធ្លាក់ទៅសហសន្តតិជន។ អច្ច័យទានត្រូវបានធ្វើការបែងចែកកជាពីរ គឺអច្ច័យសកល និងអច្ច័យកំណត់។ ករណីដែលមានការពិភាក្សាបែងចែក ឬការកំណត់វិធីបែងចែក ឬការសម្រេចក្នុងដីកាសម្រេចបែងចែកមត៌ក ដែលកំណត់យកសន្តតិជនម្នាក់ឱ្យធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ សន្តតិជនដែលបានកំណត់អាចដាក់ពាក្យសុំចុះបញ្ជីដោយខ្លួនឯងបាន។ ក្នុងករណីដែលបានធ្វើអច្ច័យទានមានកំណត់ឱ្យអច្ច័យលាភីសហសន្តតិជន ឬអ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំចុះបញ្ជីរួមគ្នា ជាមួយនឹងអច្ច័យលាភីមានកំណត់ ពោលមានន័យថាករណីចុះបញ្ជីអចលនវត្ថុចំពោះអច្ច័យទានមានកំណត់ ប្រសិនបើមតកសាសន៍ដែលមានវត្តមានរបស់អ្នកប្រតិបត្តិមតកសាសន៍ គឺត្រូវឱ្យអ្នកប្រតិបត្តិមតកសាសន៍ធ្វើការចុះបញ្ជីរួមគ្នាជាមួយអច្ច័យលាភីមានកំណត់។

**២.៣.៧.ការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍បន្ត**

បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកប្រតិបត្តិមតកសាសន៍ពុំអាចឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួនបានឡើយ។ ប៉ុន្តែមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍។[82] ការមិនអនុញ្ញាតឱ្យតតិយជនអនុវត្តភារកិច្ចបន្ត ដោយហេតុថា ជាគោលការណ៍ដោយសារមតកជនបានជឿទុកចិត្តទៅលើចំណេះដឹង និងសមត្ថភាពរបស់អ្នកប្រតិបត្តិមតកសាសន៍ ទើបប្រគល់សិទ្ធិដែលមានលក្ខណៈផ្តាច់មុខឱ្យទៅអ្នកប្រតិបត្តិមតកសាសន៍ បើប្រគល់សិទ្ធិបន្តទៅឱ្យតតិយជន វាហាក់បីដូចផ្ទុយនឹង

[82] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១២២៤ កថាខណ្ឌទី ១។

ឆន្ទៈរបស់មតកជន ប៉ុន្តែច្បាប់ក៏មិនហាមឃាត់ទេ តែក្នុងករណីដែរអ្នកប្រតិបត្តិមានមូលហេតុដែលពុំអាចជៀសបានដូចជាអ្នកប្រតិបត្តិមតកសាសន៍ធ្លាក់ខ្លួនឈឺជាទម្ងន់មួយរយៈ ទទួលបានភារកិច្ចណាមួយដែលមិនអាចដកខ្លួនបានដែលមិនអាចប្រតិបត្តិមតកសាសន៍បាន។

ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍បានឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួន អ្នកប្រតិបត្តិមតកសាសន៍ ត្រូវទទួលខុសត្រូវក្នុងការជ្រើសរើស និងការត្រួតពិនិត្យជនដែលខ្លួនបានផ្តល់ភារកិច្ច ចំពោះអច្ច័យលាភី និងសន្តតិជន។ បើតតិយជន ដែលជ្រើសរើសដោយអ្នកប្រតិបត្តិមតកសាសន៍ទទួលអនុវត្តភារកិច្ចបន្ត ហើយអនុវត្តផ្ទុយទៅនឹងបណ្តាំមត៌ក ឬមានការខូចខាតណាមួយកើតឡើង អ្នកប្រតិបត្តិមតកសាសន៍ត្រូវសងការខូចខាតដែលកើតឡើង ចំពោះអច្ច័យលាភី និងសន្តតិជន។[83] ការទទួលខុសត្រូវក្នុងករណីខាងលើ គឺដូចគ្នានឹងករណីដែល អ្នកតំណាងជ្រើសតាំងអនុតំណាងនៃក្រមរដ្ឋប្បវេណី។[84]

## ២.៤.សោហ៊ុយ និងកម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍

ក្នុងពេលប្រតិបត្តិមតកសាសន៍អ្នកប្រតិបត្តិអាចប្រើប្រាស់សោហ៊ុយដែលមានក្នុងមត៌កដើម្បីដំណើរការការប្រតិបត្តិមតកសាសន៍ (២.៤.១.) និង មានសិទ្ធិទទួលបានកម្រៃពីការប្រតិបត្តិមតកសាសន៍របស់ខ្លួនផងដែរ (២.៤.២)។

### ២.៤.១.សោហ៊ុយក្នុងការប្រតិបត្តិមតកសាសន៍

សោហ៊ុយដែលពាក់ព័ន្ធនឹងការប្រតិបត្តិមតកសាសន៍ជាបន្ទុកនៃមត៌ក ប៉ុន្តែមិនអាចបន្ថយភាគបម្រុងដោយសារបន្ទុកទេ។[85] សោហ៊ុយដើម្បីប្រតិបត្តិមតកសាសន៍មានដូចជា សោហ៊ុយចាំបាច់ដើម្បីធ្វើនីតិវិធីពិនិត្យបញ្ជាក់លិខិតមតកសាសន៍ សោហ៊ុយធ្វើបញ្ជីសារពើភ័ណ្ឌមត៌ក សោហ៊ុយមត៌ក សោហ៊ុយគ្រប់គ្រងមត៌ក សោហ៊ុយដាក់ពាក្យសុំកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជន សោហ៊ុយដាក់ពាក្យសុំផ្តាច់មត៌ក ឬលុបចោលនូវការផ្តាច់មត៌កពីសន្តតិជនដោយមតកសាសន៍ សោហ៊ុយទាក់ទងនឹងការចុះសំបុត្រកំណើតរបស់កូនមតកជននៅក្នុងសៀវភៅកំណើត ប្រសិនបើករណីមតកសាសន៍មានការទទួលស្គាល់កូន ជាអាទិ៍។

### ២.៤.២.កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ អាចទទួលកម្រៃដែលបានកំណត់នៅក្នុងមតកសាសន៍បាន។[86] ឧបមាថាម្ចាស់បណ្តាំបានសរសេរក្នុងខ្លឹមសារនៃបណ្តាំថា ចំពោះបុគ្គលដែលជាអ្នកប្រតិបត្តិមតកសាសន៍ និងទទួលបាន

---

[83] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១២២៤ កថាខណ្ឌទី ២។

[84] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ភាគ៦,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០) ,មាត្រា ១២២៤ កថាខណ្ឌទី ២។

[85] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១២២៨។

[86] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១២២៦ កថាខណ្ឌទី ១។

ប្រាក់កម្រៃចំនួនទឹកប្រាក់ណាមួយ បន្ទាប់ពីប្រតិបត្តិការងារតាមបណ្តាំបានជោគជ័យ។ អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិបានកម្រៃស្មើនឹងទឹកប្រាក់ដែលបានកំណត់ក្នុងមតកសាសន៍ បន្ទាប់ពីការប្រតិបត្តិមតកសាសន៍បានបញ្ចប់។

មួយវិញទៀត ក្នុងករណីដែលមតកជនមិនបានកំណត់កម្រៃសម្រាប់អ្នកប្រតិបត្តិមតកសាសន៍ទេ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃកម្រៃ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ បើយល់ឃើញថាសមរម្យក្នុងការបង់កម្រៃ ដោយពិចារណាទៅលើស្ថានភាពនៃមត៌កទំនាក់ទំនងរវាងម្ចាស់បណ្តាំ និងអ្នកប្រតិបត្តិមតកសាសន៍ និងស្ថានភាពផ្សេងទៀត។[87]

## ២.៥. ការលាឈប់ និងការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍

បើមានមូលហេតុត្រឹមត្រូវ អ្នកប្រតិបត្តិមតកសាសន៍ អាចដាក់ពាក្យសុំលាឈប់ពីភារកិច្ចបាន ដោយទទួលការអនុញ្ញាតពីតុលាការ។[88] តុលាការនៃទីកន្លែងដែលចាប់ផ្តើមសន្តតិកម្ម ជាអ្នកអនុញ្ញាតឱ្យលាឈប់ និងបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍ដោយដីកាសម្រេច។[89] ការដែលបានលើកឡើងខាងលើ បានបង្ហាញអំពីភាពតឹងរឹងសម្រាប់ការបំពេញការងារ និងការលាឈប់របស់អ្នកប្រតិបត្តិមតកសាសន៍ ព្រោះការបំពេញការងារជាអ្នកប្រតិបត្តិមតកសាសន៍ទាមទារឱ្យមានការទទួលខុសត្រូវខ្ពស់ និងប្រុងប្រយ័ត្ន ដោយមិនអនុញ្ញាតឱ្យអ្នកប្រតិបត្តិមតកសាសន៍អាចធ្វើតាមទំនើងចិត្តបានឡើយ។

មូលហេតុត្រឹមត្រូវសម្រាប់ការលាឈប់ អាចមានដូចជា មានជំងឺ ត្រូវទៅបំពេញបេសកម្មនៅឆ្ងាយក្នុងរយៈពេលវែង ចូលកាន់មុខងារថ្មីដែលមានភាពមមាញឹកខ្លាំង ឬមានធុរៈចាំបាច់ណាមួយជាដើម ដែលបណ្តាលឱ្យមានការយឺតយ៉ាវក្នុងការធ្វើកិច្ចការងារ។ ម្យ៉ាងទៀត បើអ្នកប្រតិបត្តិមតកសាសន៍ធ្វេសប្រហែសក្នុងភារកិច្ចដូចជាការខ្ជិលច្រអូសក្នុងពេលធ្វើការងារ ការបាត់ខ្លួន ឬមានជំងឺរយៈពេលវែង ប្រព្រឹត្តិបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមណាមួយ ឬបើមានមូលហេតុត្រឹមត្រូវផ្សេងទៀត អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ដូចជាសន្តតិជន ឬអច្ច័យលាភីអាចដាក់ពាក្យសុំទៅតុលាការឱ្យបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍បាន។[90]

[87] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១២២៦ កថាខណ្ឌទី ២។

[88] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១២២៧ កថាខណ្ឌទី ១។

[89] ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣,០៨ សីហា ២០១០,ផ្នែក ៥ ចំណុច៨។

[90] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១២២៧ កថាខណ្ឌទី ២។

# ជំពូកទី៣

# ការបែងចែកមត៌កករណី
# មតកសាសន៍មិនបានកំណត់
# ពីវិធីបែងចែក

# ជំពូកទី៣
# ការបែងចែកមត៌កករណីមតកសាសន៍មិនបានកំណត់ពីវិធីបែងចែក

មត៌ក គឺជាទ្រព្យសម្បត្តិរបស់មតកជនដែលបានបន្សល់ទុកដែលសន្តតិជនគ្រប់រូបមានសិទ្ធិទទួលបាន។ ដូច្នេះហើយ ប្រសិនបើមត៌កទាំងនោះ គឺមានតែសាច់ប្រាក់ការបែងចែកមត៌កឱ្យមានភាពស្មើគ្នា គឺមានភាពងាយស្រួល។ ប៉ុន្តែជាទូទៅ មត៌ករួមមានទ្រព្យសម្បត្តិផ្សេងៗដូចជា ចលនវត្ថុ អចលនវត្ថុ និងសិទ្ធិលើបំណុលជាដើម។ នៅពេលចាប់ផ្តើមសន្តតិកម្ម សន្តតិជនមិនត្រឹមតែត្រូវកំណត់ចំនួនចំណែកមត៌កដែលនឹងត្រូវបែងចែកសម្រាប់សន្តតិជនម្នាក់ៗប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវកំណត់ថា សន្តតិជនរូបណានឹងត្រូវទទួលមត៌កមួយណាផងដែរ។ ដូច្នេះហើយសន្តតិជនត្រូវកំណត់នូវរបៀបនៃការបែងចែកមត៌ក។ [91] ការបែងចែកមត៌ក ជាទូទៅត្រូវធ្វើតាមរយៈការពិភាក្សារវាងសហសន្តតិជន ប្រសិនបើពួកគេពិភាក្សាមិនអាចឈានដល់ការព្រមព្រៀង ឬការពិភាក្សាមិនបានសម្រេច សន្តតិជនណាម្នាក់អាចដាក់ពាក្យសុំទៅតុលាការ ហើយតុលាការនឹងធ្វើការបែងចែកទ្រព្យសម្បត្តិតាមរយៈដីកាសម្រេច។[92]

## ៣.១. ការគ្រប់គ្រងមត៌កមុនធ្វើការបែងចែក

សន្តតិជនដែលបានកាន់កាប់មត៌កនៅពេលមតកជនទទួលមរណភាព សន្តតិជននោះអាចធ្វើការគ្រប់គ្រងមត៌កមុនធ្វើការបែងចែក (៣.១.១.) ហើយក្នុងករណីមានអ្នកប្រតិបត្តិមតកសាសន៍ បើបានកាន់កាប់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍ហើយត្រូវធ្វើការគ្រប់គ្រងមត៌ក (៣.១.២.) ផ្ទុយទៅវិញប្រសិនបើគ្មានអ្នកគ្រប់គ្រងមត៌កទេ សន្តតិជនអាចស្នើសុំឱ្យតុលាការ ធ្វើការជ្រើសរើសអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្នបាន (៣.១.៣.)។

### ៣.១.១.ការគ្រប់គ្រងដោយសន្តតិជន

សន្តតិជនដែលកាន់កាប់មត៌កនៅពេលដែលមតកជនទទួលមរណភាព ត្រូវរក្សាទុក និង គ្រប់គ្រងមត៌ករហូតដល់ពេលធ្វើការបែងចែកមត៌ក។[93] ចំពោះមត៌កដែលមិនត្រូវបានកាន់កាប់ដោយសន្តតិជនណាម្នាក់ទេ នៅពេលដែលមតកជនទទួលមរណភាព សន្តតិជនទាំងអស់ ត្រូវរក្សាទុក និង គ្រប់គ្រងជាមួយគ្នា។[94] ប៉ុន្តែ ករណីដែលមានមតកសាសន៍ ហើយអ្នកប្រតិបត្តិមតកសាសន៍គឺជាអ្នកគ្រប់គ្រងមត៌ក ដែលនៅក្នុងមតកសាសន៍បាន

[91] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ៣ បោះពុម្ពលើកទី១ (ភ្នំពេញ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន,២០១៣), ទំព័រ ៧២។

[92] ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង,នស/រកម/០៧១០/០១៣,០៨ សីហា ២០១០,មាត្រា ៣ ផ្នែក៥ចំណុច១៧។

[93] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦២ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១។

[94] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ភាគ៦,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០) ,មាត្រា ១២៦២។

កំណត់ម្ចាស់ហើយ។[95] មានន័យថា សន្តតិជនអាចធ្វើការគ្រប់គ្រងតែមត៌កដែលមិនបានកំណត់នូវម្ចាស់ជាក់លាក់នូវក្នុងមតកសាសន៍ប៉ុណ្ណោះ។ ចំពោះមត៌កដែលបានកំណត់នូវម្ចាស់ជាក់លាក់ហើយត្រូវគ្រប់គ្រងដោយអ្នកប្រតិបត្តិមតកសាសន៍។

### ៣.១.២.ការគ្រប់គ្រងដោយអ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ បើបានកាន់កាប់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍ហើយ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើការគ្រប់គ្រងមត៌ក។[96] ប៉ុន្តែ ប្រសិនបើមតកសាសន៍ទាក់ទងនឹងទ្រព្យសម្បត្តិដែលមានកំណត់ ត្រូវគ្រប់គ្រងតែទ្រព្យសម្បត្តិដែលបានកំណត់ប៉ុណ្ណោះ។[97] មានន័យថា ក្នុងករណីដែលមតកសាសន៍ចែងកំណត់អំពីទ្រព្យសម្បត្តិជាក់លាក់ណាមួយ ដូចជាករណីដែលទំហំនៃមត៌កមានដីឡូត៍ច្រើនកន្លែង តែក្នុងមតកសាសន៍កំណត់អំពីអច្ច័យទាននូវដីមួយចំនួនឱ្យទៅបុគ្គលណាម្នាក់ប៉ុណ្ណោះ ជាអាទិ៍ មួយចំនួនទៀតមិនបានកំណត់ក្នុងបណ្តាំទេ អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើការគ្រប់គ្រងតែទ្រព្យសម្បត្តិជាក់លាក់ដែលបានកំណត់ប៉ុណ្ណោះ។ ចំពោះមត៌កដែលមិនបានចែងកំណត់ក្នុងមតកសាសន៍ទេ ត្រូវធ្វើការគ្រប់គ្រងដោយសន្តតិជន។[98]

### ៣.១.៣.អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន

ប្រសិនបើគ្មានអ្នកប្រតិបត្តិមតកសាសន៍ គ្រប់គ្រងមត៌កទាំងមូល ឬមួយផ្នែកណាដែលមិនបានចែងក្នុងបណ្តាំទេ សន្តតិជន អច្ច័យលាភី ឬម្ចាស់បំណុលរបស់មតកជន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្នបាន រហូតដល់ពេលធ្វើការបែងចែកមត៌ក។[99] ចំពោះសិទ្ធិអំណាចពិសេសរបស់អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន ត្រូវបានផ្តល់ផងដែរនូវតួនាទីដែលហៅថា អ្នកការពារមត៌ក។ លើសពីនេះ ក៏បានផ្តល់នូវលក្ខណសម្បត្តិឱ្យធ្វើជាអ្នកទទួលបន្ទុកក្នុងបណ្តឹងចំពោះសិទ្ធិទាមទារពាក់ព័ន្ធនឹង មត៌ក។ ដូច្នេះ អ្នកគ្រប់គ្រងបណ្តោះអាសន្ន អាចធ្វើបណ្តឹងដើម្បីរក្សាការពារ ឬគ្រប់គ្រងមត៌កទាំងនោះបាន។[100]

---

[95] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ភាគ ៦,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០) ,មាត្រា ១២៦២ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២។

[96] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៣ វាក្យខណ្ឌទី ១។

[97] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៣ វាក្យខណ្ឌទី ២។

[98] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ភាគ ៦,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០) ,មាត្រា ១២៦៣ វាក្យខណ្ឌទី ២។

[99] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៤ កថាខណ្ឌទី ១។

[100] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ភាគ ៦,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០) ,មាត្រា ១២៦៤ កថាខណ្ឌទី ២។

## ៣.២. ប្រភេទនៃការបែងចែកមត៌ក

មតកជន អាចកំណត់ចំណែកមត៌ក របស់សហសន្តតិជនតាមរយៈមតកសាសន៍បាន។[101] មតកជន ក៏អាចកំណត់នូវវិធីបែងចែកមត៌កតាមមតកសាសន៍ ឬអាចប្រគល់អាណត្តិឱ្យតតិយជនកំណត់វិធីបែងចែក ម្យ៉ាងទៀតមតកជន អាចហាមឃាត់មិនឱ្យបែងចែកមត៌កនៅក្នុងកំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីរយៈពេលដែលចាប់ផ្តើមសន្តតិកម្ម។[102] មានន័យថា ហាមឃាត់មិនទាន់ឱ្យបែងចែកមត៌ក ក្នុងករណីដែលកូនមួយចំនួនមិនទាន់គ្រប់អាយុជានីតិជន ជាដើម។ ប៉ុន្តែ បើទោះបីជាកូនមួយចំនួនមិនទាន់គ្រប់អាយុជានីតិជនក៏ដោយបើដល់អំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកំណត់មកដល់គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម ទោះជាកូនមួយចំនួនមិនទាន់គ្រប់អាយុក៏ដោយ គឺមិនអាចហាមឃាត់មិនឱ្យបែងចែកមត៌កបាននោះទេ។

បើមតកជន បានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬច្រើនឱ្យទៅសន្តតិជនតែម្នាក់ ឬច្រើននាក់ មតកសាសន៍នឹងត្រូវបានសន្មតថាបានកំណត់ពីវិធីបែងចែកមត៌ក លើកលែងតែនៅក្នុងករណីដែលនៅក្នុងមតកសាសន៍ មានអត្ថន័យជាអច្ច័យទានយ៉ាងច្បាស់ណាស់ ដូចជាអច្ច័យទានដែលភ្ជាប់នឹងបន្ទុក ជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់ មានចំនួនលើសពីចំណែកមត៌ករបស់សន្តតិជន ត្រូវសន្មតថាបានកំណត់ចំណែកមត៌កផងដែរ។[103]

ម្យ៉ាងទៀត ប្រសិនបើមតកជនមិនបានកំណត់នូវវិធីបែងចែកនៅក្នុងមតកសាសន៍ក៏ដោយក៏នៅតែអាចធ្វើការបែងចែកមត៌កបានដដែរ ដោយសហសន្តតិជនធ្វើការពិភាក្សាគ្នាបែងចែកមត៌ក (៣.២.១.) ប៉ុន្តែប្រសិនបើការពិភាក្សាគ្នាក្នុងការបែងចែកមិនបានសម្រេច អាចស្នើសុំឱ្យតុលាការធ្វើការបែងចែកមត៌ក (៣.២.២.)។

### ៣.២.១.ការពិភាក្សាបែងចែកមត៌ករវាងសហសន្តតិជន

ការបែងចែកមត៌ក ជាគោលការណ៍ត្រូវធ្វើការបែងចែកពិភាក្សារវាងសហសន្តតិជន។ ក្នុងករណីដែលសន្តតិជន ច្រើននាក់ មត៌កត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន[104] ហើយការបែងចែកមត៌កគឺជាការប្តូរគ្នាទៅវិញទៅមករវាងសហសន្តតិជននីមួយៗ នូវចំណែកនៃកម្មសិទ្ធិអវិភាគរបស់សាមីខ្លួនម្នាក់ៗចំពោះទ្រព្យសម្បត្តិច្រើនដែលជាកម្មសិទ្ធិអវិភាគ រួចកំណត់ឱ្យមត៌កនីមួយៗ ធ្លាក់ជាកម្មសិទ្ធិឯករាជ្យដោយឡែក

[101] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨២ កថាខណ្ឌទី ១។
[102] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨៣ កថាខណ្ឌទី ១។
[103] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨៥ កថាខណ្ឌទី ១។
[104] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៤៨ កថាខណ្ឌទី ២។

របស់សហសន្តតិជនម្នាក់ ឬជាកម្មសិទ្ធិអវិភាគរបស់សហសន្តតិជនកំណត់មួយ។ ដូច្នេះ ដើម្បីបែងចែកមត៌ក ចាំបាច់ត្រូវមានការព្រមព្រៀងរវាងសហសន្តតិជនទាំងអស់។

នៅក្នុងកំឡុងពេលមួយខែបានកន្លងផុតទៅ ក្រោយពីការចាប់ផ្ដើមសន្តតិកម្ម សហសន្តតិជនអាចចាប់ផ្ដើមពិភាក្សាគ្នា ដើម្បីបែងចែកមត៌កពេលណាក៏បានដែរ។[105] ហើយបន្ទាប់មក ត្រូវកំណត់ថា តើសហសន្តតិជនយល់ព្រម ឬបោះបង់សន្តតិកម្ម រួចកំណត់នូវទំហំនៃសហសន្តតិជន ហើយបន្ទាប់មកទៀត ធ្វើការពិភាក្សាដើម្បីបែងចែកមត៌ក ដូច្នេះ ត្រូវការពេលវេលាច្រើនគួរសមដែរ។ ប៉ុន្តែ ទោះបីជាការស្រាវជ្រាវអាចធ្វើបានងាយស្រួលក៏ដោយ ក្នុងកំឡុងពេលមួយខែក្រោយមរណភាពរបស់មតកជន ចាំបាច់ត្រូវផ្ដល់ការគោរពចំពោះវិញ្ញាណក្ខ័ន្ធមតកជន ហេតុដូច្នេះហើយបានជាក្នុងកំឡុងពេលមួយខែ ហាមមិនឱ្យបែងចែកមត៌ក។[106]

ចំពោះការពិភាក្សាបែងចែកមត៌ក មិនមែនជាសកម្មភាពដែលតម្រូវឱ្យមានទម្រង់ជាក់លាក់ណាមួយទេ ហើយមិនចាំបាច់ធ្វើជាលាយលក្ខណ៍អក្សរទេ ប៉ុន្តែក្នុងការអនុវត្តជាក់ស្ដែងគប្បីមានកិច្ចសន្យាព្រមព្រៀងគ្នាក្នុងការបែងចែក ដើម្បីកុំឱ្យមានជម្លោះនៅពេលក្រោយ។ ក្នុងចំណោមមត៌កទាំងអស់ មានមត៌កខ្លះចាំបាច់ត្រូវការមានទម្រង់កំណត់មួយដើម្បីផ្ទេរសិទ្ធិ ឬដើម្បីឱ្យមានលក្ខខណ្ឌតតាំង។ ហេតុនេះហើយ ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុតាមការបែងចែកមត៌ក ការបែងចែកត្រូវធ្វើឡើងតាមទម្រង់ចាំបាច់ដើម្បីផ្ទេរសិទ្ធិនីមួយៗដូចជា លិខិតយថាភូតលាយលក្ខណ៍អក្សរ ជាអាទិ៍។[107] ករណីដូចជាការបែងចែកមត៌កជាដីធ្លីត្រូវបានបែងចែកក្នុងករណីដែលចំណែកនៃកម្មសិទ្ធិអវិភាគត្រូវបានផ្ទេរ ឬក្នុងករណីដែលដីធ្លីដែលមានឈ្មោះ មតកជនត្រូវដាក់ជាកម្មសិទ្ធិរបស់សន្តតិជនកំណត់ណាមួយតែម្នាក់ឯង ដើម្បីចុះបញ្ជីបញ្ជាក់អំពីការផ្ទេរទាំងនោះត្រូវធ្វើលិខិតយថាភូត ជាអាទិ៍។[108]

ដើម្បីការពារម្ចាស់បំណុលរបស់មតកជន ទោះបីជាការពិភាក្សាគ្នាទទួលបានលទ្ធផលល្អក៏ដោយក្នុងអំឡុងពេលកំណត់មួយ សន្តតិជន និង អ្នកគ្រប់គ្រងមត៌ក មិនអាចផ្លាស់ប្ដូរឈ្មោះ ម្ចាស់សិទ្ធិលើមត៌កទៅឱ្យសន្តតិជន ឬអច្ច័យលាភីបានឡើយរហូតដល់ពេលដែលកំឡុងពេលដែលបានកំណត់មកដល់ ជាធម្មតាកំឡុងពេលមានរយៈពេល ៣ ខែ។[109]

---

[105] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៦ កថាខណ្ឌទី ១។

[106] គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី, សេចក្ដីកំណត់ចំពោះមាត្រានីមួយៗ ភាគ ៦,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០) ,មាត្រា ១២៦៦ កថាខណ្ឌទី ១។

[107] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៦ កថាខណ្ឌទី ២។

[108]ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៣៦ កថាខណ្ឌទី ២។

[109] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨៥ វាក្យខណ្ឌទី ១។

### ៣.២.២.ការបែងចែកមត៌កដោយតុលាការ

បើការពិភាក្សារវាងសហសន្តតិជន ចំពោះការបែងចែកមត៌ក ពុំបានសម្រេច ឬបើពុំអាចពិភាក្សាបានទេ សហសន្តតិជនណាម្នាក់អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការបែងចែកមត៌កបាន។[110] តុលាការមិនអាចធ្វើការបែងចែកមត៌កដោយឆន្ទានុសិទ្ធិរបស់ខ្លួនបានទេ ពោលគឺអាចធ្វើបាននៅពេលដែលមានពាក្យសុំពីសហសន្តតិជនប៉ុណ្ណោះ។ នៅពេលតុលាការត្រូវសម្រេចករណីបែងចែកមត៌កដោយពិចារណាទៅលើស្ថានភាពមួយចំនួនដូចជា ការបែងចែកសម្រួលដោយបង់ជាប្រាក់ ប្រសិនបើសហសន្តតិជនព្រមព្រៀងដោយស្ម័គ្រចិត្ត អាចពិភាក្សាដោយឱ្យជនណាម្នាក់ទទួលមត៌កតែឯងបាន ហើយជននោះត្រូវបង់ប្រាក់សម្រួលទៅឱ្យសហសន្តតិជនផ្សេងទៀតបាន។[111] ប៉ុន្តែមាន ករណីខ្លះគ្មានសន្តតិជនណាម្នាក់ មានលទ្ធភាពដើម្បីបង់ប្រាក់សម្រួលបានទេ តុលាការអាចលក់ ហើយធ្វើការបែងចែកប្រាក់ដែលបានមកពីការលក់បាន។[112]មានន័យថា ដើម្បីបែងចែកមត៌ក តុលាការអាចដាក់លក់មត៌កបាន ហើយនីតិវិធីនៃការលក់មត៌កមានដូចជា ការបង្គាប់ដោយតុលាការឱ្យសហសន្តតិជនលក់តាមវិធីឡាយឡុងបាន។

តុលាការក៏ពិចារណាដល់ស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួន ដែលគិតទៅតាមចំនួននៅលើទ្រព្យសម្បត្តិតែមួយ ហៅថាកម្មសិទ្ធិអវិភាគ។[113] វិធីបែងចែកវត្ថុកម្មសិទ្ធិអវិភាគ ក្នុងករណីការពិភាក្សារបស់ម្ចាស់កម្មសិទ្ធិអវិភាគអំពីការបែងចែកមត៌កមិនអាចសម្របសម្រួលគ្នាបានទេ ម្ចាស់កម្មសិទ្ធិអវិភាគអាចទាមទារការបែងចែក ដោយប្ដឹងទៅតុលាការបាន ហើយតុលាការអាចបង្គាប់ឱ្យធ្វើការបែងចែកវត្ថុតាមរូបភាពដើមរបស់វា ឬប្រសិនបើមានការបារម្ភថាការបែងចែកតាមរូបដើមនឹងធ្វើឱ្យខូចតម្លៃហួសហេតុ ឬប្រសិនបើមានមូលហេតុសមរម្យតុលាការអាចបង្គាប់ឱ្យលក់ដេញថ្លៃហើយបែងចែកប្រាក់លក់តាមចំណែក ឬអាចបង្គាប់ឱ្យផ្ទេរចំណែកកម្មសិទ្ធិអវិភាគមួយភាគឱ្យម្ចាស់កម្មសិទ្ធិអវិភាគផ្សេង ដោយឱ្យបង់ប្រាក់សំណងនៃចំណែកកម្មសិទ្ធិអវិភាគបាន។[114]

លើសពីនេះ តុលាការក៏ត្រូវពិចារណាដល់ ទំនៀមទម្លាប់នៅក្នុងតំបន់ និងមតិលើសពីពាក់កណ្ដាលរបស់សហសន្តតិជន ផងដែរ។ ចំពោះ មតិលើសពីពាក់កណ្ដាលរបស់សហសន្តតិជន ពេលចាប់ផ្ដើមពិភាក្សា

[110] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៧០ កថាខណ្ឌទី ១។

[111] គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី, សេចក្ដីកំណត់ចំពោះមាត្រានីមួយៗ ភាគ៦,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០) ,មាត្រា ១២៦៧ កថាខណ្ឌទី ២។

[112] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៧១។

[113] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២០២។

[114] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២១២។

ដើម្បីបែងចែកមត៌ក មិនអាចធ្វើទៅបានទេ គឺដោយសារតែក្នុងចំណោមសហសន្តតិជនមានសហសន្តតិជនណាម្នាក់ ឬភាគច្រើនមិនសុខចិត្តសម្របមតិរបស់ខ្លួនទៅនឹងមតិភាគច្រើន។ ប៉ុន្តែ ទោះបីជាមានមតិភាគច្រើនរបស់សហសន្តតិជនក៏ដោយ ប្រសិនបើមតិមិនសមរម្យទេ ក៏តុលាការមិនត្រូវយកមកពិចារណាដែរ ហើយបើទោះជាមតិភាគតិចក៏ដោយ ប្រសិនបើសមរម្យតុលាការគួរតែស្តាប់តាមមតិភាគតិចដែរ។[115]

## ៣.៣.លំហូរនៃការបែងចែក

### ៣.៣.១.ទំហំនៃសន្តតិជន

ទំហំនៃសន្តតិជន ចំពោះសន្តតិកម្មដែលមានមតកសាសន៍ គឺមានតែសន្តតិជនដែលមានឈ្មោះនៅក្នុងបណ្តាំតែប៉ុណ្ណោះដែលមានសិទ្ធិទទួលបានទ្រព្យសម្បត្តិដែលមានកំណត់ក្នុងបណ្តាំ។ ចំពោះសន្តតិជនដែលមិនមានឈ្មោះនៅក្នុងបណ្តាំ មិនមែនមានន័យថាគាត់មិនមែនជាសន្តតិជនទេ គ្រាន់តែឆន្ទៈរបស់ម្ចាស់បណ្តាំ មិនមានបំណងបែងចែកទ្រព្យសម្បត្តិឱ្យទៅសន្តតិជននោះ ដោយទុកលទ្ធភាពឱ្យធ្វើការបែងចែកតាមច្បាប់។ មួយវិញទៀតចំពោះសន្តតិជនណាដែលមានឈ្មោះក្នុងបណ្តាំ ប៉ុន្តែបានបង្ហាញឆន្ទៈមិនទទួល ឬបោះបង់មត៌កដោយបានដាក់ពាក្យសុំទៅតុលាការ ត្រូវបានចាត់ទុកមិនមែនជាសន្តតិជនតាំងពីដំបូង ហើយទ្រព្យសម្បត្តិដែលជាចំណែកដែលបោះបង់នឹងត្រូវធ្វើការបែងចែកតាមច្បាប់។[116] មួយវិញទៀត ចំពោះសន្តតិជនណាដែលមិនបានទទួលបានចំណែកមត៌កពីមតកសាសន៍ អាចធ្វើការទាមទារភាគបម្រុងបាន។

### ៣.៣.២.ទំហំនៃមត៌ក

ទំហំនៃមត៌ក ប្រសិនបើមានទ្រព្យសម្បត្តិរបស់មតកជនបានសរសេរក្នុងបណ្តាំអស់ហើយ វាមិនមែនជាបញ្ហាទេ ព្រោះនៅពេលដែលមានអ្នកប្រតិបត្តិមតកសាសន៍ គាត់នឹងធ្វើការស្រាវជ្រាវមត៌កដែលមានចែងក្នុងបណ្តាំហើយធ្វើជាបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិដែលមានក្នុងបញ្ជីសារពើភ័ណ្ឌ គឺជាទំហំនៃមត៌ក។ ប៉ុន្តែករណីដែលទ្រព្យសម្បត្តិរបស់មតកជន មានសរសេរក្នុងបណ្តាំផង ហើយមាននៅក្រៅបណ្តាំផង សន្តតិជន ឬអ្នកគ្រប់គ្រងមត៌កអាចធ្វើការស្រាវជ្រាវមត៌កដែលមិនមានក្នុងបណ្តាំ ហើយធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិដើម្បីកំណត់ពីទំហំនៃមត៌ក។

មួយវិញទៀត គប្បីប្រុងប្រយ័ត្នពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។ ទាក់ទងនឹងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ គឺមានតែចំណែកកម្មសិទ្ធិអវិភាគរបស់មតកជនប៉ុណ្ណោះដែលក្លាយជាមត៌ក ពោលគឺមានន័យថា

---

[115] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ភាគ៦,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០) ,មាត្រា ១២៧០ កថាខណ្ឌទី ២។

[116] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦០ និងមាត្រា ១២៦១។

ករណីដែលប្តីប្រពន្ធមានទ្រព្យសម្បត្តិរួម (ទ្រព្យសម្បត្តិប្តីពាក់កណ្តាល ប្រពន្ធពាក់កណ្តាល) ហើយប្តីបានទទួលមរណភាព ដូចនេះមានតែចំណែកអវិភាគរបស់ប្តីនៅក្នុងទ្រព្យរួមជាមួយប្រពន្ធទេ ដែលជាកម្មវត្ថុនៃ មត៌ក មិនមែនទ្រព្យរួមទាំងអស់ទេ ហើយកម្មសិទ្ធិអវិភាគមួយផ្នែកទៀត ឬពាក់កណ្តាលទៀតជារបស់ប្រពន្ធ គឺមិនមែនជាកម្មវត្ថុនៃមត៌កនោះទេ។ ក្នុងករណីដែលមានវិវាទពាក់ព័ន្ធនឹងការបញ្ចូល ឬមិនបញ្ចូលទ្រព្យសម្បត្តិណាមួយជាមត៌ក ជាទូទៅគេតែងតែអនុវត្តតាមនីតិវិធីរដ្ឋប្បវេណីជាមុនសិន។[117]

### ៣.៣.៣.ការវាយតម្លៃមត៌ក

ទ្រព្យសម្បត្តិដែលជាមត៌ក គប្បីត្រូវបានវាយតម្លៃជាសាច់ប្រាក់ ដោយបុគ្គលជំនាញ ទៅតាមប្រភេទនៃមត៌ក ដែលអាចជាចលនវត្ថុ និងអចលនវត្ថុ។ ប្រសិនបើមានការព្រមព្រៀងអំពី ចំនួននៃការវាយតម្លៃ វិធីវាយតម្លៃ គេអាចសម្រេចតាមការព្រមព្រៀងរបស់សហសន្តតិជនបាន ប៉ុន្តែសហសន្តតិជនគប្បីធ្វើការកិច្ចសន្យាលើការព្រមព្រៀង ជៀសវាងមានការប្រួលប្រែនៅពេលក្រោយ។ ចំពោះអចលនវត្ថុ នៅប្រទេសជប៉ុន តុលាការអាចបង្គាប់ឱ្យដាក់ឯកសារដូចជា លិខិតវាយតម្លៃអចលនវត្ថុ លិខិតប្រកាសពន្ធសន្តតិកម្ម និងលិខិតវាយតម្លៃរបស់ក្រុមហ៊ុនអចលនវត្ថុធំៗ ដើម្បីសម្រួលយោបល់របស់ភាគី និងឈានទៅដល់ការព្រមព្រៀង។ ក្នុងករណីដែលមិនអាចព្រមព្រៀងគ្នាទេ តុលាការនឹងជ្រើសរើសអ្នកវាយដែលជាបុគ្គលមានចំណេះដឹងដូចជាអ្នកជំនាញវាយតម្លៃអចលវត្ថុ ជាដើម មកឱ្យវាយតម្លៃ។[118]

## ៣.៤.ការវិនិច្ឆ័យអំពីវិធីបែងចែក

### ៣.៤.១.វិធីនៃការបែងចែក

វិធីនៃការបែងចែកមត៌ក ត្រូវបានបែងចែកជា ៤(បួន) ដូចជា ការបែងចែកវត្ថុជាក់ស្តែង(៣.៤.១.១.) ការបែងចែកតាមការសងជំនួស(៣.៤.១.២.) ការបែងចែកដោយប្តូរជាប្រាក់(៣.៤.១.៣.) ការរក្សាទុកនូវស្ថានភាពអវិភាគ(៣.៤.១.៤.)។

[117] សាស្ត្រាចារ្យ UMEMOTO Yumi,ការអនុវត្តជាក់ស្តែងនៃការបែងចែកមត៌ក I,(ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់),ទំហំមត៌ក។

[118] សាស្ត្រាចារ្យ UMEMOTO Yumi,ការអនុវត្តជាក់ស្តែងនៃការបែងចែកមត៌ក I,(ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់),ការវាយតម្លៃមត៌ក។

**៣.៤.១.១.ការបែងចែកវត្ថុជាក់ស្តែង**

ការបែងចែកវត្ថុជាក់ស្តែង គឺជាវិធីនៃការបែងចែកវត្ថុដោយផ្ទាល់តែម្តង ពោលគឺមានន័យថាបែងចែកទ្រព្យជាក់ស្តែងដែលជាកម្មវត្ថុនៃមត៌ក ដូចជាឡាន ដី ផ្ទះ ប្រាក់ក្នុងធនាគារឱ្យទៅសន្តតិជន ឬ អច្ច័យលាភីនូវទ្រព្យសម្បត្តិតែម្តង ដោយពុំចាំបាច់ធ្វើការលក់ប្តូរជាប្រាក់ ឬការសងជំនួសឡើយ។

**៣.៤.១.២.ការបែងចែកតាមការសងជំនួស**

ការបែងចែកក្រោមលក្ខខណ្ឌនៃការបង់ប្រាក់សម្រួល គឺជាវិធីនៃការបែងចែកមត៌កដោយអនុញ្ញាតឱ្យសន្តតិជនណាម្នាក់ទទួលនូវមត៌កទាំងមូល ដោយស្ថិតក្នុងលក្ខខណ្ឌនៃការបង់ប្រាក់សម្រួលក្នុងចំនួនសមរម្យទៅឱ្យសន្តតិជនផ្សេងទៀត ឱ្យត្រូវនឹងចំណែកមត៌កដែលសន្តតិជននីមួយៗត្រូវទទួលបាន។ [119] វិធីបែងចែកដោយឱ្យសន្តតិជនណាមួយធ្វើលទ្ធកម្មលើទ្រព្យសម្បត្តិលើសពីចំណែកច្បាប់ ដោយត្រូវបង់ប្រាក់សម្រួលទៅតាមសមាមាត្រនៃចំណែកមត៌កឱ្យសន្តតិជនផ្សេងទៀត។

**៣.៤.១.៣.ការបែងចែកដោយប្តូរជាប្រាក់**

ការបែងចែកដោយប្តូរជាប្រាក់ គឺជាវិធីបែង ដោយលក់មត៌ក ហើយបែងចែកប្រាក់ថ្លៃលក់ ដោយការលក់អាចធ្វើឡើងដោយការលក់ដោយស្ម័គ្រចិត្ត ឬលក់ដោយបង្ខំដោយតុលាការ។ ចំពោះវត្ថុដែលគ្មានសន្តតិជនណាចង់ធ្វើលទ្ធកម្ម តុលាការនឹងបែងចែកដោយប្តូរជាប្រាក់ ឬប្រសិនបើសន្តតិជន គ្មានធនធានគ្រប់គ្រាន់សម្រាប់បង់ប្រាក់សម្រួលឱ្យសន្តតិជនផ្សេងទៀតទេ ក៏តុលាការអាចធ្វើការបែងចែកដោយប្តូរជាប្រាក់បានដែរ ប្រសិនបើមិនអាចជៀសវាងបាន។

**៣.៤.១.៤.ការបែងចែកដោយអវិភាគ**

ប្រសិនបើតុលាការមិនអាចបែងចែកមត៌កតាមវិធីបែងចែកតាមវត្ថុជាក់ស្តែង ឬការបែងចែកតាមការសងជំនួសមិនបានទេ តុលាការអាចសម្រេចខុសពីធម្មតាដោយបែកចែកជាអវិភាគ។ ពិសេសមត៌កដែលមានកម្មវត្ថុជាអចលនវត្ថុ ដែលភាគច្រើនតម្លៃនៃអចលនវត្ថុនៅកម្ពុជាមានភាពឡើងចុះ ធ្វើឱ្យសន្តតិជនភាគច្រើនចង់ក្លាយជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុ ជៀសជាងទទួលយកការសងជំនួស ឬលក់ប្តូរជាប្រាក់។

ប៉ុន្តែបើមើលលើគោលបំណងនៃការបែងចែក គឺដើម្បីរំលាយស្ថានភាពអវិភាគ ទើបនៅក្នុងស្ថានភាពជាក់ស្តែងតុលាការមិនងាយទុកមត៌កឱ្យនៅក្នុងស្ថានភាពអវិភាគឡើយ បើមិនអាចធ្វើការបែងចែកបានតុលាការអាចបង្គាប់ឱ្យលក់ដេញថ្លៃហើយបែងចែកប្រាក់លក់តាមចំណែក ឬអាចបង្គាប់ឱ្យផ្ទេរចំណែកកម្មសិទ្ធិអវិភាគមួយភាគឱ្យម្ចាស់កម្មសិទ្ធិអវិភាគផ្សេង ដោយឱ្យបង់ប្រាក់សំណងនៃចំណែកកម្មសិទ្ធិអវិភាគបាន ឬលទ្ធកម្ម

[119] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៧ កថាខណ្ឌទី ២។

មត៌កឱ្យទៅសន្តតិជនណាម្នាក់ ហើយបង្គាប់ឱ្យសន្តតិជននោះ ធ្វើការបង់ប្រាក់សងជំនួសដោយធ្វើការពិចារណាទៅលើមូលដ្ឋាននៃការបែងចែកដូចជា ប្រភេទលក្ខណនៃវត្ថុ សិទ្ធិដែលមានក្នុងមត៌ក អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត ស្ថានភាពជីវភាពរបស់សន្តតិជននីមួយៗ និងស្ថានភាពផ្សេងទៀត។[120]

### ៣.៤.២.មូលដ្ឋាននៃការពិចារណានៅពេលបែងចែកមត៌ក

ក្នុងការពិភាក្សាបែងចែកមត៌ក ឬការបែងចែកដោយតុលាការគប្បីមានមូលដ្ឋានមួយជាគោលក្នុងការពិចារណា ដើម្បីជៀសវាងការបែងចែកដោយមិនលំអៀង ឬមិនសុខចិត្តពីសន្តតិជនដែលអាចនាំមកនូវជម្លោះថែមទៀត។ មូលដ្ឋានក្នុងការពិចារណានៅពេលបែងចែករួមមាន មូលដ្ឋាននៃការបែងចែក (៣.៤.២.១.) សិទ្ធិអាទិភាពរបស់សហព័ទ្ធ (៣.៤.២.២.) សំណងនៃកាតព្វកិច្ចរបស់មតកជន (៣.៤.២.៣.) ទម្រង់នៃការផ្ទេរសិទ្ធិចំពោះវត្ថុជាមត៌ក ជាអាទិ៍ (៣.៤.២.៤.)។

#### ៣.៤.២.១.មូលដ្ឋាននៃការបែងចែក

បើពុំបានកំណត់វិធីបែងចែកនៅក្នុងមតកសាសន៍ទេ ការបែងចែកមត៌ក ត្រូវធ្វើដោយពិចារណាទៅលើប្រភេទ និងលក្ខណៈនៃវត្ថុ ឬសិទ្ធិដែលមាននៅក្នុងមត៌ក ឬអាយុ មុខរបរ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត ស្ថានភាពជីវភាព របស់សហសន្តតិជននីមួយៗ និងស្ថានភាពផ្សេងទៀត។[121] ពេលធ្វើការបែងចែកមត៌ករវាងសហសន្តតិជន សហសន្តតិជនត្រូវពិចារណាដល់ស្ថានភាពខាងលើ ប៉ុន្តែប្រសិនបើសហសន្តតិជនទាំងអស់បានព្រមព្រៀងគ្នា ទោះបីជាខ្លឹមសារនៃការព្រមព្រៀងខុសនឹងគោលគំនិតនៃមូលដ្ឋានក៏ដោយ បើខ្លឹមសារមិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អទេ ក៏ហេតុនេះគ្មានឥទ្ធិពលទៅលើអានុភាពនៃការព្រមព្រៀងដែរ។

ករណីដែលការបែងចែកបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃ បើយល់ឃើញថាសមរម្យ សហសន្តតិជនអាចឱ្យសហសន្តតិជនម្នាក់ ធ្វើលទ្ធកម្មទ្រព្យសម្បត្តិបាន ដោយដាក់លក្ខខណ្ឌឱ្យបង់ប្រាក់សម្រួលចំពោះសហសន្តតិជនផ្សេងទៀតបាន តាមការពិភាក្សា។[122] ក្នុងការបែងចែកវត្ថុកម្មសិទ្ធិអវិភាគ ប្រសិនបើសហសន្តតិជនព្រមព្រៀងគ្នាដោយស្ម័គ្រចិត្ត ដោយឱ្យសន្តិជនណាម្នាក់ទទួលមត៌ក ហើយព្រមព្រៀងគ្នាបង់ប្រាក់សម្រួលទៅឱ្យសន្តតិជនផ្សេងៗទៀត។ ការពិភាក្សាបើមានការព្រមព្រៀងរវាងសហសន្តតិជនទាំងអស់ហើយ

[120] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៧ កថាខណ្ឌទី ១។
[121] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៧ កថាខណ្ឌទី ១។
[122] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៧ កថាខណ្ឌទី ២។

គប្បីធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរដើម្បីជាភស្តុតាង ករណីគ្មានការព្រមព្រៀងនៅពេលក្រោយពិសេសមត៌កដែលជាអចលនវត្ថុ។

### ៣.៤.២.២.សិទ្ធិអាទិភាពរបស់សហព័ទ្ធ

ករណីសហព័ទ្ធក្លាយជាសន្តតិជន បើមានទ្រព្យសម្បត្តិដែលទទួលបានជាកម្មសិទ្ធអវិភាគជាមួយនឹងមតកជន ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ នៅក្នុងការបែងចែកមត៌ក សហព័ទ្ធមានអាទិភាពជាងសហព័ទ្ធសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិ រហូតដល់គ្រប់ចំនួននៃចំណែកមត៌ក។ [123] ទ្រព្យសម្បត្តិទាំងឡាយដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបានកំឡុងពេលអាពាហ៍ពិពាហ៍ជាគោលការណ៍ជាទ្រព្យសម្បត្តិរួម។ [124] ប្រសិនបើប្តី ឬប្រពន្ធណាម្ខាងបានទទួលមរណភាព ពាក់កណ្តាលនៃទ្រព្យសម្បត្តិ ជារបស់សហព័ទ្ធដែលនៅរស់ ហើយពាក់កណ្តាលទៀតជាមត៌ក។ មត៌កដែលមានកម្មសិទ្ធិអវិភាគជាមួយទ្រព្យរបស់សហព័ទ្ធពេលនៅរស់ ភាគច្រើនសហព័ទ្ធដែលនៅរស់តែងតែចង់ទទួលតែម្នាក់ឯង ដើម្បីជាអនុស្សាវរីយ៍រវាងសហព័ទ្ធដែលនៅរស់ និងមតកជន ហើយប្រសិនបើទទួលបាននូវកម្មសិទ្ធិតែឯង ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់មិនសូវមានភាពស្មុគស្មាញ ឬមានបញ្ហាដែរ។[125] ដូច្នេះបានជាក្នុងការបែងចែកមត៌ក ផ្តល់អាទិភាពឱ្យសហព័ទ្ធជៀសជាងសហសន្តតិជនដទៃទៀត ក្នុងការទទួលចំណែកកម្មសិទ្ធិអវិភាគរបស់មតកជន ចំពោះទ្រព្យសម្បត្តិរួម រហូតដល់បានទទួលគ្រប់ចំនួននូវចំណែកមត៌ករបស់ខ្លួន។ សហព័ទ្ធដែលនៅរស់អាចជ្រើសរើសយកវិធីបង់ប្រាក់សម្រួលជាមួយសហសន្តតិជន ដើម្បីអាចធ្វើលទ្ធកម្ម កម្មសិទ្ធិលើមត៌កអវិភាគបាន។ ប៉ុន្តែករណីដែលមត៌កដែលមានកម្មវត្ថុត្រឹមតែជាប្រាក់ទេ អាចធ្វើការបែងចែកតាមចំណែកបាន។

### ៣.៤.២.៣.សំណងនៃការកាតព្វកិច្ចរបស់មតកជន

បើមតកជនមានកាតព្វកិច្ចសហសន្តតិជនត្រូវបែងចែកមត៌កដោយពិចារណាពីថា ខ្លួនត្រូវសងកាតព្វកិច្ច និងមិនអាចប្តូរភាគបន្ទុកនៃកាតព្វកិច្ច ដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់បំណុលឡើយ។[126] ប្រព័ន្ធសន្តតិកម្មនៅកម្ពុជាប្រកាន់យកប្រព័ន្ធទទួលបន្ត មិនត្រឹមតែសិទ្ធិរបស់មតកជនទេ ថែមទាំងកាតព្វកិច្ច

[123] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៨។

[124] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៣។

[125] ក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយនៃក្រមរដ្ឋប្បវេណី ភាគ៦ គន្ថីទី៨,( ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ឆ្នាំ២០១០),មាត្រា ១១៦៨។

[126] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៩។

របស់មតកជនផងដែរ ទៅតាមចំណែកនៃមត៌ករបស់ខ្លួន។[127] សន្តតិជនត្រូវទទួលបន្តនៅកាតព្វកិច្ចទៅតាមចំណែកនៃមត៌កដែលខ្លួនទទួលបាន ដោយមិនអាចប្តូរភាគនៃកាតព្វកិច្ច ដោយគ្មានការយល់ព្រមពីម្ចាស់បំណុលឡើយ ពោលគឺមានន័យថា ជាគោលការណ៍គឺកាតព្វកិច្ចត្រូវធ្លាក់ទៅតាមចំណែកនៃមត៌កដែលសន្តតិជនទទួលបាន ប៉ុន្តែករណីដែលសន្តតិជនធ្វើការព្រមព្រៀងគ្នាផ្សេងក្រៅពីនេះ ត្រូវមានការអនុញ្ញាតពីម្ចាស់បំណុលក្នុងទិដ្ឋភាពជាក់ស្តែងនៅពេលដែលសន្តតិជនរកឃើញមតកជនមានបំណុល ហើយបំណុលមានតិចជាងមត៌កសហសន្តតិជននឹងធ្វើការសងបំណុលមុនធ្វើការបែងចែក ប្រសិនបើមត៌កមានជាប្រាក់ដែលបញ្ញើនៅធនាគារសហសន្តតិជននឹងដកយកប្រាក់ទៅសងម្ចាស់បំណុល ហើយបើគ្មានមត៌កជាប្រាក់ទេ ឬមានមិនគ្រប់ សហសន្តតិជនអាចលក់កម្មវត្ថុនៃមត៌កណាមួយប្តូរជាប្រាក់ដើម្បីយកសងម្ចាស់បំណុល។ ការដោះស្រាយបញ្ហាបំណុលមុន មានភាពងាយស្រួលនៅពេលធ្វើការបែងចែកមត៌ករវាងសហសន្តតិជន ព្រោះថានៅពេលដែលសងកាតព្វកិច្ចអស់ហើយ សហសន្តតិជននឹងអាចមើលឃើញថាតើមត៌កនៅសល់ប៉ុន្មាន ហើយធ្វើការបែងចែកយ៉ាងដូចម្តេច។

#### ៣.៤.២.៤.ទម្រង់នៃការផ្ទេរសិទ្ធិចំពោះវត្ថុជាមត៌ក ជាអាទិ៍

ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុតាមការបែងចែកមត៌ក ការបែងចែកត្រូវធ្វើតាមទម្រង់ចាំបាច់ដើម្បីផ្ទេរសិទ្ធិនីមួយៗ ដូចជាលិខិតលាយលក្ខណ៍អក្សរ ជាអាទិ៍ដើម្បីឱ្យការព្រមព្រៀងបែងចែកមានភាពច្បាស់លាស់ទាំងចលនវត្ថុ និងអចលវត្ថុ។[128] ចំពោះការបែងចែកមត៌កជាអចលនវត្ថុ ដើម្បីចុះបញ្ជីបញ្ជាក់អំពីការផ្ទេរសិទ្ធិ ជាអាទិ៍ចាំបាច់ត្រូវធ្វើជាលិខិតយថាភូត។ រីឯកម្មវត្ថុមត៌កដែលជាសិទ្ធិលើបំណុលរបស់មតកជន ក៏អាចធ្វើការព្រមព្រៀងបែងចែកទៅតាមភាគក្រៅពីចំណែកមត៌កកំណត់ដោយច្បាប់បានដែរ ក៏ប៉ុន្តែសហសន្តតិជន ត្រូវធ្វើការជូនដំណឹងអំពីការបែងចែក ឬបើធ្វើការបែងចែកដោយលិខិតយថាភូត តែមិនបានបង្ហាញលិខិតយថាភូតនោះ ឬប្រគល់លិខិតចម្លងទៅឱ្យកូនបំណុលទេ ពុំអាចតតាំងជាមួយកូនបំណុលបានឡើយ។[129] ករណីកូនបំណុលនៃមតកជនដែលបានសងសំណងតាមចំណែកមត៌កដែលកំណត់ដោយច្បាប់ចំពោះសហសន្តតិជន នៅមុនពេលបានទទួលដំណឹង កូនបំណុលអាចតតាំងចំពោះសហសន្តតិជនដែលបានធ្វើលទ្ធកម្មសិទ្ធិលើបំណុល តាមការបែងចែកមត៌កបាន។[130] ក្នុងរឿងមត៌កការផ្ទេរសិទ្ធិលើបំណុល ឬអនុប្បទានសិទ្ធិលើបំណុលមានភាពធូរស្រាល

[127] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៤៨ កថាខណ្ឌទី ១។

[128] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៦ កថាខណ្ឌទី ១។

[129] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៧៥ កថាខណ្ឌទី ១។

[130] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៧៥ កថាខណ្ឌទី ២។

ជាងការធ្វើអនុប្បទានសិទ្ធិលើបំណុលក្នុងបញ្ញត្តិពាក់ព័ន្ធនឹងកាតព្វកិច្ចដោយហេតុថា ការធ្វើអនុប្បទានសិទ្ធិលើបំណុលនៅក្នុងរឿងមត៌កតម្រូវឱ្យសហសន្តតិជនគ្រាន់តែធ្វើការជូនដំណឹងទៅឱ្យកូនបំណុលតែប៉ុណ្ណោះដែលជាលក្ខខណ្ឌចាំបាច់ ប៉ុន្តែក្នុងបញ្ញត្តិពាក់ព័ន្ធនឹងកាតព្វកិច្ចត្រូវមានការយល់ព្រមពីកូនបំណុល បើគ្រាន់តែជូនដំណឹងហើយគ្មានការយល់ព្រមពីកូនបំណុល អានុប្បទាយី និងអានុប្បទានិកមិនអាចធ្វើអនុប្បទានសិទ្ធិលើបំណុលបានឡើយ។[131]

### ៣.៤.៣.អានុភាពនៃការបែងចែក

ការបែងចែកមត៌ក មានអានុភាពប្រតិសកម្ម គិតចាប់ពីពេលដែលបានចាប់ផ្តើមសន្តតិកម្ម។ អានុភាពប្រតិសកម្ម គឺមានន័យថាសន្តតិជនទទួលបានបានមត៌កពីមតកជនផ្ទាល់ គឺមិនមែនបានទទួលពីសហសន្តតិជនផ្សេងទៀតទេ ទោះបីជាការបែងចែកតាមរយៈពិភាក្សា ឬដោយតុលាការក៏ដោយ គឺការទទួលបានមត៌ក បានក្នុងន័យពីមត៌កជនដោយផ្ទាល់តែម្តង អានុភាពប្រតិសកម្មធ្វើឱ្យសន្តតិជនដែលទទួលបានមត៌កអាចមានមនោសញ្ចេតនាពិសេសចំពោះមតកជន។[132] ប៉ុន្តែការបែងចែក ពុំអាចបំពានសិទ្ធិរបស់តតិយជនដែលបានចុះបញ្ជី ឬបានទទួលលក្ខខណ្ឌតតាំងបានឡើយ។[133] ការកំណត់ខាងលើជាការការពារតតិយជនដើម្បីឱ្យមានសុវត្ថិភាពជំនួញ ដូចជាករណីមត៌កស្ថិតក្នុងស្ថានភាពអវិភាគ ទៅតាមសមាមាត្រនៃចំណែករបស់សហសន្តតិជន ទោះបីជាមុនការបែងចែកមត៌កក៏ដោយ ក៏សហសន្តតិជនអាចធ្វើអនុប្បទានចំណែករបស់ខ្លួនទៅឱ្យតតិយជនបាន ឬក៏ម្ចាស់បំណុលរបស់សន្តតិជនណាម្នាក់ អាចរឹបអូសនូវចំណែកមត៌ករបស់សន្តតិជនបាន ដូច្នេះប្រសិនបើទទួលស្គាល់នូវអានុភាពប្រតិសកម្ម ដោយគ្មានលក្ខខណ្ឌ នឹងធ្វើឱ្យបាត់បង់នូវសុវត្ថិភាពក្នុងកិច្ចការជំនួញ ហេតុនេះអានុភាពប្រតិសកម្មដូចករណីខាងលើ មិនត្រូវទទួលស្គាល់ទេ ចំពោះតតិយជនដែលបានធ្វើនីតិវិធីចុះបញ្ជី ឬមានលក្ខខណ្ឌតតាំងបានឡើយ។[134]

---

[131] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៥០៣ កថាខណ្ឌទី ១។

[132] ក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយនៃក្រមរដ្ឋប្បវេណី ភាគ៦ គន្ថីទី៨,( ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ឆ្នាំ២០១០),មាត្រា ១២៧៣ (១) វាក្យខណ្ឌទី១។

[133] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៧៣ កថាខណ្ឌទី ១ ។

[134] ក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយនៃក្រមរដ្ឋប្បវេណីភាគ៦ គន្ថីទី៨,( ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ឆ្នាំ២០១០),មាត្រា ១២៧៣ (១) វាក្យខណ្ឌទី២។

សហសន្តតិជននីមួយៗ ត្រូវទទួលយកលិខិតបញ្ជាក់សិទ្ធិដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិដែលខ្លួនបានធ្វើលទ្ធកម្ម។[135] តាមលទ្ធផលនៃការបែងចែក សហសន្តតិជនដែលបានលទ្ធកម្មនូវសិទ្ធិដែលមានលិខិតប័ណ្ណបញ្ជាក់សិទ្ធិ អាចទទួលលិខិត ប័ណ្ណបញ្ជាក់សិទ្ធិបាន ឧបមាថាករណីសន្តតិជនដែលបានលទ្ធកម្មនូវសិទ្ធិលើប្រាក់បញ្ញើរបស់មតកជន អាចទទួលបានយកសៀវភៅគណនីធនាគាររបស់មតកជនទៅរក្សាទុកបាន។

[135] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៧៣ កថាខណ្ឌទី ២។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ជាទីអវសាន្តនៃប្រធានបទស្ដីពីការប្រតិបត្តិមតកសាសន៍ យើងអាចធ្វើការសន្និដ្ឋានបានថា កាលដែលមានរបបសន្តតិកម្មតាមរយៈមតកសាសន៍ វាគឺជាការល្អមួយ ដែលអាចឱ្យម្ចាស់បណ្ដាំអាចបង្ហាញឆន្ទៈរបស់ខ្លួនដោយសេរីនូវការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន ឱ្យទៅសន្តតិជនរូបណាដែលខ្លួនចង់ឱ្យ។ ការធ្វើមតកសាសន៍បានផ្ដល់ឱកាសឱ្យម្ចាស់បណ្ដាំ អាចមានពេលវេលាគ្រប់គ្រាន់ក្នុងការពិចារណាបានយ៉ាងល្អិតល្អន់ក្នុងការកំណត់ថា តើសន្តតិជនរូបណាគួរបានអ្វី តើគួរឱ្យ ឬមិនគួរឱ្យ បើឱ្យតើឱ្យប៉ុនណា មត៌កប្រភេទណាដែលគួរឱ្យ ទៅតាមការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន ឱ្យបានត្រឹមត្រូវទៅលើអ្នកដែលមានសិទ្ធិទទួលមត៌កនាអនាគត ដើម្បីបញ្ចៀសការបារម្ភនាពេលទទួលមរណភាពទៅ សន្តតិជនរបស់ខ្លួនមិនអាចទទួលបានមត៌ក។ ដើម្បីធ្វើឱ្យមតកសាសន៍មានសុពលភាពបាន ម្ចាស់បណ្ដាំត្រូវគោរពទៅតាមលក្ខខណ្ឌចាំបាច់ដែលច្បាប់បានតម្រូវ ដែលរួមមានលក្ខខណ្ឌទម្រង់ និងលក្ខខណ្ឌគ្រឹះ។ លក្ខខណ្ឌទម្រង់ ជាលក្ខខណ្ឌដែលម្ចាស់បណ្ដាំត្រូវបំពេញទៅតាមទម្រង់នៃមតកសាសន៍ដែលរួមមានមតកសាសន៍ដោយលិខិយថាភូត លិខិតឯកជន លិខិតសម្ងាត់ និងមតកសាសន៍ក្នុងស្ថានភាពពិសេស ជាអាទិ៍។ ចំពោះលក្ខខណ្ឌគ្រឹះវិញ សំដៅដល់លក្ខខណ្ឌសារជាតុដែលជាការពិចារណាពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្ដាំ។ ក្នុងខ្លឹមសារនៃបណ្ដាំក្រៅពីការបែងចែកទ្រព្យសម្បត្តិទៅឱ្យសន្តតិជន ម្ចាស់បណ្ដាំក៏អាចបង្ហាញឆន្ទៈឱ្យបុគ្គលណាម្នាក់ ជួយបំពេញបំណងណាមួយឱ្យខ្លួនបានដែរ ឱ្យតែមិនផ្ទុយពីច្បាប់។ ដូចជានៅពេលដែលខ្លួនទទួលមរណភាពទៅ ឱ្យសន្តតិជនរៀបចំទុកដាក់សពឱ្យបានត្រឹមត្រូវ និងធ្វើពិធីបុណ្យតាមបែបសាសនា ជាដើម។ ហើយសន្តតិជន ឬអ្នកកពាក់ព័ន្ធនឹងផលប្រយោជន៍ ត្រូវអនុវត្តតាមបំណងចុងក្រោយនៃខ្លឹមសារក្នុងលិខិតមតកសាសន៍នោះ ជាអាទិ៍។

នៅពេលដែលបណ្ដាំមានអានុភាព សន្តតិជន អ្នកពាក់ព័ន្ធផលប្រយោជន៍ ឬអ្នកថែរក្សាមតកសាសន៍ត្រូវយកមតកសាសន៍ទៅពិនិត្យបញ្ជាក់នៅតុលាការដោយគ្មានការយឺតយ៉ាវ លើកលែងតែមតកសាសន៍ដោយលិខិយថាភូត។ ក្នុងនីតិវិធីនៃការពិនិត្យបញ្ជាក់ តុលាការមិនធ្វើការពិនិត្យលើទម្រង់ ឬខ្លឹមសារនៃបណ្ដាំឡើយ គឺពិនិត្យតែលើស្ថានភាពខាងក្រៅរបស់បណ្ដាំតែប៉ុណ្ណោះ លើកលែងតែមានការប្ដឹងតវ៉ាពីសន្តតិជនទៅលើទម្រង់ទើបតុលាការពិនិត្យលើទម្រង់ និងខ្លឹមសាររបស់បណ្ដាំ។ ក្នុងខ្លឹមសារនៃបណ្ដាំមតកជនក៏អាចធ្វើការជ្រើសតាំងឬប្រគល់សិទ្ធិឱ្យតតិយជនជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍ក្នុងការគ្រប់គ្រងមត៌ក និងធ្វើនូវរាល់សកម្មភាពផ្សេងៗដែលចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍បាន។ ប៉ុន្តែករណីដែលបណ្ដាំមិនបានកំណត់ពីអ្នកប្រតិបត្តិមតកសាសន៍ទេ សន្តតិជន ឬអ្នកពាក់ព័ន្ធផលប្រយោជន៍អាចដាក់ពាក្យស្នើសុំឱ្យតុលាការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍បាន។ វត្តមានរបស់អ្នកប្រតិបត្តិមតកសាសន៍មានភាពមិនដាច់ខាតទេ ករណីដែលមិនមានកំណត់នៅក្នុងបណ្ដាំទេ សន្តតិជនអាចធ្វើការប្រតិបត្តិមតកសាសន៍ដោយខ្លួនរវាងសហសន្តតិជនទាំងអស់បាន ភាគច្រើន

ការប្រតិបត្តិដោយខ្លួនឯងនេះ គឺដោយសារតែទ្រព្យសម្បត្តិដែលជាមត៌កមានតិចតួច ស្ួចស្តើងពេក ហើយគ្មានភាពស្មុគស្មាញក្នុងការប្រតិបត្តិ។ ប៉ុន្តែក៏មានករណីចាំបាច់មួយចំនួនដែលត្រូវតែមានវត្តមានរបស់អ្នកប្រតិបត្តិមតកសាសន៍ដែរ ដូចជាបណ្តាំដែលមានសរសេរអំពីការទទួលស្គាល់កូនជាដើម ដែលត្រូវការដាច់ខាតនូវវត្តមានរបស់អ្នកប្រតិបត្តិមតកសាសន៍។ តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍មានច្រើនក្នុងការអនុវត្តមតកសាសន៍ទៅតាមខ្លឹមសារនៃបណ្តាំ ដូចជាការស្រាវជ្រាវមត៌ក ការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ ធ្វើសកម្មភាពគ្រប់គ្រង និងរក្សាទុកមត៌កមុនការបែងចែក ការទទួលស្គាល់កូន ជាភាគីនៃបណ្តឹងពាក់ព័ន្ធនឹងទ្រព្យដែលជាមត៌ក និងបែងចែកមត៌កទៅតាមអ្វីដែលបានកំណត់ក្នុងបណ្តាំ ជាអាទិ៍។ ការកាន់មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍ ធ្វើឱ្យមានការកម្រិតសិទ្ធិរបស់សហសន្តតិជនក្នុងការចាត់ចែងទ្រព្យដែលមានចែងក្នុងបណ្តាំ។ ប៉ុន្តែចំពោះទ្រព្យសម្បត្តិដែលជាមត៌កទាំងឡាយណាដែលមិនចែងក្នុងបណ្តាំទេ សហសន្តតិជនអាចធ្វើសកម្មភាពគ្រប់គ្រង ចាត់ចែង និងពិភាក្សាគ្នាបែងចែកបាន។

មួយវិញទៀត ករណីមួយចំនួនមតកសាសន៍មិនបានកំណត់ពីវិធីនៃការបែងចែកមត៌កនោះទេ ដែលជាហេតុនាំឱ្យសន្តតិជន អ្នកពាក់ព័ន្ធផលប្រយោជន៍ និងអ្នកប្រតិបត្តិមតកសាសន៍ពិបាកក្នុងការបែងចែក ដោយសារតែទ្រព្យសម្បត្តិដែលត្រូវបែងចែកស្ថិតក្នុងស្ថានភាពអវិភាគ។ ការណ៍នេះ សហសន្តតិជនអាចមានជម្រើសពីរ គឺធ្វើការពិភាក្សាគ្នាបែងចែកទ្រព្យសម្បត្តិដើម្បីរំលាយស្ថានភាពអវិភាគនៃមត៌ក ដោយតម្រូវឱ្យមានវត្តមានរបស់សហសន្តតិជនទាំងអស់ ប្រសិនបើនត្ថិភាព ឬអវត្តមានសន្តតិជនរូបម្នាក់ ការពិភាក្សាបែងចែកនឹងត្រូវចាត់ទុកថាមោឃភាព។ ប្រសិនបើមានការព្រមព្រៀងគ្នាក្នុងការបែងចែកហើយ សហសន្តតិជនគប្បីធ្វើកិច្ចសន្យាមួយដើម្បីកុំឱ្យមានកែប្រែដែលអាចបង្កជាជម្លោះនៅពេលក្រោយ ហើយអ្នកប្រតិបត្តិមតកសាសន៍នឹងធ្វើការបែងចែកមត៌កទៅតាមការព្រមព្រៀងនោះ ហើយតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ក៏ត្រូវបានបញ្ចប់ផងដែរ។ ផ្ទុយមកវិញ ប្រសិនបើការពិភាក្សាមិនអាចធ្វើការបែងចែកបានទេ សន្តតិជនណាម្នាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ អាចដាក់ពាក្យសុំឱ្យតុលាការឱ្យធ្វើការបែងចែកបាន។ ក្នុងការបែងចែកតុលាការនឹងពិចារណាទៅលើស្ថានភាពផ្សេងៗ ដើម្បីជៀសវាងការបែងចែកដោយមិនលំអៀង ឬមិនសុខចិត្តពីសន្តតិជនដែលអាចនាំមកនូវជម្លោះថែមទៀត។ ក្នុងការបែងចែកមត៌កតុលាការនឹងពិចារណាទៅលើ មូលដ្ឋាននៃការបែងចែក ដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី សិទ្ធិអាទិភាពរបស់សហព័ទ្ធ សំណងនៃកាតព្វកិច្ចរបស់មតកជន ទម្រង់នៃការផ្ទេរសិទ្ធិចំពោះវត្ថុជាមត៌ក ជាអាទិ៍។ ក្រៅពីកត្តាខាងលើតុលាការក៏អាចពិចារណាទៅលើទំនៀមទម្លាប់នៅក្នុងតំបន់ និងមតិលើសពីពាក់កណ្តាលរបស់សហសន្តតិជនផងដែរ ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានឆ្លងកាត់ការសិក្សាស្រាវជ្រាវប្រធានបទស្តីពី ការប្រតិបត្តិមតកសាសន៍ ឃើញថាការអនុវត្តសន្តតិកម្មតាមមតកសាសន៍ក្នុងបរិបទនៅកម្ពុជា មិនទាន់មានការអនុវត្តឱ្យបានទូលំទូលាយនៅឡើយទេ ហើយជួបនៅបញ្ហាជាច្រើនដូចជា បញ្ហាពាក់ព័ន្ធទៅនឹងការធ្វើមតកសាសន៍ បញ្ហាជម្រោងជម្រះទៅលើការប្រតិបត្តិមតសាសន៍ និងទំនៀមទម្លាប់ បញ្ហាពាក់ព័ន្ធទៅនឹងមតកសាសន៍ដែលមិនបានកំណត់ពីវិធីនៃការបែងចែក។ ការណ៍នេះ ក្រុមយើងខ្ញុំសូមលើកយកនូវដំណោះស្រាយមួយចំនួនដូចតទៅៈ

បញ្ហាពាក់ព័ន្ធនឹងការធ្វើមតកសាសន៍ៈ ប្រជាជនខ្មែរយើងមិនសូវមានការយល់ដឹងអំពីច្បាប់ ជាពិសេសបញ្ញត្តិស្តីពីសន្តតិកម្មតាមមតកសាសន៍នេះតែម្តង។ បញ្ហាដែលកើតមានឡើងជារឿយៗ គឺបញ្ហាទៅលើទម្រង់នៃមតកសាសន៍ដែលម្ចាស់បណ្តាំភាគច្រើនមិនអនុវត្តតាមទម្រង់ ដែលនាំឱ្យនៅពេលដែលបណ្តាំមានអានុភាព សន្តតិជន និងអ្នកពាក់ព័ន្ធផលប្រយោជន៍អាចប្តឹងមោឃភាពបាន។ ដូចនេះទម្រង់នៃមតកសាសន៍គប្បីធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅក្នុងសង្គម ពិសេសទៅលើលក្ខខណ្ឌនៃទម្រង់នីមួយៗ ឱ្យបានច្បាស់លាស់ និងណែនាំឱ្យបានច្បាស់លាស់ផងដែរ អំពីបញ្ហានៃការប្រើប្រាស់ស្នាមមេដៃ ដែលជាបញ្ហាចម្បងធំមួយដែលប្រជាជនមានការភាន់ច្រឡំ ដោយក្នុងទម្រង់នៃមតកសាសន៍តម្រូវឱ្យប្រើប្រាស់ហត្ថលេខា។ មួយវិញទៀត គប្បីណែនាំឱ្យប្រជាពលរដ្ឋបានយល់ដឹងអំពីគុណសម្បត្តិ និងគុណវិបត្តិរបស់ទម្រង់នីមួយៗផងដែរ ដើម្បីឱ្យពួកគាត់អាចមានលទ្ធភាពជ្រើសរើសយកទម្រង់ណាមួយដែលស័ក្តិសមទៅនឹងស្ថានភាពរបស់គាត់។

បញ្ហាពាក់ព័ន្ធនឹងការប្រតិបត្តិមតកសាសន៍ៈ ពាក់ព័ន្ធទៅលើបញ្ហានៃការអនុវត្តមតកសាសន៍ ក្នុងទំនៀមទម្លាប់ប្រពៃណីខ្មែរមិនឱ្យតម្លៃទៅលើការជីកកាយរឿងគ្រួសារអ្នកដទៃឡើយ ប៉ុន្តែបញ្ញត្តិពាក់ព័ន្ធនឹងសន្តតិកម្មតាមមតកសាសន៍បានបើកផ្លូវឱ្យអ្នកប្រតិបត្តិមតកសាសន៍ និងអ្នកជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍ដែលជាតតិយជន អាចដឹងពីបញ្ហាផ្ទៃក្នុងគ្រួសាររបស់មតកជនបាន ដែលជាបញ្ហាមួយពិបាកក្នុងការអនុវត្ត ដែលភាគច្រើនមតកជនឱ្យសន្តតិជនខ្លួនឯងជាអ្នកប្រតិបត្តិមតកសាសន៍ ហើយអាចបង្កបានជាជម្លោះផ្សេងៗ ដោយសារតែអ្នកប្រតិបត្តិមតកសាសន៍ជាសន្តតិជន ហើយខ្វះចំណេះដឹងពាក់ព័ន្ធនឹងការប្រតិបត្តិមតកសាសន៍។ ដូចនេះប្រជាពលរដ្ឋខ្មែរគួរគប្បីទទួលយកស្មារតីរបស់ច្បាប់ ដើម្បីជួយសម្រួលដល់ការប្រតិបត្តិឱ្យបានកាន់តែទូលំទូលាយ ជៀងវាងការមានវិវាទ។ មួយវិញទៀត ចំពោះម្ចាស់បណ្តាំ ឬសន្តតិជននៅពេលដែលជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍ក្រៅពីសារការី គប្បីជ្រើសរើសអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ ឬបានឆ្លងកាត់ការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការប្រតិបត្តិមតកសាសន៍ ដើម្បីអាចបំពេញការងារបានត្រឹមត្រូវ និងទាន់ពេលវេលា។ ផ្ទុយទៅវិញ ករណីដែលទំហំនៃមត៌កតិចតួចពេក ឬ

សន្តតិជនមានតែម្នាក់ឯង ម្ចាស់បណ្តាំពុំចាំបាច់កំណត់អំពីអ្នកប្រតិបត្តិមតកសាសន៍ទេ លើកលែងតែករណីដាច់ខាតមួយចំនួនតម្រូវឱ្យមានអ្នកប្រតិបត្តិមតកសាសន៍ចូលរួមជាចាំបាច់ ដូចជាការទទួលស្គាល់កូនជាដើម។

បញ្ហាពាក់ព័ន្ធនឹងមតកសាសន៍ដែលមិនបានកំណត់ពិធីនៃការបែងចែកៈ ចំពោះមតកសាសន៍ដែលមិនបានកំណត់អំពីវិធីនៃការបែងចែក ធ្វើឱ្យសហសន្តតិជន ឬអ្នកប្រតិបត្តិមតសាសន៍ មានភាពលំបាកក្នុងការបែងចែក ដោយហេតុថាមត៌កស្ថិតក្នុងស្ថានភាពអវិភាគ បើទោះបីជាធ្វើការបែងចែកតាមបណ្តាំក៏ដោយ ក៏តម្រូវឱ្យសហសន្តតិជនត្រូវធ្វើការពិភាក្សាគ្នាបែងចែកដើម្បីរំលាយស្ថានភាពអវិភាគ ហើយបើពិភាក្សាគ្នាមិនបានទៀត ត្រូវដាក់ពាក្យទៅតុលាការឱ្យធ្វើការបែងចែក ដែលហេតុធ្វើឱ្យនីតិវិធីមានភាពស្មុគស្មាញ ខាតពេលវេលា និងខូចប្រយោជន៍របស់សហសន្តតិជន។ ដើម្បីកុំឱ្យមានភាពលំបាកទៅដល់ សហសន្តតិជន ឬអ្នកប្រតិបត្តិមតកសាសន៍នៅពេលក្រោយ ម្ចាស់បណ្តាំគួរតែកំណត់អំពីវិធីបែងចែកមត៌កឱ្យរួចរាល់នូវក្នុងមតកសាសន៍ជៀសវាងកុំឱ្យមានផលលំបាកទៅថ្ងៃក្រោយ ឬផ្តល់សិទ្ធិទៅឱ្យតតិយជនក្នុងការកំណត់អំពីវិធីនៃការបែងចែក។

សរុបមក ប្រព័ន្ធច្បាប់ស្តីពីរបបសន្តតិកម្មតាមមតកសាសន៍នៅកម្ពុជា មានភាពក្មេងខ្ចីនៅឡើយ ការអនុវត្តនូវមិនទាន់មានភាពទូលំទូលាយ ហើយម្យ៉ាងទៀតការនិយមរបស់ប្រជាជនខ្មែរ ភាគច្រើនតែងធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិរបស់ខ្លួន ទៅឱ្យកូននៅពេលដែលគាត់នៅរស់ ឬក្នុងឱកាសពិសេសអ្វីមួយ ដូចជាក្នុងឱកាសនៃការរៀបអាពាហ៍ពិពាហ៍ជាដើម ដែលទាមទារឱ្យមានការចូលរួម និងផ្សព្វផ្សាយបន្ថែមពាក់ព័ន្ធនឹងបញ្ញត្តិស្តីពីសន្តតិកម្មតាមមតកសាសន៍នេះ។

# គន្ថនិទ្ទេស

# គន្ថនិទ្ទេស


## ១.វចនានុក្រមខ្មែរ

១. សម្ដេចព្រះសង្ឃរាជ ជួន ណាត.១៩៦៧."វចនានុខ្មែរ".ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ។

២. វចនានុក្រមច្បាប់ ខ្មែរ-អង់គ្លេស បោះពុម្ពលើកទី១ ឆ្នាំ២០១២។

## ២.អត្ថបទច្បាប់

១. ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

២. ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។

៣.ច្បាប់ស្ដីពីនីតិវិធីរឿងនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១០។

## ៣.អត្ថបទពិគ្រោះ

១.គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី.ឆ្នាំ២០១០.សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៣ គន្ថីទី៥. ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

២.គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី.ឆ្នាំ២០១០.សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ គន្ថីទី៨-ទី៩. ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

៣.ក្រុមការងារនៃគ្រូបណ្ដុះបណ្ដាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ.ឆ្នាំ២០១៧, សេចក្ដីពន្យល់ចំពោះក្រមរដ្ឋប្បវេណី ភាគ ៣.ភ្នំពេញ,ការកែសម្រួលលើកាបោះពុម្ពលើកទី១។

៤. មេធាវី អ៊ីវ ប៉ូលី.ឆ្នាំ២០១១.នីតិរដ្ឋប្បវេណី៖ មេរៀនសង្ខេប.ភ្នំពេញ ។

៥.ហាប់ ផល្លី. ២០១៩.វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា.ភ្នំពេញ៖ខេយ&ណាយច៍ព្រីនធីង។

៦. Jaques Flour ,Jean Jean Aubert, Eric Savaux.ឆ្នាំ២០០០. ``Les obligations, 1.l´ acte juridique´´ បោះពុម្ពលើកទី៨, Edition Armand Colin។

## ៤.ឯកសារតាមរយៈការធ្វើបទបង្ហាញ សិក្ខាសាលា និងតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ៖

១.SHINODA Yoichiro (Attorney at Law (Japan) ,សាលាដំបូងរាជធានីភ្នំពេញ បទបង្ហាញស្ដីពី សន្តតិកម្ម II។

២.សាស្ត្រាចារ្យ UMEMOTO Yumi,ការអនុវត្តជាក់ស្ដែងនៃការបែងចែកមត៌ក I,(ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់),ការវាយតម្លៃមត៌ក។

៣.លោកមេធាវី អ៊ីវ ប៉ូលី, ការបែងចែកមត៌ក,១៥ មករា ឆ្នាំ២០១៨។

៤.លោក វ៉េ ភីរក្ស,″ការប្រតិបត្តិមតកសាសន៍″ និង ″ការបែងចែកមត៌ក″ ,(វិភាគទានច្បាប់ វគ្គបណ្តុះបណ្តាលក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីជំនាន់ទី៦),ឆ្នាំសិក្សា២០២២-២០២៣។

៥.សិស្សសារការីជំនាន់ទី២៖ លោក ស៊ិន ច័ន្ទផល្គុន,តារាងសង្ខេបនីតិវិធីប្រតិបត្តិមតកសាសន៍ និង កាដម្រះមត៌កក្នុងករណីយល់ព្រមដោយកម្រិត។

**៥.គេហទំព័រ**

https://www.jica.go.jp/Resource/project/english/cambodia/025/materials/c8h0vm0000c54sbn-att/code_08_02.pdf

https://www.jica.go.jp/Resource/project/english/cambodia/025/materials/c8h0vm0000c54sbn-att/code_03_04.pdf

https://www.jica.go.jp/Resource/project/english/cambodia/025/materials/c8h0vm0000c54sbn-

**បញ្ជីឧបសម្ព័ន្ធ**

| **ល.រ** | **ឈ្មោះ** | **លេខឧបសម្ព័ន្ធ** |
|---|---|---|
| **១** | គម្រូលិខិតមតកសាសន៍ដោយលិខិតឯកជន | **ឧបសម្ព័ន្ធទី១** |
| **២** | គម្រូលិខិតមតកសាសន៍ដោយលិខិតយថាភូត | **ឧបសម្ព័ន្ធទី២** |
| **៣** | កិច្ចសន្យាប្រទានកម្ម | **ឧបសម្ព័ន្ធទី៣** |
| **៤** | គម្រូកិច្ចព្រមព្រៀងបែងចែកចំណែក សន្តតិកម្ម ឬមត៌ក | **ឧបសម្ព័ន្ធទី៤** |
| **៥** | គម្រូពាក្យសុំបែងចែកមត៌ក | **ឧបសម្ព័ន្ធទី៥** |
| **៦** | គម្រូដីកាសម្រេចបែងចែកមត៌ក | **ឧបសម្ព័ន្ធទី៦** |
| **៧** | គម្រូដីកាសម្រេចចាត់តាំងអ្នកជំនាញ | **ឧបសម្ព័ន្ធទី៧** |
| **៨** | គម្រូដីកាសម្រេចកំណត់តម្លៃ | **ឧបសម្ព័ន្ធទី៨** |
| **៩** | សាលក្រម សាលដីកាតុលាការពាក់ព័ន្ធនឹងរឿងក្តីមត៌ក | **ឧបសម្ព័ន្ធទី៩** |

# គម្រូលិខិតបណ្តាំមត៌ក

(មតកសាសន៍ដោយលិខិតឯកជន)

មាត្រា១១៧៤

## ១.អត្តសញ្ញាណរបស់ម្ចាស់បណ្តាំ ( មតកជន )

ឈ្មោះ.......................................................................................................................................

..........................................................................................................................................។

(ចំណុចនេះអាចបញ្ជាក់អំពីសមត្ថភាពរបស់បុគ្គលដែលអាចធ្វើមតកសាសន៍)

មាត្រា១១៦៨

## ២.ស្ថានភាពពេលកំពុងសរសេរមតកសាសន៍

ខ្ញុំសរសេរបណ្តាំមត៌កនេះ ក្នុងស្ថានភាពដែលខ្ញុំមានស្មារតីល្អ ដឹងច្បាស់ពីអ្វីដែលខ្ញុំ កំពុងតែចាត់ចែង ហើយអ្វីដែលខ្ញុំសរសេរនៅក្នុងបណ្តាំមត៌កនេះ ជាគោលបំណងរបស់ខ្ញុំ នៅពេលដែលខ្ញុំទទួលមរណភាព។

(ចំណុចនេះ បញ្ជាក់អំពីសមត្ថភាពរបស់ម្ចាស់បណ្តាំនៅពេលធ្វើលិខិតបណ្តាំ)

មាត្រា១១៦៩

## ៣.បុគ្គលដែលត្រូវទទួលមត៌ក

អ្នកដែលត្រូវទទួលមត៌ករបស់ខ្ញុំ គឺ កូន...........................។ (បញ្ជាក់អំពីអត្តសញ្ញាណរបស់ជនដែលទទួលមត៌ក) ។

## ៤.បញ្ជាក់អំពីទំហំនៃទ្រព្យសម្បត្តិ

ដីទី១ ដីទី២ ដីទី៣ ដីទី៤ (អត្តសញ្ញាណនៃដី) លុយ (លេខគណនី ឈ្មោះធនាគារ.....) គ្រឿងអលង្កា សិទ្ធិលើបំណុល (ថ្លៃឈ្នួល ភាគហ៊ុន.........) សរុបទាំងអស់......................បំណុល........................។

## ៥.កំណត់អំពីចំណែកមត៌ក ឬវិធីបែងចែកមត៌ក

- ដីទី១ ដែលមានកំណត់នៅក្នុងចំណុចទី៤ ប្រគល់ឱ្យ កូន A...................។
- លុយចំនួន.................កំណត់នៅក្នុងចំណុចទី៤ ប្រគល់ឱ្យកូន B ។
- ធ្វើអច្ច័យទាន នូវគ្រឿងអលង្កាដែលមានកំណត់នៅក្នុងចំណុចទី៤ ឱ្យទៅកូន C។

- ភាគហ៊ុនដែលមានកំណត់នៅក្នុងចំណុចទី៤ ប្រគល់ឱ្យកូនA ២០ ភាគរយចំនួន កូនB ២០ភាគរយ កូន C ៦០ភាគរយ។
- ដីទី២ ដែលមានកំណត់នៅក្នុងចំណុចទី៤ ប្រគល់ឱ្យកូនD ប្រសិនបើ D រៀបការ ។

(មតកសាសន៍ដែភ្ជាប់លក្ខខណ្ឌបង្គង់មាត្រា១១៩៤)

## ៦.កំណត់អ្នកប្រតិបត្តិមតកសាសន៍

មេធាវី............................ ជាអ្នកប្រតិបត្តិមតកសាសន៍ ដោយទទួលកម្រៃ.................។

## ៧.ផ្ដាច់មត៌ក

កូន E មិនទទួលបានចំណែកមត៌ករបស់ខ្ញុំទេ ពីព្រោះកូន បានប្រមាទមើលងាយខ្ញុំ ធ្វើឱ្យខ្ញុំពិបាកចិត្តគ្រប់ពេល។ (មាត្រា ១១៥២)

## 8.អច្ច័យទាន

ដីទី៣ ដែលមានកំណត់នៅក្នុងចំណុចទី៤ ខ្ញុំប្រគល់ឱ្យG ជាក្មួយរបស់ខ្ញុំ ប៉ុន្តែដីនោះ ត្រូវគ្រប់គ្រងដោយប្អូនស្រីខ្ញុំ.................រហូតដល់ ក្មួយរបស់ខ្ញុំដល់នីតិភាព។

## ៩.ចំនួន ការរក្សាទុក បើក និងប្រកាសបណ្ដាំមត៌ក

បណ្ដាំមត៌កច្បាប់ដើម ធ្វើឡើងចំនួន១ (មួយ) ច្បាប់។

បណ្ដាំមត៌កច្បាប់ដើម រក្សាទុកនៅការិយាល័យមេធាវី...............។

បណ្ដាំមត៌កនេះ អាចបើកបាន ២ខែ ក្រោយពេលខ្ញុំទទួលមរណភាព.........។

បណ្ដាំមត៌កនេះ ត្រូវប្រកាស នៅផ្ទះរបស់ខ្ញុំ...................................។

## ១០. បណ្ដាំចុងក្រោយរបស់ម្ចាស់បណ្ដាំ

ឪពុកសង្ឃឹមថាកូនចេះស្រលាញ់គ្នា មិនធ្វើបាបគ្នា មិនយកទ្រព្យជាត្រីមុខ បំភ្លេចញាតិភាព ធ្វើឱ្យគ្រួសារក្លាយជាអព្វមង្គល ក្រោយពេលឪពុកស្លាប់ទៅ..........................................................។ (មាត្រា ១១៨៧)

**ម្ចាស់បណ្ដាំ**

**ហត្ថលេខារបស់ម្ចាស់បណ្ដាំ និងចុះកាលបរិច្ឆេទ**

(មាត្រា១១៧៤)

[ **ឧបសម្ព័ន្ធទី ២** ]

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតមតកសាសន៍

### ម្ចាស់បណ្តាំ

- នាម-គោត្តនាមៈ..............................ភេទៈ.............ជនជាតិៈ....................................។
- ថ្ងៃខែឆ្នាំកំណើតៈ..............................មុខរបរៈ............................................................។
- ទីកន្លែងកំណើតៈ...............................................................................................................។
- ឪពុកឈ្មោះៈ........................................ម្ដាយឈ្មោះៈ.................................................។
- ស្ថានភាពគ្រួសារៈ............................................................................................................។
- អត្តសញ្ញាណប័ណ្ណលេខៈ....................................................................................................។
- សៀវភៅគ្រួសារលេខៈ........................................................................................................។
- ទីលំនៅបច្ចុប្បន្នៈ ផ្ទះលេខ.............ផ្លូវ.............ភូមិ........................សង្កាត់......................
  ខណ្ឌ...........................រាជធានី/ខេត្ត..................................។

### អច្ច័យលាភី ឬសន្តតិជន

- នាម-គោត្តនាមៈ..............................ភេទៈ.............ជនជាតិៈ....................................។
- ថ្ងៃខែឆ្នាំកំណើតៈ..............................មុខរបរៈ............................................................។
- ទីកន្លែងកំណើតៈ...............................................................................................................។
- ឪពុកឈ្មោះៈ........................................ម្ដាយឈ្មោះៈ.................................................។
- ស្ថានភាពគ្រួសារៈ............................................................................................................។
- អត្តសញ្ញាណប័ណ្ណលេខៈ....................................................................................................។
- សៀវភៅគ្រួសារលេខៈ........................................................................................................។
- ទីលំនៅបច្ចុប្បន្នៈ ផ្ទះលេខ.............ផ្លូវ.............ភូមិ........................សង្កាត់......................
  ខណ្ឌ...........................រាជធានី/ខេត្ត..................................។

### សាក្សីទី១

- នាម-គោត្តនាមៈ..............................ភេទៈ.............ជនជាតិៈ....................................។
- ថ្ងៃខែឆ្នាំកំណើតៈ..............................មុខរបរៈ............................................................។
- ទីកន្លែងកំណើតៈ...............................................................................................................។
- ឪពុកឈ្មោះៈ........................................ម្ដាយឈ្មោះៈ.................................................។

- ស្ថានភាពគ្រួសារ៖...........................................................................................................។
- អត្តសញ្ញាណប័ណ្ណលេខ៖.....................................................................................................។
- សៀវភៅគ្រួសារលេខ៖.........................................................................................................។
- ទីលំនៅបច្ចុប្បន្ន៖ ផ្ទះលេខ.............ផ្លូវ.............ភូមិ........................សង្កាត់......................
ខណ្ឌ..........................រាជធានី/ខេត្ត.................................។
(សាក្សីត្រូវតែជាជនដែលមិនស្ថិតក្នុងបញ្ញត្តិមាត្រា១១៧២)

**សាក្សីទី២**

- នាម-គោត្តនាម៖..............................ភេទ៖.............ជនជាតិ៖....................................។
- ថ្ងៃខែឆ្នាំកំណើត៖.............................មុខរបរ៖...........................................................។
- ទីកន្លែងកំណើត៖.............................................................................................................។
- ឪពុកឈ្មោះ៖.......................................ម្តាយឈ្មោះ៖................................................។
- ស្ថានភាពគ្រួសារ៖...........................................................................................................។
- អត្តសញ្ញាណប័ណ្ណលេខ៖.....................................................................................................។
- សៀវភៅគ្រួសារលេខ៖.........................................................................................................។
- ទីលំនៅបច្ចុប្បន្ន៖ ផ្ទះលេខ.............ផ្លូវ.............ភូមិ........................សង្កាត់......................
ខណ្ឌ..........................រាជធានី/ខេត្ត.................................។
(សាក្សីត្រូវតែជាជនដែលមិនស្ថិតក្នុងបញ្ញត្តិមាត្រា១១៧២)

**សារការីផ្តល់លិខិតយថាភូតលើលិខិតមតកសាសន៍**

ឈ្មោះ..........................ជាសារការី និងជា.........(សមាសភាព និងនាមករណ៍ស្ថាប័ន).........មានអាស័យដ្ឋាននៅផ្ទះលេខ....................ផ្លូវ.................ភូមិ...........................សង្កាត់.............................ខណ្ឌ....................... រាជធានី/ខេត្ត................................។

**I.អត្ថន័យនៃបណ្តាំ**

.................................................................................................................................................................................................................................................................................................។

**II.សេចក្តីអះអាងរបស់សាក្សី**

..............................................................................................................................................................................................................................................................................................................................................................................................................................................................................។

**III.អ្នកទទួលអច្ច័យទាន (ករណីដែលមានការចូលរួមពីសំណាក់អច្ច័យលាភី)**

..........................................................................................................................................
..........................................................................................................................................
.......................................................................................................................................។

**IV.ការរៀបចំ និងការផ្តិតមេដៃលើលិខិតមតកសាសន៍**

..........................................................................................................................................
..........................................................................................................................................
.......................................................................................................................................។

| | |
|---|---|
| ហត្ថលេខាម្ចាស់បណ្តាំ | ស្នាមមេដៃស្តាំអច្ច័យលាភី |
| .............................. | ....................................... |
| ស្នាមមេដៃស្តាំសាក្សីទី១ | ស្នាមមេដៃស្តាំសាក្សីទី២ |
| ................................ | ...................................... |

**លិខិតមតកសាសន៍នេះ ត្រូវបានពិនិត្យ និងធ្វើការបញ្ជាក់**

**ជាលិខិតយថាភូតដោយចុះបញ្ជី**

**លេខ**..........................................................

**នៅមន្ទីរសារការី**.............................................

**ក្រោមការទទួលខុសត្រូវរបស់**

**សារការី**....................................................

**មានខ្លឹមសារបញ្ជាក់ដូចតទៅ៖**

**១.សារការីបានពិនិត្យឯកសារច្បាប់ដើមរួមមាន៖**

..............................................................................................................................................

.............................................................................................................................។

**២.សារការីបានធ្វើការកត់ត្រាសម្គាល់បញ្ជាក់ឆន្ទៈរបស់ភាគីពាក់ព័ន្ធថា៖**

..............................................................................................................................................

.............................................................................................................................។

**៣.អត្ថបទច្បាប់**

..............................................................................................................................................

.............................................................................................................................។

**៤.មន្ទីរសារការី.................ទទួលលិខិតមតកសាសន៍នេះ តាមសំណើររបស់ម្ចាស់បណ្តាំតាមនីតិវិធីច្បាប់។**

លិខិតមតកសាសន៍នេះមានសុពលភាពអនុវត្ត
ចាប់ពីថ្ងៃ.............ខែ........ឆ្នាំ.......... ព.ស..............
ត្រូវនឹងថ្ងៃទី..........ខែ........ឆ្នាំ.................

(ហត្ថលេខា និងត្រា)
(ឈ្មោះសារការី)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតមរតកសាសន៍
## និងការប្រគល់សិទ្ធិឲ្យចាត់ចែងទ្រព្យបណ្តោះអាសន្ន

**ម្ចាស់បណ្តាំ និងជាអ្នកប្រគល់សិទ្ធិ**

- នាម-គោត្តនាម ៖ **ម្ចាស់បណ្តាំ** ភេទ៖ប្រុស ជនជាតិ៖ ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត ៖ ០៧-០៥-១៩៣៧ មុខរបរ៖ ៣...
- ទីកន្លែងកំណើត ៖ សង្កាត់ លេខ៥ ក្រុងភ្នំពេញ
- ឪពុកឈ្មោះ ៖ **អៀ ឡាំ** ម្តាយឈ្មោះ៖ **ឡាំ**
- ស្ថានភាពគ្រួសារ ៖ ពោះម៉ាយពីខ្មោចនាង **តាំង ស៊ីមទៀង** និងមានកូន០៧នាក់
- អត្តសញ្ញាណប័ណ្ណលេខ៖ ០១០៤២៦៨៨៣ (០១)
- សៀវភៅគ្រួសារលេខ៖០១.០២៥១៨២ ចុះថ្ងៃទី១៥-១០-២០១០
- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ១៦៩ ផ្លូវម៉ៅសេទុង ភូមិ០៥ សង្កាត់ទួលស្វាយ ព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**អ្នកទទួលអច្ច័យទាន និងជាអ្នកទទួលសិទ្ធិ**

- នាម-គោត្តនាម ៖ **សន្តតិជន** ភេទ៖ប្រុស ជនជាតិ៖ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត ៖ ០១-០៦-១៩៦២ មុខរបរ៖ពាណិជ្ជករ
- ទីកន្លែងកំណើត ៖ សង្កាត់លេខ៥ ក្រុងភ្នំពេញ
- ឪពុកឈ្មោះ ៖ **ម្ចាស់បណ្តាំ** ម្តាយឈ្មោះ៖ **តាំង ស៊ីមទៀង(ស្លាប់)**
- ស្ថានភាពគ្រួសារ ៖ ប្រពន្ធឈ្មោះ **ជាសារី** កូន៣នាក់
- កំរិតវប្បធម៌៖ ថ្នាក់ទីបញ្ចប់
- កាន់អត្តសញ្ញាណប័ណ្ណ០១០៧១៨៧២៦(០១)
- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ១៦៩ ផ្លូវម៉ៅសេទុង ភូមិ០៥ សង្កាត់ទួលស្វាយ ព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**សាក្សីទី១៖**

- នាម-គោត្តនាម ៖ **ជា ស៊ីថា** ភេទ៖ប្រុស ជនជាតិ៖ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត ៖ ០៧-១០-១៩៥២ មុខរបរ៖ ពាណិជ្ជករ
- ទីកន្លែងកំណើត ៖ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល
- ឪពុកឈ្មោះ ៖ **ជា លី** ម្តាយឈ្មោះ ៖ **ឌូរ**
- ស្ថានភាពគ្រួសារ ៖ ពោះម៉ាយ កំរិតវប្បធម៌៖ ថ្នាក់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ៖ ០១០១៤៨០៤៨(០១)

- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ២២៦អឺ០ ផ្លូវ៣៥៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**សាក្សីទី២៖**

- នាម-គោត្តនាម ៖ **លាង ស្រីទូច** ភេទ៖ស្រី ជនជាតិ៖ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត ៖ ១០/០៣/១៩៨១ មុខរបរ៖ពាណិជ្ជករ
- ទីកន្លែងកំណើត ៖ សង្កាត់លេខ៥ ក្រុងភ្នំពេញ
- ឪពុកឈ្មោះ ៖ **លាង វ៉ាន់ថុន** ម្តាយឈ្មោះ ៖ **ឈឿង យ៉ុង**
- ស្ថានភាពគ្រួសារ ៖ មានគ្រួសារ កំរិតវប្បធម៌ ៖ បរិញ្ញាប័ត្រ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ៖ ០១០៦៧៥២០៣(០១)
- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ២២៨ ផ្លូវលេខ៣៥៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

សាក្សីបានអះអាងថាមិនមែនជាញាតិលោហិតខ្សែផ្ទាល់របស់ម្ចាស់បណ្តាំ ។

**សារការីផ្តល់យថាភូតលើលិខិតមតកសាសន៍**

បណ្ឌិត ( **ជាសារការី** និងជា**ប្រធានមន្ទីរសារការី (** មានអាសយដ្ឋាននៅ ផ្ទះលេខ ១៣៥ CD ផ្លូវ១៩៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទការិយាល័យ ( អ៊ីម៉ែល៖

**I-អត្ថន័យនៃបណ្តាំ និងការប្រគល់សិទ្ធិ**

ម្ចាស់បណ្តាំ និងជាអ្នកប្រគល់សិទ្ធិឲ្យគ្រប់គ្រងចាត់ចែងបណ្តោះអាសន្នរួមទាំងបំណុល និងពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរបស់ខ្លួន បានប្រកាសជាឱឡារិកជម្រាបជូន **សារការី** នូវទ្រព្យសម្បត្តិដែល ជាកម្មវត្ថុនៃបណ្តាំ និងការប្រគល់សិទ្ធិរបស់ខ្លួនរួមមាន៖

**ទ្រព្យសម្បត្តិផ្ទាល់ខ្លួន**

១ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ** ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ទទួលស្គាល់ដោយម.រ.ជ.ន.ស **រាជធានីភ្នំពេញ**

២ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ** ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ទទួលស្គាល់ដោយម.រ.ជ.ន.ស **រាជធានីភ្នំពេញ**

៣ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ** ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ទទួលស្គាល់ដោយម.រ.ជ.ន.ស **រាជធានីភ្នំពេញ**

៤ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ** ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ទទួលស្គាល់ដោយម.រ.ជ.ន.ស **រាជធានីភ្នំពេញ**

៥ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយ**ម.រ.ជ.ន.ស រាជធានីភ្នំពេញ**

៦ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយ**ម.រ.ជ.ន.ស រាជធានីភ្នំពេញ**

៧ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយ**ម.រ.ជ.ន.ស រាជធានីភ្នំពេញ**

៨ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយ**ម.រ.ជ.ន.ស រាជធានីភ្នំពេញ**

៩ - **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយ**ម.រ.ជ.ន.ស រាជធានីភ្នំពេញ**

១០- **វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ**

ទទួលស្គាល់ដោយ**ម.រ.ជ.ន.ស រាជធានីភ្នំពេញ**

១១- ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ

ដោយ**ម.រ.ជ.ន.ស ខេត្តស្វាយរៀង**

១២- ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ

ទទួលស្គាល់ដោយ**ម.រ.ជ.ន.ស ខេត្តកណ្តាល**

១៣- លិខិតផ្ទេរសិទ្ធិកាន់កាប់ដី/ផ្ទះ របស់ឈ្មោះ ចុះ

ទទួលស្គាល់ដោយ

១៤- លិខិតផ្ទេរសិទ្ធិកាន់កាប់ដី/ផ្ទះ របស់ឈ្មោះ ចុះ

ទទួលស្គាល់ដោយ

១៥- លិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ របស់ឈ្មោះ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

១៦- លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ របស់ឈ្មោះ

ចុះថ្ងៃទី ទទួលស្គាល់ដោយ

ទ្រព្យសម្បត្តិសហកម្មសិទ្ធិ

១ - ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

២ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

៣ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

៤ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

៥ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

៦ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

៧ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

៨ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

៩ - វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

១០- វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី

ទទួលស្គាល់ដោយ

**ទ្រព្យសម្បត្តិជាក្រុមហ៊ុន**

**អាជីវកម្ម ក្រុមហ៊ុន**

ម្ចាស់បណ្តាំ បានបង្ហាញឆន្ទៈជាចុងក្រោយនៅចំពោះមុខសារការីមានខ្លឹមសារ ច្បាស់លាស់ថា"ម្ចាស់បណ្តាំបានសម្រេចចិត្តធ្វើអច្ច័យទាននូវទ្រព្យសម្បត្តិជាកម្មសិទ្ធិ និងសហកម្មសិទ្ធិរបស់ខ្លួនដែលមានទំហំ ទីតាំង និងមានឯកសារសម្គាល់ដូចបានបញ្ជាក់ខាងលើនេះ ឲ្យទៅអ្នកទទួលអច្ច័យទានដូចមានអត្តសញ្ញាណខាងលើ ធ្វើជាម្ចាស់កម្មសិទ្ធិ កាន់កាប់ទ្រព្យរបស់ខ្លួនបន្តបន្ទាប់ពីម្ចាស់បណ្តាំទទួលមរណភាព ។ ដោយឡែកចំពោះស្ថានភាពបច្ចុប្បន្នម្ចាស់បណ្តាំស្ថិតនៅក្នុងស្ថានភាពសុខភាពពុំល្អ ហេតុនេះបានសម្រេចចិត្តប្រគល់សិទ្ធិឲ្យអ្នកទទួលអច្ច័យទាន មានសិទ្ធិគ្រប់គ្រងលើអាជីវកម្មក្រុមហ៊ុន ដោះស្រាយបំណុលរបស់ក្រុមហ៊ុន និងចាត់ចែងលើទ្រព្យសម្បត្តិដើម្បីឲ្យក្រុមហ៊ុនដំណើរការបានល្អ ។ ក្រៅពីនេះម្ចាស់បណ្តាំបានអះអាងថាខ្លួនមានកូនចំនួន៧នាក់ ដែលតាមច្បាប់មានសិទ្ធិទទួលមរតកពីខ្លួន ក៏ប៉ុន្តែខ្លួនបានសម្រេចិត្តមិនធ្វើការបែងចែកបណ្តាំតាមច្បាប់ទេ គឺបែងចែកបណ្តាំតាមឆន្ទៈរបស់ខ្លួនដោយមានមូលហេតុថា កូន នាក់ផ្សេងទៀតមិនព្រមមកជួយការងាររបស់ម្ចាស់បណ្តាំនៅក្នុងប្រទេសកម្ពុជា ហើយរាល់ការងាររបស់ខ្លួនមានតែអ្នកទទួលអច្ច័យទានម្នាក់នេះប៉ុណ្ណោះ ដែលបានបំពេញការងារ ជួយដល់ម្ចាស់បណ្តាំ លើគ្រប់កិច្ចការទាំងអស់ ។





ការអនុវត្តលិខិតមតកសាសន៍នេះ នឹងត្រូវធ្វើឡើងដោយ **មន្ទីរសារការី** តាមនីតិវិធីច្បាប់ ដើម្បីឲ្យអច្ច័យទានទាំងអស់តាមម្ចាស់បណ្តាំទៅអ្នកទទួលអច្ច័យទាន ដោយពេញលេញ និងស្របតាមច្បាប់ ។

ម្ចាស់បណ្តាំបានយល់ព្រមផ្តិតមេដៃលើលិខិតមតកសាសន៍នេះ មុកជាភស្តុតាងតាមច្បាប់ នៅចំពោះមុខសារការី ។

**II-សេចក្តីអះអាងរបស់សាក្សី**

សាក្សីទាំងពីររូបមានអត្តសញ្ញាណដូចខាងលើ ដែលបានយល់ព្រមធ្វើជាសាក្សីក្នុងលិខិតមតកសាសន៍ បានអះអាងដោយប្រាកដថា សាក្សីមិនមានជាប់ពាក់ព័ន្ធជាញាតិលោហិតខ្សែផ្ទាល់ជាមួយនឹងម្ចាស់បណ្តាំឡើយ ហើយយល់ព្រមផ្តល់ចម្លើយជាសាក្សីជូនសមត្ថកិច្ចពាក់ព័ន្ធនៅពេលដែលអនុវត្តខ្លឹមសារ នៃលិខិតមតកសាសន៍នេះថាម្ចាស់បណ្តាំពិតជាបានធ្វើបណ្តាំដោយស្ម័គ្រចិត្ត ដោយមានសមត្ថភាពពេញបរិបូរណ៍ ដោយមានសាក្សីដែលជារូបខ្លួនបានចូលរួមដឹងឮដោយផ្ទាល់ប្រាកដមែន។

**III-អ្នកទទួលអច្ច័យទាន**

អ្នកទទួលអច្ច័យទានដែលត្រូវជាកូនបង្កើតជាមួយម្ចាស់បណ្តាំ បានចូលរួម ការធ្វើបណ្តាំនេះ នៅចំពោះមុខសារការី ហើយក៏បានយល់ព្រមផ្តិតមេដៃ នឹងទទួលយកនូវអច្ច័យទានជាអចលនទ្រព្យខាងលើ រួមទាំងទទួលសិទ្ធិដោះស្រាយ និងចាត់ចែងអាជីវកម្មក្រុមហ៊ុន និងដោះស្រាយបញ្ហាបំណុល រួមទាំងការចាត់ចែងលើទ្រព្យជាបណ្តោះអាសន្នក្នុងពេលបច្ចុប្បន្នតាមខ្លឹមសារ នៃលិខិតមតកសាសន៍នេះដោយពេញចិត្តពីម្ចាស់បណ្តាំ ។

**IV-ការរៀបចំ និងការផ្តិតមេដៃលើលិខិតមតកសាសន៍**

លិខិតមតកសាសន៍នេះ ត្រូវបានរៀបចំឡើងដោយ**មន្ទីរសារការី** ក្រោមការទទួលខុសត្រូវរបស់ លោក ជាសារការី អមដោយលោក ជាលេខាធិការកត់ត្រា និងវាយអក្សរ នៃបណ្តាំនេះ ។ លិខិតនេះ មានចំនួន ០៣ច្បាប់ ជាច្បាប់ដើម ធ្វើឡើងជាភាសាខ្មែរ និងត្រូវបានផ្តល់ជូនម្ចាស់បណ្តាំ ចំនួន ០១ច្បាប់ អ្នកទទួលអច្ច័យទានចំនួន ០១ច្បាប់ និងរក្សាទុកនៅ មន្ទីរសារការី លុច ស៊ីអេចឌី ចំនួន ០១ច្បាប់ សម្រាប់ប្រើប្រាស់តាមច្បាប់តទៅ ។

លិខិតមតកសាសន៍នេះ បន្ទាប់ពីរៀបចំ និងកែសម្រួលខ្លឹមសារច្បាស់លាស់រួច សារការីបានអានឲ្យម្ចាស់បណ្តាំ អ្នកទទួលអច្ច័យទាន និងសាក្សី ស្តាប់ និងអ្នកទាំង អស់គ្នាបានឆ្លើយតបមកវិញ នៅចំពោះមុខសារការីថា ខ្លឹមសារនៃលិខិតមតកសាសន៍ នេះពិតជាត្រឹមត្រូវតាមឆន្ទៈរបស់ខ្លួនទាំងស្រុង ហើយយល់ព្រមផ្តិតមេដៃលើលិខិតមតកសាសន៍នេះ នៅចំពោះមុខសារការី និងបានសរសេរឈ្មោះរបស់ខ្លួន រៀងខ្លួនៗ នៅលើលិខិតមតកសាសន៍នេះ ដោយសារការីបានចុះថ្ងៃខែឆ្នាំចំណាំតទៅ ។

**ស្នាមមេដៃស្ដាំអ្នកធ្វើបណ្ដាំ** **ស្នាមមេដៃស្ដាំអ្នកទទួលអច្ច័យទាន**

**ឈ្មោះ ម្ចាស់បណ្ដាំ** **អច្ច័យលាភី**

ស្នាមមេដៃស្ដាំសាក្សីទី ១ ស្នាមមេដៃស្ដាំសាក្សីទី២

លិខិតមរតកសាសន៍នេះ ត្រូវបានពិនិត្យ និងធ្វើការបញ្ជាក់
ជាលិខិតយថាភូតដោយចុះបញ្ជី

**លេខ**

**នៅមន្ទីរសារការី**

ក្រោមការទទួលខុសត្រូវរបស់

**សារការី**

មានខ្លឹមសារបញ្ជាក់ដូចតទៅ ៖

១. សារការីបានពិនិត្យឯកសារច្បាប់ដើមរួមមាន៖

- អត្តសញ្ញាណប័ណ្ណឈ្មោះ ម្ចាស់បណ្ដាំ
- អត្តសញ្ញាណប័ណ្ណឈ្មោះ អច្ច័យលាភី
- អត្តសញ្ញាណប័ណ្ណឈ្មោះ សាក្សីទី១
- អត្តសញ្ញាណប័ណ្ណឈ្មោះ សាក្សីទី២
- សៀវភៅស្នាក់នៅរបស់ឈ្មោះ ម្ចាស់បណ្ដាំ
  ប័ណ្ណកម្មសិទ្ធិជាកម្មវត្ថុ នៃមរតកសាសន៍នេះ

២. សារការីធ្វើការកត់សម្គាល់បញ្ជាក់ឆន្ទៈរបស់ភាគីពាក់ព័ន្ធថា៖

ម្ចាស់បណ្ដាំឈ្មោះ ម្ចាស់បណ្ដាំ និងអ្នកទទួលអច្ច័យទានឈ្មោះ អច្ច័យលាភី រួមទាំងសាក្សីទាំងពីរនាក់ពិតជាបានយល់ព្រមដោយស្ម័គ្រចិត្តផ្ដិតមេដៃលើលិខិតមរតកសាសន៍នេះ ទុកជាចំណាំតាមច្បាប់ តាមឆន្ទៈរៀងខ្លួន នៅចំពោះ មុខសារការី។

៣. **អត្ថបទច្បាប់**

សារការីបានបង្កើតលិខិតមរតកសាសន៍នេះ ដោយផ្អែកតាមមាត្រា ១១៦៩ មាត្រា ១១៧០ មាត្រា ១១៧១ មាត្រា១១៧២ មាត្រា ១១៧៣ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

៤. **មន្ទីរសារការី** ទទួលអនុវត្តលិខិតមតកសាសន៍នេះ តាមសំណើរបស់ ម្ចាស់បណ្តាំ និងរបស់អ្នកទទួលអច្ច័យទាន តាមនីតិវិធី និងច្បាប់ ។

៥. ការបង្កើតលិខិតមរតកសាសន៍នេះ អនុឡោមតាមអនុក្រឹត្យលេខ (**អនុក្រឹត ទទួលស្គាល់មន្ទីសារក** របស់រាជរដ្ឋាភិបាលកម្ពុជា ។

លិខិតមតកសាសន៍នេះមានសុពលភាពអនុវត្ត

ចាប់ពីថ្ងៃ ខែ ឆ្នាំ សំរឹទ្ធិស័ក ព.ស ២៥៦២

ត្រូវនឹងថ្ងៃទី ខែ ឆ្នាំ

**មន្ទីសារការី** (នាមករណ៍)

**សារការី**

(ហត្ថលេខា និងត្រា)

(ឈ្មោះ សារការី)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចសន្យា ប្រទានកម្ម

*កិច្ចសន្យាប្រទានកម្មនេះ (" ជាកិច្ចព្រមព្រៀង ") ដែលត្រូវបានធ្វើឡើង និងមានប្រសិទ្ធភាព*
*ចាប់ពី ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១០ នេះតទៅ*

***រវាង***

ខាងខ្ញុំឈ្មោះ ..... ភេទ ស្រី អត្តសញ្ញាណប័ណ្ណលេខ ០១០៣២០៦៦៤ ថ្ងៃខែឆ្នាំកំណើត ០៥.០៦.១៩២៧ ទីលំនៅ បច្ចុប្បន្ន ផ្ទះលេខ ៤១២៣ ភូមិ ទួលគោក សង្កាត់ ទួលសង្កែ ខ័ណ្ឌ ឬស្សីកែវ រាជធានីភ្នំពេញ ជាអ្នកធ្វើអំណោយ ឬ ទាយក ។

***និង***

ឈ្មោះ ..... ភេទ ស្រី អត្តសញ្ញាណប័ណ្ណលេខ ០១០៣២០៤៨៣ ថ្ងៃខែឆ្នាំកំណើត ១០.០៣.១៩៧៤ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ៤១២៣ ភូមិ ទួលគោក សង្កាត់ ទួលសង្កែ ខ័ណ្ឌ ឬស្សីកែវ រាជធានីភ្នំពេញ ជាអ្នកទទួលអំណោយ ឬ បដិគ្គាហក ។

### បុព្វកថា

ដោយឆ្លងកាត់ការពិចារណាយ៉ាងល្អិតល្អន់ ក្នុងខណៈដែលខាងខ្ញុំមានស្មារតីពេញលេញល្អត្រឹមត្រូវតាមធម្មតា និងគ្មានការបង្ខិតបង្ខំពីអ្នកណាម្នាក់ឡើយ និងនៅចំពោះមុខមេធាវី និងអាជ្ញាធរដែនដីជាសាក្សី ។

### ប្រការ ១: ការពិពណ៌នាអំពី ដីនិងផ្ទះ ដែលធ្វើប្រទានកម្ម

ដីធ្លីនិងផ្ទះដែលជាកម្មវត្ថុក្នុងប្រទានកម្មនេះ មានចំនួន០១ (មួយ) ល្វែង ស្ថិតនៅដីឡូតលេខ ៤១២៣ ផ្លូវ លំ ក្រុម ៧ ភូមិទួលគោក សង្កាត់ សង្កាត់ទួលសង្កែ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ មានទំហំដីសរុបចំនួន ២៤៦,៦៦ ម៉ែត្រការ៉េ (ពីររយសែសិបប្រាំមួយក្បៀសហុកសិបប្រាំមួយម៉ែត្រការ៉េ) ដែលមានលិខិតបញ្ជាក់ប្រវត្តិដីលេខ០១៧ / ១០ ល.ប និងមានព្រំប្រទល់ដូចខាងក្រោម:

- ខាងជើងទល់នឹង : របងថ្មរបស់លឹម សំអុន
- ខាងកើតទល់នឹង : របងថ្មរបស់លឹម សំអុន
- ខាងត្បូងទល់នឹង : ផ្លូវបេតុងទទឹង៤ម៉ែត្រ
- ខាងលិចទល់នឹង : ផ្លូវបេតុងទទឹង៦ម៉ែត្រ

### ប្រការ ២: ការព្រមព្រៀងធ្វើប្រទានកម្ម

ខាងខ្ញុំឈ្មោះ ..... (ជាអ្នកធ្វើអំណោយ ឬ ទាយក) សូមធ្វើប្រទានកម្មទ្រព្យសម្បត្តិរបស់ខាងខ្ញុំ ដែលមានដីនិងផ្ទះដូចរៀបរាប់ខាងលើនេះទាំងស្រុង ទៅឱ្យឈ្មោះ ...... (អ្នកទទួលអំណោយ ឬ បដិគ្គាហក) ភេទ ស្រី កាន់អត្តសញ្ញាណប័ណ្ណលេខ ០១០៣២០៤៨៣ ថ្ងៃខែឆ្នាំកំណើត ១០.០៣.១៩៧៤ ដើម្បីគ្រប់គ្រង ប្រើប្រាស់ អាស្រ័យផល និងចាត់ចែងជាកម្មសិទ្ធិ ។

**ប្រការ ៤: ការអនុវត្តនៃប្រទានកម្ម**

កិច្ចសន្យា ការព្រមព្រៀងនេះ និងខព្រមព្រៀងនានានៃកិច្ចសន្យានេះ ត្រូវអនុវត្តដោយផ្សារភ្ជាប់ទៅនឹងផលប្រយោជន៍របស់គូភាគី ទាយាទរបស់ពួកគេ អ្នកតំណាង អ្នកទទួលសិទ្ធិ និងអ្នកដែលបានចាត់តាំង ។

**ប្រការ ៥: ការអានឱ្យស្តាប់ ការយល់លើអត្ថន័យនិងខ្លឹមសារ និងសក្ខីភាព**

កិច្ចសន្យានេះបានអានឱ្យស្តាប់ចំនួន០៣ចប់ ដោយឈ្មោះ ...................................... ភេទ .......... អាយុ .........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ ............... មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ........ ភូមិ ........ សង្កាត់ ................ខណ្ឌ ........ .... រាជធានីភ្នំពេញ ហើយភាគីទាំងពីរបានស្តាប់ និងយល់យ៉ាងច្បាស់នូវអត្ថន័យខ្លឹមសារលើកិច្ចសន្យានេះ ហើយយល់ព្រមធ្វើតាម ដោយបានផ្តិតមេដៃ ដើម្បីទុកជាភស្តុតាងតាមផ្លូវច្បាប់ ។

កិច្ចសន្យាប្រទានកម្មនេះធ្វើឡើងជា ០៤ ច្បាប់ដើម គូភាគីរក្សាទុកម្នាក់០១ច្បាប់ មេភូមិរក្សាទុក០១ច្បាប់ និង០១ច្បាប់ទៀត រក្សាទុកនៅការិយាល័យមេធាវី ដែលកិច្ចសន្យានេះ មានអត្ថន័យ និងខ្លឹមសារតែមួយដូចគ្នា ។

ភ្នំពេញ, ថ្ងៃទី..... ខែ...... ឆ្នាំ ២០០..

**អ្នកធ្វើអំណោយ ឬ នាយក** **អ្នកទទួលអំណោយ ឬ បដិគ្គាហក**

**សាក្សីទី១** **សាក្សីទី២**

**អ្នកអានអោយស្តាប់**

**បានឃើញ និងបញ្ជាក់ថា :**
ស្នាមមេដៃទាំងអស់ខាងលើនេះពិតជាបានផ្តិត
ផ្តិតចំពោះមុខពិតប្រាកដមែន ។
ធ្វើនៅ, ថ្ងៃទី..... ខែ....... ឆ្នាំ.........
**មេភូមិទួលគោក**

**ធ្វើចំពោះមុខមេធាវី**
**ហត្ថលេខា និង ត្រា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀងបែងចែកចំណែក សន្តតិកម្ម ឬមត៌ក

**យោង:** សំបុត្រមរណៈភាពឪពុកឈ្មោះ ...... លេខ៣៥ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៦

សំបុត្រមរណៈភាពរបស់ម្តាយឈ្មោះ ...... លេខ៤៨ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥

**យើងខ្ញុំជាសហសន្តតិជន (លំដាប់ទី១) ដែលមានរាយឈ្មោះដូចខាងក្រោមនេះ :**

**១- ឈ្មោះ** ...... ភេទស្រី ថ្ងៃខែឆ្នាំកំណើត ១៧.០៥.១៩៥៧ កាន់អត្តសញ្ញាណប័ណ្ណលេខ ...... ទីលំនៅអចិន្ត្រៃយ៍ ផ្ទះលេខ ...... ភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**២- ឈ្មោះ** ...... ភេទស្រី ថ្ងៃខែឆ្នាំកំណើត ១២.០៣.១៩៦៦ កាន់អត្តសញ្ញាណប័ណ្ណលេខ ...... ទីលំនៅអចិន្ត្រៃយ៍ ផ្ទះលេខ ...... ភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**៣- ឈ្មោះ** ...... ភេទស្រី ថ្ងៃខែឆ្នាំកំណើត ០៨.០៥.១៩៦៩ កាន់អត្តសញ្ញាណប័ណ្ណលេខ ...... ទីលំនៅអចិន្ត្រៃយ៍ ផ្ទះលេខ ...... ភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**៤- ឈ្មោះ** ...... ភេទស្រី ថ្ងៃខែឆ្នាំកំណើត ២៨.០៨.១៩៧២ កាន់អត្តសញ្ញាណប័ណ្ណលេខ ...... ទីលំនៅអចិន្ត្រៃយ៍ ផ្ទះលេខ ...... ភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**៥- ឈ្មោះ** ...... ភេទស្រី ថ្ងៃខែឆ្នាំកំណើត ១៥.០៨.១៩៧២ កាន់អត្តសញ្ញាណប័ណ្ណលេខ ...... ទីលំនៅអចិន្ត្រៃយ៍ ផ្ទះលេខ ...... ភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**៦- ឈ្មោះ** ...... ភេទស្រី ថ្ងៃខែឆ្នាំកំណើត ០៥.០៧.១៩៧៥ កាន់អត្តសញ្ញាណប័ណ្ណលេខ ...... ទីលំនៅអចិន្ត្រៃយ៍ ផ្ទះលេខ ...... ភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

ជាកូនរបស់មតកជន ឈ្មោះ ...... ជាឪពុក បានស្លាប់នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៦ និង មតកជន ឈ្មោះ ...... ជាម្តាយ បានស្លាប់នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៥ សុំធ្វើការបែកចែក និងយល់ព្រមទទួលយកចំណែកនៃសន្តតិកម្ម ឬមត៌ក របស់មតកជនទាំងពីរនាក់ខាងលើដូចខាងក្រោម។

### ការពិពណ៌នាអំពីសន្តតិកម្ម ឬមត៌ក

សន្តតិកម្មដែលធ្វើការបែកចែក និងទទួលយកនោះគឺជាដីមួយកន្លែងស្ថិតនៅភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៥-១១៣០ ក្បាលដីលេខ ១១៣០ មានទំហំ ៦២៤ ម៉ែត្រការ៉េ។

### ប្រការ ១: ការព្រមព្រៀងបែងចែក និងទទួលយកសន្តតិកម្ម ឬមត៌ក

យើងខ្ញុំទាំងអស់ជាសហសន្តតិជនដែលមានរាយនាមដូចខាងលើ បានព្រមព្រៀងធ្វើការបែកចែក និងយល់ព្រមទទួលយកចំណែកសន្តតិកម្ម និងផលប្រយោជន៍ដែលបានមកពីសន្តតិកម្ម ដូចបានរៀបរាប់ខាងលើនេះ ដោយបែងចែកជា៦(ប្រាំមួយ)ចំណែកស្មើៗគ្នា ទោះសន្តតិកម្មនោះគិតជាប្រាក់ក្តី ឬគិតជាទំហំដីក្តី។

### ប្រការ ២: សិទ្ធិ និង ភារកិច្ចលើសម្បត្តិកម្ម ឬមតិក

សហសម្បត្តិជនដែលមានរាយនាមដូចខាងលើ ត្រូវមានសិទ្ធិ និងភារកិច្ច ទាក់ទង ពាក់ព័ន្ធទៅនឹងសម្បត្តិកម្មខាងលើដូចៗគ្នា។ ក្នុងករណី មានការសំរេចចាត់ចែងណាមួយ ដែលពាក់ព័ន្ធទៅនឹងសម្បត្តិកម្មខាងលើនេះ ការសំរេចនោះត្រូវអនុម័តយកតាមមតិភាគច្រើននៃសហសម្បត្តិជនជាដាច់ខាត។

### ប្រការ ៣: សោហ៊ុយចំណាយលើសម្បត្តិកម្ម ឬមតិក

សហសម្បត្តិជន ដែលមានរាយនាមដូចខាងលើ ត្រូវទទួលខុសត្រូវលើសោហ៊ុយចំណាយផ្សេងៗដែលពាក់ព័ន្ធ ទៅនឹងសម្បត្តិកម្មខាងលើដូចៗគ្នា។ ក្នុងករណីដែលសម្បត្តិជនម្នាក់បានចំណាយក្នុងការថែរក្សាសម្បត្តិកម្ម ឬត្រូវឱ្យចំណាយជាចាំបាច់ណាមួយ ការចំណាយនោះត្រូវធ្វើការទូទាត់ ឬកាត់កងសងវិញនៅពេលដែលសម្បត្តិកម្មនោះត្រូវបានលក់។

### ប្រការ ៤: ការអនុភាពនៃការបែងចែកសម្បត្តិកម្ម ឬមតិក

កិច្ចព្រមព្រៀងនេះ និងខព្រមព្រៀងនានានៃកិច្ចព្រមព្រៀងនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃផ្តិតមេដៃលើកិច្ចព្រមព្រៀងនេះ និងត្រូវអនុវត្តដោយផ្សាភ្ជាប់ទៅនឹងផលប្រយោជន៍របស់សហសម្បត្តិជន និងទាយាទរបស់ពួកគេ។ -

### ប្រការ ៥: ការយល់លើអត្ថន័យខ្លឹមសារ និងសត្យាភាព

សហសម្បត្តិជនទាំងអស់បានស្តាប់ និងយល់យ៉ាងច្បាស់នូវអត្ថន័យខ្លឹមសារលើកិច្ចព្រមព្រៀងនេះ ហើយយល់ព្រមធ្វើតាម ដោយបានផ្តិតមេដៃ ដើម្បីទុកជាភស្តុតាងតាមផ្លូវច្បាប់។

កិច្ចព្រមព្រៀងនេះធ្វើឡើងជា ០៧ ច្បាប់ដើម សម្បត្តិជនរក្សាទុកម្នាក់០១ច្បាប់ និង០១ច្បាប់ទៀត រក្សាទុកនៅការិយាល័យ លោក មេធាវី ......។

យើងខ្ញុំសូមផ្តិតមេដៃទុកជាភស្តុតាង ព្រមទាំងមានសាក្សីដឹងឮផង។

ភ្នំពេញថ្ងៃទី០២ ខែមិនា ឆ្នាំ២០១២

**ស្នាមមេដៃសហសម្បត្តិជន**

........................ ........................ ........................

........................ ........................ ........................

**ធ្វើនៅចំពោះមុខមេធាវី**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**គម្រូពាក្យសុំសម្រាប់ករណីសិក្សាទី១**

## ពាក្យស្នើសុំឲ្យបែងចែកមត៌ក

**អ្នកដាក់ពាក្យសុំ** ៖ ឈ្មោះ **A** អាយុ ៤០ ឆ្នាំ មុខរបរពាណិជ្ជករ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ០២ ផ្លូវលេខ ១៧៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** "អ្នកដាក់ពាក្យសុំ[1]" ៖ ខ្ញុំ **P** ជាមេធាវីនៃក្រុមហ៊ុនមេធាវី.................. ដែលមានអាសយដ្ឋានស្ថិតនៅ...............មហាវិថី............... សង្កាត់.............. ខណ្ឌ......... រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ ............។

ទីកន្លែងបញ្ជូន ៖ ក្រុមហ៊ុនមេធាវី.................[2]

**ភាគីម្ខាងទៀតនៃពាក្យសុំ** ៖ ឈ្មោះ **B** អាយុ ៤២ ឆ្នាំ មុខរបរពាណិជ្ជករ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ៣៥ ផ្លូវលេខ៦៦ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

### សូមគោរពចូលមក

### ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ[3]

**ក**-ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ

១.អ្នកដាក់ពាក្យសុំធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ ស្ដីពីមតិកដែលបានភ្ជាប់ជាមួយនេះ។

---

[1] មានករណីមួយចំនួនដែលការពិភាក្សាលក្ខណៈសារធាតុរវាងសហសន្តតិជនបានធ្វើឡើងរួចរាល់ ប៉ុន្តែ ចំណុចនេះបង្ហាញតែអំពីឧទាហរណ៍ដែលមេធាវីបានដាក់ពាក្យសុំក្នុងនាមជាអ្នកតំណាងដោយអាណត្តិឲ្យសន្តតិជនតែម្នាក់គត់ក្នុងចំណោមសហសន្តតិជន។ ប្រសិនបើមេធាវីបានដាក់ពាក្យសុំក្នុងនាមតំណាងឲ្យសន្តតិជនច្រើននាក់ក្នុងចំណោមសហសន្តតិជន (រួមបញ្ចូលទាំងករណីដែលធ្វើការតំណាងឲ្យសន្តតិជនទាំងអស់ផងដែរ) នឹងធ្វើឲ្យមានការព្រួយបារម្ភណ៍អំពីភាពផ្ទុយគ្នានៃផលប្រយោជន៍ ហេតុនេះមេធាវីចាំបាច់ត្រូវតែពន្យល់ឲ្យបានច្បាស់លាស់អំពីចំនុចនេះទៅកាន់អតិថិជន និងត្រូវទទួលការយល់ព្រមពីអតិថិជនផងដែរ។ យ៉ាងណាមិញ គេគិតថា វិធីដែលសន្តតិជនណាម្នាក់ក្នុងចំណោមសហសន្តតិជនតំណាងឲ្យសហសន្តតិជនផ្សេងទៀត ហើយបានដាក់ពាក្យសុំ នឹងធ្វើឲ្យមានការព្រួយបារម្ភថាខ្វះការធានាចំពោះនីតិវិធីសម្រាប់សហសន្តតិជនផ្សេងទៀត ហើយពួកគេនឹងមិនពេញចិត្ត។

[2]មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការដាក់ពីទីកន្លែងដែលត្រូវបញ្ជូន មិនមែនជាកាតព្វកិច្ចនោះទេ។ ទោះបីជាមិនដាក់ពីកន្លែងដែលត្រូវបញ្ជូនក៏ដោយ ក៏ជាទូទៅគឺត្រូវធ្វើការបញ្ជូនទៅការិយាល័យមេធាវីនៃបណ្ដឹង។ ប៉ុន្តែ ដើម្បីឲ្យមានភាពច្បាស់លាស់ពីទីកន្លែងដែលត្រូវបញ្ជូន វាជាការល្អដែលដាក់ពីទីកន្លែងដែលត្រូវបញ្ជូន។ ជាពិសេស ក្នុងករណីដែលមានមេធាវីច្រើនធ្វើជាអ្នកតំណាងរបស់ដើមចោទ នោះដើម្បីឲ្យមានភាពច្បាស់លាស់ក្នុងការបញ្ជូនទៅការិយាល័យមេធាវីណាមួយ នោះត្រូវដាក់ពីទីកន្លែងដែលត្រូវបញ្ជូន។

[3]តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការនៃទីកន្លែងចាប់ផ្ដើមសន្តតិកម្ម (តារាងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង)។ ហើយទីកន្លែងចាប់ផ្ដើមសន្តតិកម្ម គឺជាអាសយដ្ឋាននៅពេលមរណភាពរបស់មតកជន (ក្រមរដ្ឋប្បវេណីមាត្រា១១៩៦)។

២.ភាគីម្ខាងទៀត......ធ្វើលទ្ធកម្មនូវប្រាក់បញ្ញើដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ២ ស្តីពីមតិក និងសាច់ប្រាក់ដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ៣ស្តីពីមតិក ដែលបានភ្ជាប់ជាមួយនេះ ។

**ខ.អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

១.មតកជន...... បានទទួលមរណភាពនៅថ្ងៃទី......ខែ......ឆ្នាំ...... ហើយមតិកដែលដឹងច្បាស់នាពេលបច្ចុប្បន្ន មានដូចទៅនឹងការសរសេរនៅក្នុងបញ្ជីសារពើភ័ណ្ឌស្តីពីមតិកដែលបានភ្ជាប់ជាមួយនេះ (តទៅនេះហៅថា "មតិកនៃរឿងក្តីនេះ")។

២.នៅពេលទទួលមរណភាព មតកជន.............មានប្រពន្ធ..............ហើយរវាងមតកជន និងប្រពន្ធ.......នោះ មានកូន...........១នាក់។ មតកជនមិនមានកូនផ្សេងទៀតទេ។ មតកជន......មិនបានបន្សល់ទុកមតកសាសន៍ឡើយ[4]។

៣.សន្តតិជនរបស់មតកជនដែលជាអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត បានពិភាក្សាគ្នាអំពីការបែងចែកមតិកនៃរឿងក្តីនេះ។ ជាលទ្ធផលនៃការពិភាក្សា ភាគីម្ខាងទៀតមានផ្ទះដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនរួចទៅហើយ ប៉ុន្តែ ដោយសារតែគាត់មានអាយុច្រើន និង មិនមានប្រាក់ចំណូល ដូច្នេះ គាត់ត្រូវការចាំបាច់នូវសាច់ប្រាក់និង ប្រាក់បញ្ញើក្នុងធនាគារ សម្រាប់ជីវភាពរបស់គាត់ក្នុងពេលខាងមុខ។ ចំណែកឯអ្នកដាក់ពាក្យសុំវិញ គឺជាបុគ្គលិកក្រុមហ៊ុនដែលមានប្រាក់ចំណូល ប៉ុន្តែ គាត់មិនទាន់មានផ្ទះដែលជាកម្មសិទ្ធិផ្ទាល់ខ្លួននៅឡើយទេ ដូច្នេះហើយ អ្នកដាក់ពាក្យសុំ ត្រូវធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ស្តីពីមតិកដែលបានភ្ជាប់ជាមួយនេះ ហើយភាគីម្ខាងទៀតត្រូវធ្វើលទ្ធកម្មនូវសាច់ប្រាក់ និងប្រាក់បញ្ញើក្នុងធនាគារដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ ២ និង ៣ ស្តីពីមតិកដែលបានភ្ជាប់ជាមួយនេះ។ បន្ថែមពីនេះទៀត តម្លៃទីផ្សារនៃអចលនវត្ថុ ដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ ស្តីពីមតិកដែលបានភ្ជាប់ជាមួយនេះ គឺប្រហែល......ដុល្លារ ហើយ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃនៃការបូកសរុបប្រាក់បញ្ញើនៅក្នុងធនាគារ និងសាច់ប្រាក់សុទ្ធដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ ២ និង ៣ ស្តីពីមតិកដែលបានភ្ជាប់ជាមួយនេះ។ ដូចនេះ នៅថ្ងៃទី......ខែ.......ឆ្នាំ២០១៧ ភាគីទាំង២ បានបង្កើត[5]នូវការព្រមព្រៀងដូចមាននៅក្នុងការសរសេរនៃចំណុចទី១ ខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ។

៤.អាស្រ័យហេតុនេះ អ្នកដាក់ពាក្យសុំសូមឲ្យតុលាការចេញដីកាសម្រេចតាមការសរសេរនៅក្នុងចំណុចទី១ ខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ ចំពោះពាក្យសុំនៃរឿងក្តីនេះ។

[4] បើសិនជាមានមតកសាសន៍ ករណីនេះនឹងក្លាយជាសន្តតិកម្មអនុវត្តតាមមតកសាសន៍ (សន្តតិកម្មតាមមតកសាសន៍)(ក្រមរដ្ឋប្បវេណី មាត្រា ១១៩៥ និង ចាប់ពីមាត្រា ១១៦៨)។

[5] ដើម្បីឲ្យតុលាការចេញដីកាសម្រេចទៅតាមខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ តើរវាងសហសន្តតិជនបានបង្កើតនូវការព្រមព្រៀងពិតប្រាកដដែរឬទេ? (តើសហសន្តតិជនទាំងអស់បានយល់ព្រមតាមការបែងចែកដូចនៅក្នុងខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញដែរឬទេ?)គឺជាចំណុចសំខាន់។ ដូច្នេះហើយ ត្រង់ចំណុចនេះ គួរតែមានការពន្យល់អំពីមូលហេតុលម្អិត ថាតើហេតុអ្វីបានជាបែងចែកតាមវិធីបែបនេះ?

**គ.ភស្តុតាងជាឯកសារ**[6]

១.សំបុត្រមរណភាពរបស់មតកជន

២.សំបុត្រកំណើតរបស់អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត

៣.ច្បាប់ចម្លងនៃសៀវភៅគ្រួសារ

៤.ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ

៥.លិខិតបញ្ជាក់ប្រាក់ដែលនៅសល់ក្នុងគណនីប្រាក់បញ្ញើ

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាត ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៨

**អ្នកតំណាងដោយអាណត្តិ**

P

**ឯកសារភ្ជាប់**

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

៣-លិខិតបញ្ជាក់អះអាងអំពីតម្លៃដី "ចំនួន ០២ ច្បាប់"

[6] ចំពោះឯកសារបញ្ជាក់ដំបូង ចាំបាច់ត្រូវតែដាក់ឯកសារដែលចាំបាច់ និងគ្រប់គ្រាន់ទៅតុលាការ ដើម្បីឲ្យតុលាការទទួលស្គាល់នូវខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ប៉ុន្តែដំណើរការនៃការព្រមព្រៀងទាក់ទងនឹងវិធីបែងចែកមតិកជាដើម អំពីចំណុចដែលមិនមានឯកសារត្រឹមត្រូវ នឹងក្លាយជាការពន្យល់នៅក្នុងការសួរជំនួសនៅតុលាការ (ច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងមាត្រា ២៨ កថាខណ្ឌទី២) ។

## បញ្ជីសារពើភ័ណ្ឌស្តីពីមតិក[7]

១.អចលនវត្ថុ[8]

ទីតាំងស្ថិតនៅ ៖ ភូមិ...... សង្កាត់ ផ្សារកណ្តាល ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ

លេខវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ៖

លេខក្បាលដី ៖

កម្មសិទ្ធិករ ៖ ឈ្មោះ និង អាសយដ្ឋាន

អាគារដែលជាសមាសភាពនៃដីខាងលើ

២.ប្រាក់បញ្ញើក្នុងធនាគារ[9]

ធនាគារ ៖ ប្រទេសកម្ពុជា ធនាគារពាណិជ្ជទី១

សាខា ៖ សាខាតាមដងមហាវិថីព្រះមុន្នីវង្ស

លេខគណនីធនាគារ ៖

ឈ្មោះម្ចាស់គណនី ៖

៣.សាច់ប្រាក់ ៖ (អ្នកថែរក្សាគ្រប់គ្រង)[10]

ប្រាក់......រៀល

---

[7] បញ្ជីសារពើភ័ណ្ឌនៃមតិក ត្រូវសរសេរខ្លឹមសារដែលអាចឲ្យតុលាការយកមកប្រើប្រាស់ក្នុងដីកាសម្រេចបានតែម្តង។

[8] អចលនវត្ថុ ចាំបាច់ត្រូវធ្វើនូវបញ្ជីសារពើភ័ណ្ឌដែលមានទម្រង់ ឬ ខ្លឹមសារដែលអាចយកទៅធ្វើការចុះបញ្ជីបាន។

[9] ប្រាក់បញ្ញើក្នុងធនាគារ ចាំបាច់ត្រូវកំណត់ឲ្យបានច្បាស់លាស់អំពីខ្លឹមសារនៃប្រាក់បញ្ញើ ដើម្បីអាចតតាំងដោយភាពត្រឹមត្រូវជាមួយនឹងធនាគារ (ក្រមរដ្ឋប្បវេណី១២៧៥ កថាខណ្ឌទី១)។

[10] សាច់ប្រាក់ភាគច្រើនត្រូវកំណត់ដោយដាក់ឈ្មោះរបស់អ្នកថែរក្សាគ្រប់គ្រង ដោយសារតែវាមានភាពពិបាកក្នុងការកំណត់។

[ **ឧបសម្ព័ន្ធទី ៦** ]

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

__គម្រូដីកាសម្រេចសម្រាប់ករណីសិក្សាទី១__

សាលាដំបូងរាជធានីភ្នំពេញ

## __ដីកាសម្រេចបែងចែកម៌ក__

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងរដ្ឋប្បវេណីដែល
មិនមែនជាបណ្តឹងលេខ១៥៩ ចុះ
ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០១៧
ដីកាសម្រេចលេខ ១២៣ "ង"
ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨

-បានឃើញច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី ១៦-០៧-២០១៤

-បានឃើញមាត្រា **២៦**នៃច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

-បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃ**ទី១៥ ខែមករា ឆ្នាំ២០១៨** និងបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃ**ទី០៧ ខែធ្នូ ឆ្នាំ២០១៧** ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

លោក J ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោកស្រី C ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

## អង្គហេតុ និងការអះអាងរបស់ភាគី

### ក.ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារឲ្យតុលាការចេញ

១. អ្នកដាក់ពាក្យសុំ A ធ្វើលទ្ធកម្មចំណែកអវិភាគ ១ភាគ២នៃអចលនវត្ថុដូចក្នុងបញ្ជីសារពើភ័ណ្ឌ១ និង រថយន្តដូចក្នុងបញ្ជីសារពើភ័ណ្ឌ៣។

២. ភាគីម្ខាងទៀតនៃពាក្យសុំ B ធ្វើលទ្ធកម្មប្រាក់ក្នុងគណនីដូចក្នុងបញ្ជីសារពើភ័ណ្ឌ២។

ទី៣ បង្គាប់ឲ្យអ្នកដាក់ពាក្យសុំ A បង់ប្រាក់ចំនួន 35,000$ ដែលជាប្រាក់សម្រួលនៃលទ្ធកម្មមត៌កខាងលើឲ្យទៅភាគីម្ខាងទៀតនៃពាក្យសុំ B។

### ខ. អង្គហេតុ

#### ខ.១ ការសង្ខេបរឿងក្តី

កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤

#### ខ.២. ការអះអាងរបស់ភាគី

**-ការអះអាងរបស់អ្នកដាក់ពាក្យសុំ A**

អ្នកដាក់ពាក្យសុំបាន

**-ការអះអាងរបស់ភាគីម្ខាងទៀតនៃពាក្យសុំ B**

ភាគីម្ខាងទៀតនៃពាក្យសុំបានអះអាងថា

**សំអាងហេតុ**

**ក. ស្តីពីចំណុចទាមទារទី១**

**ក.១. អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់**

-ករណីរឿងក្តីនេះ

-

**ក.២. ការវិនិច្ឆ័យអំពីចំណុចទាមទារ**

-ករណីនេះ

-

**ខ. ស្តីពីចំណុចទាមទារទី២**

**ខ.១. អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់**

-ករណីនេះ

-

**ខ.២.ការវិនិច្ឆ័យអំពីចំណុចទាមទារ**

-ករណីនេះ

-

**គ. ស្តីពីចំណុចទាមទារទី៣**

**គ.១. អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់**

២ (ពីរ) សប្តាហ៍មុន

**គ.២.ការវិនិច្ឆ័យអំពីចំណុចទាមទារ**

សាក្សី B បានអះអាងថា

**ឃ.សេចក្តីសន្និដ្ឋាន**

-

-

ជាសរុប តុលាការនឹងសម្រេចរឿងក្តីនេះ ដូចខាងក្រោម ៖

**សេចក្តីសម្រេចបញ្ចប់**

១.អ្នកដាក់ពាក្យសុំធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ស្តីពីមត៌ក ដែលបានភ្ជាប់ជាមួយនេះ។

២.ភាគីម្ខាងទៀត......ធ្វើលទ្ធកម្មនូវប្រាក់បញ្ញើដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ២ស្តីពីមត៌ក និងសាច់ប្រាក់ដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ៣ស្តីពីមត៌ក ដែលបានភ្ជាប់ជាមួយនេះ ។

ដីកាសម្រេចនេះប្រកាសជាសាធារណៈនៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៨ ចំពោះមុខភាគី និងអ្នកតំណាងដោយអាណត្តិរបស់ភាគី។ ទុកសិទ្ធិឲ្យភាគីប្តឹងជំទាស់ក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតដីកាសម្រេចនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៨

**ចៅក្រម**

[ **ឧបសម្ព័ន្ធទី ៧** ]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងក្រុងភ្នំពេញ
លេខ:
........................

# ដីកាសម្រេចចាត់តាំងអ្នកជំនាញ

យើង.................................... ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរះ នៃសាលាដំបូងក្រុងភ្នំពេញ។

បានឃើញមាត្រា ១៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជ ក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ.................. ចុះថ្ងៃទី......... ខែ.............ឆ្នាំ............ របស់សាលាដំបូងក្រុងភ្នំពេញ

រវាងដើមចោទឈ្មោះ......................ភេទ........... អាយុ........ឆ្នាំ របរកស៊ី................................ មានទីលំនៅសព្វថ្ងៃផ្ទះលេខ........... ផ្លូវលេខ....... ក្រុម........ភូមិ................... ឃុំ, សង្កាត់.................... ស្រុក, ខណ្ឌ.................... ខេត្ត, ក្រុង..................... ប្តី, ប្រពន្ធឈ្មោះ................. មានកូន..........នាក់។

និងចុងចំលើយឈ្មោះ.....................ភេទ........... អាយុ........ឆ្នាំ របរកស៊ី................................ មានទីលំនៅសព្វថ្ងៃផ្ទះលេខ........... ផ្លូវលេខ....... ក្រុម........ភូមិ................... ឃុំ, សង្កាត់.................... ស្រុក, ខណ្ឌ.................... ខេត្ត, ក្រុង..................... ប្តី, ប្រពន្ធឈ្មោះ................. មានកូន..........នាក់។

ដែលមានកម្មវត្ថុបណ្តឹង:........................................................................................................
.......................................................................................................................

## សំអាងហេតុ

-.......................................................................................................................

-.......................................................................................................................

-.......................................................................................................................

## ហេតុដូច្នេះសម្រេច

ចាត់តាំងឈ្មោះ................................ ភេទ............. អាយុ............ឆ្នាំ របរកស៊ី ................................ មានទីលំនៅផ្ទះលេខ............ ផ្លូវ........................ ក្រុម.......... ភូមិ...............ឃុំ-សង្កាត់...................... ស្រុក-ខណ្ឌ........................ ខេត្ត-ក្រុង.................... ជាអ្នកជំនាញខាងកោសលវិច័យលើ ........................................
.......................................................................................................................

ធ្វើនៅក្រុងភ្នំពេញ, ថ្ងៃទី.......... ខែ............ឆ្នាំ............

**ចៅក្រម, ក្រុមប្រឹក្សាជំនុំជំរះ**

[ **ឧបសម្ព័ន្ធទី ៨** ]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងក្រុងភ្នំពេញ
លេខៈ
........................

**ដីកាសម្រេចកំណត់តំលៃ**

យើង...................................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរៈ នៃសាលាដំបូងក្រុងភ្នំពេញ។

បានឃើញមាត្រា៤៣០, មាត្រា៤៣១, មាត្រា៤៣២ និងមាត្រា៤៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជា ណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ.................. ចុះថ្ងៃទី......... ខែ.............ឆ្នាំ........... របស់សាលា ដំបូងក្រុងភ្នំពេញ។

បានឃើញសាលក្រមលេខ........................... ចុះថ្ងៃទី........ ខែ................. ឆ្នាំ............

បានឃើញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំលេខ............. ចុះថ្ងៃទី...... ខែ........ ឆ្នាំ.......

បានឃើញដីកាសម្រេចរឹបអូសលេខ............... ចុះថ្ងៃទី......... ខែ................ ឆ្នាំ..............

បានឃើញដីកាសម្រេចជ្រើសតាំងអ្នកវាយតំលៃលេខ............ ចុះថ្ងៃទី....... ខែ....... ឆ្នាំ...........

**សំអាងហេតុ**

-......................................................................................................................
-......................................................................................................................
-......................................................................................................................

**ហេតុដូច្នេះសម្រេច**

១-បង្គាប់ឱ្យលក់ក:-............................................................ តំលៃ...................................
ខ-............................................................ តំលៃ...................................
គ-............................................................ តំលៃ...................................

២-បង្គាប់ឱ្យផ្លាស់ប្តូរតំលៃលក់:
ក-............................................................ តំលៃ...................................
ខ-............................................................ តំលៃ...................................
គ-............................................................ តំលៃ...................................

៣-បង្គាប់ឱ្យលក់សរុបនូវ:
ក-............................................................ តំលៃ...................................
ខ-............................................................ តំលៃ...................................
គ-............................................................ តំលៃ...................................

ធ្វើនៅក្រុងភ្នំពេញ, ថ្ងៃទី.......... ខែ............ឆ្នាំ............

**ចៅក្រម, ក្រុមប្រឹក្សាជំនុំជំរៈ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ១៦៧
ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០០២
**សាលដីកា**
លេខៈ ២៧៩
ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០០៣

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅៈ
១.ឯកឧត្តម .......... ជាប្រធាន
២.លោក .......... ជាចៅក្រម
៣.លោក .............. ជាចៅក្រម
៤.លោក .............. ជាចៅក្រម
៥.លោក .............. ជាចៅក្រម

**ក្រឡាបញ្ជី**
-លោក ....................

**តំណាងមហាអយ្យការ**
-លោក ............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៧៧ (យ) ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៨៩ ចុះថ្ងៃទី០៩ខែឧសភា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ៈ

-រវាងដើមចោទឈ្មោះ១. ថជ(ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៦៨ឆ្នាំ ជាតិខ្មែរ

២. ថធ(ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ របរកស៊ីធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិព្រៃចក ឃុំគោគគង់ខាងលិច ស្រុកកញ្ជ្រោច ខេត្តព្រៃវែង ។ (ផ្ទេរសិទ្ធិឱ្យថ ជ )។

-និងចុងចម្លើយឈ្មោះ ថធ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៧ឆ្នាំ ជាតិខ្មែរ របរកស៊ីលក់ដូរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៦២Eoz ផ្លូវ១៥៤ ក្រុមទី២៤ សង្កាត់ផ្សារថ្មីទី៣ ខ័ណ្ឌ ដូនពេញ ក្រុងភ្នំពេញ ។

- មេធាវីលោក កចរ

*កម្មវត្ថុបណ្តឹង* ប្តឹងទាមទារដីកេរ្តិ៍មរតក

បានឃើញបណ្តឹងសាទុក្ខលេខ ២២ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២ របស់ឈ្មោះ ថធ ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៧៧"យ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៦៧ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០២ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៦ខែតុលា ឆ្នាំ២០០០ របស់ដើមចោទបានប្តឹងទាមទារចែកដីមួយ កន្លែង និង ដី ស្រែស្ថិតនៅភូមិព្រៃចក ឃុំគោគគង់ខាងលិច ស្រុកកញ្ច្រៀច ខេត្តព្រៃវែង ជាទ្រព្យ របស់ម្តាយឈ្មោះ ខ ណ ដែល បានបន្សល់ទុកដីពីរកន្លែងនេះ ក្រោយពីគាត់ស្លាប់ទៅ ពុំទាន់បាន ចែក ឬលក់ឱ្យទៅកូនណាទេ ដោយសុំចែកជា៦ ចំណែកស្មើគ្នា ដោយមានឈ្មោះថជមួយចំណែក ដែរ ។ កន្លងមកឈ្មោះថជ មិនព្រមចែក គឺរំលោភយកតែម្នាក់ឯង ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១១២ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ របស់តុលាការ ខេត្តព្រៃវែងដែល មានខ្លឹមសារនៃសេចក្តីសម្រេច ដូចតទៅ:

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះថង ធ ឈ្មោះថ ដ ឈ្មោះថ ណ និង ឈ្មោះ ថ គ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០០ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិ ច្បាប់ លើកលែងតែការប្តឹងរបស់ឈ្មោះថ ផ ត្រូវបដិសេធចោលជាអសារបង់តាមមាត្រា១៧២ នៃច្បាប់ភូមិបាលដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១០០ក្រ ចុះថ្ងៃទី១៣ខែតុលា ឆ្នាំ១៩៩២។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០០របស់ដើមចោទឈ្មោះ ថ ណ និងឈ្មោះ ថ គ ឲ្យទៅឈ្មោះ ថ ធ និង ឈ្មោះថ ដ តែបដិសេធមិនទទួល ស្គាល់ការប្រគល់សិទ្ធិរបស់ឈ្មោះថ ផ ។

៣-បដិសេធលិខិតពាក្យបណ្តឹមគេក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៦ ចោលជាអសារបង់ចាប់ពីពេលនេះទៅ

៤-ទទួលស្គាល់តាមច្បាប់ដីភូមិចាស់តាមគំនូសប្លង់ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០០និងដីផលិតកម្មកសិកម្ម តាមគំនូសប្លង់ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០០ តាមលិខិតសំណើលេខ ១២៧-២០០០ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០០ ជាទ្រព្យរបស់ខ្មោចលោកយាយ ខ ណ ចាប់ពីពេលនេះទៅ ។

៥-បដិសេធពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩០ដូចគ្នា ចំនួន២ច្បាប់ របស់ចុង ចម្លើយ ឈ្មោះដ ធ ចោលជាអសារបង់ចាប់ពីពេលនេះតទៅ ។

៦-បង្គាប់ឲ្យបែងចែកទ្រព្យរបស់ខ្មោច ខ ណ មានដីភូមិចាស់តាមទំហំនៅក្នុងគំនូសប្លង់ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០០ និងដីផលិតកម្មកសិកម្មតាមទំហំនៅក្នុងគំនូសប្លង់ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០០ទៅអោយឈ្មោះ ថ ធ ឈ្មោះថ ដ ឈ្មោះថ គ ឈ្មោះថ ណ និង ឈ្មោះថជ ជា៥ចំណែកស្មើគ្នានៅពេលសាលក្រមចូលជា ស្ថាពរ ។

៧-បង្គាប់ឲ្យចុងចម្លើយឈ្មោះថជ បង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តីនិងពហ្នឹងចំនួន១.៨០០រង្វាន់ ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះចំនួ ៥.០០០រៀល បូករួម៧.០០០រៀល ។ ប្រាក់នេះ បានកាត់យកពីប្រាក់៧.០០០រៀល ដែលដើមចោទ បានបង់ទុករួចហើយ កាលបើហួសការប្តឹងឧទ្ធរណ៍បង្គាប់ឲ្យ

ឈ្មោះថធ សងប្រាក់ចំនួន៧.០០០៛ ទៅដើមចោទវិញ។ និងឲ្យចុងចម្លើយ បង់ពន្ធសមាមាត្រលើតំលៃដីមួយភាគរយដែលត្រូវប្រគល់ ឲ្យទៅដើមចោទទាំងអស់ ។ ប្រាក់នេះបង់ចូលថវិការដ្ឋ៨០ភាគរយ និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០ភាគរយ ។

៨.សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខភូតាគីទាំងសងខាងសម្រេច បើកផ្លូវឧទ្ធរណ៍រយៈពេល៦០ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រមនេះទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៣ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ របស់ឈ្មោះ ថធ ប្តឹងសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១២ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ របស់តុលាការខេត្ត ព្រៃវែង ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦២"យ" ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:

១.ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះថធ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ទុកជា ត្រឹមត្រូវតាមទម្រង់ ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២.តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១២ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ របស់ តុលាការខេត្តព្រៃវែង ទុកជាបានការតទៅ ។

៣.កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀលដែលដើមបណ្តឹង ឧទ្ធរណ៍បានបង់ទុករួច គឺពន្ធចុះបញ្ជីក្តី ពន្ធហ្នឹង២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ចំណាយក្នុងកិច្ចប្រគល់ដីកាកោន ៥.០០០រៀល និងចំណាយលើអាជ្ញាធរតុលាការ៥.០០០រៀលសរុប ១៣០០០៛

៤.សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខចុងបណ្តឹងឧទ្ធរណ៍ កំបាំងមុខដើមបណ្តឹងឧទ្ធរណ៍ បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ៦៥ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ របស់ឈ្មោះ ថធ ប្តឹងទាស់នឹងសាលដីកាលេខ ៦២ "យ" ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧៧"យ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:

១.ទទួលបណ្តឹងទាស់របស់ឈ្មោះថធ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ទុកជា ត្រឹមត្រូវតាមចំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២.ដំកល់សាលដីកាកំបាំងមុខលេខ៦២·យ· ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០១ របស់ សាលាឧទ្ធរណ៍ ទុកជាបានការ ។

៣.សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងទាស់បើកផ្លូវសាទុក្ខក្នុងកំណត់

ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២២ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២᠁២ របស់ឈ្មោះ ប៊ឹង ធិនប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៧៧-យ- ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០២ របស់ឈ្មោះថធ ។

បានឃើញសារណាតប ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះថង ជ ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា: សូមក្រុមប្រឹក្សាជំនុំជំរះសំរេច តាមច្បាប់ ។

បានស្តាប់ចម្លើយរបស់លោកថធ ( ជាម្ចាស់បណ្តឹងសាទុក្ខ )អាយុ៤៧ឆ្នាំ នៅពេលជំនុំជំរះ

ថា: បានជាខ្លួនប្តឹងសាទុក្ខពីសាលដីការបស់សាលាឧទ្ធរណ៍ មកពីសាលាឧទ្ធរណ៍កាត់ក្តីមិនយុត្តិធម៌ ។

នៅឆ្នាំ១៩៧៩ រដ្ឋបានបែងចែករបបតាមគ្រួសាររៀងៗខ្លួន ខ្លួនរស់នៅជាមួយឪពុកហើយកន្លងមកបងៗបានរុកគួនយកផ្ទះលក់អស់ម្តងហើយ ។ ខ្លួនបានយកម្តាយមកនៅជាមួយ រហូតដល់ស្លាប់ក៏បងៗមិនរវល់មកជួយធ្វើបុណ្យដែរ។ ឆ្នាំ១៩៩០រដ្ឋបានចេញលិខិតកាន់កាប់ដីធ្លីមកឱ្យខ្លួន ។ ខ្លួនសុំធ្វើសំណូមពរសុំកាន់កាប់ដីធ្លីដែលខ្លួនធ្លាប់កាន់កាប់តាំងពីឆ្នាំ១៩៧៩មក គាត់មកបង្ខាំងដីខ្លួន៣ឆ្នាំចោលឥតបានធ្វើអ្វីទេ។ ខ្លួនដឹងក្តីពេលណាគឺខ្លួនរស់នៅជាមួយឪពុកម្តាយរហូត ព្រោះខ្លួនជាកូនពៅ។

ឪពុកខ្លួនបានប្រគល់ផ្ទះឱ្យមកខ្លួន តែបងៗរុកគួនលក់ចែកគ្នាអស់ និង ដោយខ្លាចកូន១ឈ្មោះគ្នាម្តាយ

ខ្លួនក៏បានធ្វើបណ្តាំមរតកចែកមកឱ្យខ្លួន ។ ឆ្នាំ១៩៧៩ ក្រោយរបបប៉ុលពត បងៗមិនមកនៅជាមួយទេ គាត់នៅដោយឡែក ។

បានស្តាប់ចម្លើយរបស់ឈ្មោះប៊ិង ធាង នៅពេលជំនុំជំរះនថា ខ្លួនគឺបងគេបង្អស់ គឺមិនបំបាត់កេរ្តិ៍ទេ ខ្លួនជបងនិយាយថាត្រូវតែចែកគ្នា ព្រោះកេរ្តិ៍នេះ មិនមែនឪពុកម្តាយខ្លួនទុកតែចែកឱ្យថង ធ ទេ ។ ខ្លួនសុំចែកតែដីស្រែ និងភូមិចាស់ប៉ុណ្ណោះ កេរ្តិ៍ដែលចែកហើយខ្លួនមិននិយាយទេ។ ស្រាប់តែគេយកដីនេះប្រគល់ឲ្យជន្លងគេ គ្រាន់តែខ្លួនបេះផ្លែឈើហូបបន្តិចបន្តួចជន្លងគេដេរខ្លួន និងដឹកក្របីកាត់ក៏មិនបានដែរ ។ មេឃុំត្រូវគេសួរនៅសាលាឧទ្ធរណ៍ ថា បណ្តាំមរតក ផ្តិតមេដៃនឹងចង្កៀងប្រេងកាត ។ ចំពោះបញ្ហាដី គឺស្រុកខ្លួនគេមិនវាស់ចែកគ្នាទេ គឺ ដីកេរ្តិ៍អ្នកណាអ្នកហ្នឹងទទួលម្ចាស់ដីយករៀងៗខ្លួន ម្តាយខ្លួនជួលដីនេះឱ្យគេធ្វើស្រែ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកកចរជាមេធាវីការពារចុងចម្លើយ នាពេលសវនាការថា: ដីនេះជាដីកេរ្តិ៍មរតកពីសង្គមចាស់ ថ ធ និង ម្តាយរស់នៅជាមួយគ្នាលើដីនេះតែម្តង ហើយ ថធ ក៏មានកូនដែរ ហេតុអ្វីបានជាយកដីយាយ ណ និង ថធ មកចែកគ្នា ។ ចំណែកបងៗសុទ្ធតែមានដីដែលរដ្ឋបានចែកឱ្យហើយ ។ ឆ្នាំ១៩៩០ ថធ បានដាក់ពាក្យសុំកាន់កាប់ដីហើយមេឃុំ ខ ហ បានទទួលស្គាល់ ពេលនោះក៏គ្មានអ្នកណាប្តឹងដែរ ដល់ឆ្នាំ២០០០ ទើបប្តឹង ។

សូមឯកឧត្តមប្រធានមេត្តាពិនិត្យពិចារណា និង កាត់ក្តីឱ្យ ថធ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និង សេចក្តីសន្និដ្ឋានមេធាវីការពារចុងចម្លើយ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២២ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២ របស់ឈ្មោះថជ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះនបានតាមមាត្រា១៤នៃ ច្បាប់ស្តីពីការរៀបចំ និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍បែងចែកដីទំនាស់ជា៥ចំណែកស្មើគ្នានោះ ដោយ សំអាងហេតុថា ជាមរតករបស់សពយាយ ខ ណ នោះពុំមានលក្ខណៈត្រឹមត្រូវឡើយ ព្រោះថា ពុំទាន់មានភស្តុតាងណាបញ្ជាក់ច្បាស់លាស់ថា ដីទំនាស់នោះជាកម្មសិទ្ធិផ្តាច់មុខរបស់សពលោកយាយ ខ ណ តែម្នាក់ឯងនោះទេ ។

-ក្រោយឆ្នាំ១៩៧៩ លោកយាយ ខ ណ នឹង កូនឈ្មោះថជ បានចូលមក កាន់កាប់ដីទំនាស់រហូតដល់សព្វថ្ងៃ ហើយឈ្មោះថជ មានពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លីពីកន្លែងចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩០ ទៀតផង ។

-យល់ឃើញថា សាលដីកាលេខ៧៧"យ" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ដែលបានសម្រេច សេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទម្រង់ និងគតិច្បាប់ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី ចំពោះមុខគូភាគី

១. ទទួលបណ្តឹងសាទុក្ខលេខ២២ ចុះថ្ងៃទី១៥ ខែមករាឆ្នាំ២០០០ របស់ឈ្មោះថជ ទុកជាត្រឹមត្រូវទាំងទម្រង់ ទាំងគតិច្បាប់ ។

២.ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៧៧"យ" ចុះថ្ងៃទី២៦ ខែវិច្ឆិកាឆ្នាំ២០០១របស់ សាលាឧទ្ធរណ៍ទាំងមូល ។

៣. បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១៦៧ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០២របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះនជាថ្មីឡើងវិញ ។

៤.របឹអូសប្រាក់ប្រដាប់ក្តីដែលឈ្មោះថ ជ បានបង់នៅតុលាការកំពូលចំនួន១៩០០០៛ គឺ

– ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០០៛ សម្រាប់ ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

៥.សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ ។

ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខៈ ១២៤

ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៤

**នាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

<u>សាលដីកា</u>

លេខ : ២៥៤

ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤

ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

២-លោក ជាចៅក្រម

៣-លោក ជាចៅក្រម

៤-លោក ជាចៅក្រម

៥-លោក ជាចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

លោក

តំណាងមហាអយ្យការ

លោក ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៤៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ ឆ ចា (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ ៣២ ក្រុមទី១១៧ មណ្ឌល៨ ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះជ ហ "រ" ម្តាយឈ្មោះ ស គ ហ "រ" ប្តីឈ្មោះ ទ ថ ។

មានមេធាវីលោក ស ច ឧ ជាតំណាង ។

ចុងចម្លើយឈ្មោះ ខ យ (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៧៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ ៣២ ក្រុមទី១១៧ មណ្ឌល៨ ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

ផ្ទេរសិទ្ធិឱ្យលោក ខ ស ថ ។

មានមេធាវីលោក ផ ព ស ។

**កម្មវត្ថុបណ្ដឹង** : ប្ដឹងសុំចំណែកលើបណ្ដាំមរតករបស់លោក ខ ថ .

**បណ្ដឹងតប** : ប្ដឹងសុំបដិសេធលិខិតចែកមរតក ចុះថ្ងៃទី១១-១០-២០០១ .

បានឃើញបណ្ដឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៤ របស់លោក ស ច ឱ ជាមេធាវីតំណាងឱ្យឈ្មោះជ ត ហ ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១២៤ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមបណ្ដឹងចុះថ្ងៃទី១៣-១២-២០០១ ដើមចោទ អ្នកស្រី ជ ត ហ ថា : ខ្លួនសុំចំណែកលើបណ្ដាំមរតក របស់សពលោកតា ខ ថ ចុះថ្ងៃទី១១-១០-២០០១ ដែលបានប្រគល់ឱ្យខ្លួនជាប្រពន្ធ និងជាអ្នកបំរើ មើលថែលោកតា ខ ថ និងបានមើលថែជំងឺលោកតា ខ ថ តាំងពីឆ្នាំ១៩៩៨ បានរស់នៅជាមួយគ្នារហូតមក ។ ក្នុងការបំរើលោកតា ខ ថ សព្វសារពើនេះ គាត់តែងនិយាយថា អាណិតស្រលាញ់ខ្លួនណាស់ បើគាត់ស្លាប់ទៅ មិនឱ្យខ្លួនលំបាកទេ តែខ្លួនមិនចាប់អារម្មណ៍ និងសំដីនេះឡើយ ។ នៅថ្ងៃទី១៥-១០-២០០១ លោកតា ខ ថ បានប្រគល់ស្រោមសុំបុត្រ១មកឱ្យខ្លួន ដោយប្រាប់ថា នេះជាកេរ្ដិ៍បន្តិចបន្តួច សំរាប់ឱ្យខ្លួនចិញ្ចឹមជីវិតបានដោយខ្លួនឯង នៅពេលអត់ពីគាត់ទៅ ដល់ថ្ងៃបន្ទាប់លោកតា ខ ថ មានជំងឺធ្ងន់ ខ្លួនក៏បញ្ជូនទៅមន្ទីរពេទ្យកាល់ម៉ែត្រ ដល់ថ្ងៃ២៥-១១-២០០១ វេលាម៉ោង ៥:០០ព្រឹក តា ខ ថ ទទួលមរណៈ-ភាព ខ្លួនរៀបចំធ្វើបុណ្យតាមប្រពៃណីដោយមានញាតិមិត្ត បងប្អូនជួយជ្រោមជ្រែង ។

នៅថ្ងៃទី១១-១២-២០០១ ចៅសង្កាត់ស្រះចក បានអញ្ជើញលោកស្រី ព យ ដែលជាប្រពន្ធមុន បានបួសនៅវត្តតាំងពី១០ឆ្នាំមកហើយ និងកូនដើមរបស់តា ខ ថ ចំនួន០៣នាក់ មកស្ដាប់នូវសេចក្ដីមរតក ពួកគាត់យល់ព្រមតាមសេចក្ដីនេះដោយទទួលស្គាល់ថា ពិតជាអក្សររបស់លោកតា ខ ថ មែន ដូចមានកំណត់ហេតុរបស់ចៅសង្កាត់ស្រះចកស្រាប់ ដោយខ្លួនជួបការលំបាក ខ្វះថវិកា ខ្លួនសុំឱ្យតុលាការសំរេចតាមបណ្ដាំ ចុះថ្ងៃទី១១-១០-២០០១ របស់លោកតា ខ ថ ។

តាមបណ្ដឹងតបចុះថ្ងៃទី០៨-០២-២០០២ លោក ទេព ស៊ិនថា តំណាងឱ្យលោកយាយ ព យ (ប្រពន្ធសព) ថា ខ្លួន និងបង១៦នាក់ទៀត មានឈ្មោះ ខ ណក, ខ ណល .

ទ មនៈ ទ រេ៉ា ទ រេ៉ា ទ រេង ដែលត្រូវជាកូនបង្កើតរបស់សពលោកតា ទ ថ និងជាទាយាទ សូមប្តឹងបដិសេធលិខិតចែកមរតក ចុះថ្ងៃទី១១-១០-២០០១ ដែលភាគីដើមចោទប្តឹងទាមទារ ដោយហេតុថា លិខិតនេះ បានធ្វើឱ្យខូចខាតសិទ្ធិជាទាយាទក្នុងការទទួលមរតក និងធ្វើឱ្យបាត់នូវចំណែករបស់ពួកខ្លួន ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៨"ក" ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងសុំ និងចម្លើយប្តឹងសុំរបស់លោកយាយ ព យ និងលោក ទ ស ថ ជាតំណាងទាយាទនៃសពលោក ទ ថ ដែលមានលោកមេធាវីផាត់ពៅ-សាំង ចំណាយក្តីផង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹង និងចម្លើយតវ៉ារបស់អ្នកស្រីជ គ ហ ផ្ទេរសិទ្ធិឱ្យអ្នកស្រី ជ សផ មានមេធាវី ស ច ឧ និងក សរ ចំណាយក្តីផង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយខុសនឹងគតិច្បាប់ ។

៣-ទុកជាមោឃៈនូវលិខិតបណ្តាំចែកមរតក ចុះថ្ងៃទី១១-១០-២០០១ របស់សពលោក ទ ថ តាមគោលការណ៍ច្បាប់ ។

៤-បង្គាប់ឱ្យអ្នកស្រី ជ គ ហ ចែកផ្ទះលេខ ៣៣AE1 ,ស្ថិតនៅផ្លូវលេខ ៣៣៦ ភូមិ១ សង្កាត់ផ្សារដើមគរ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ពាក់កណ្តាលឱ្យមកទាយាទនៃសពលោក ទ ថ មានលោក ទ ស ថ ជាតំណាង មានមេធាវីផ ព ស ចំណាយក្តីផង ។ បើចែកមិនដាច់ស្រេចឱ្យលក់ឡាយឡុងយកប្រាក់ចែកជាពីរភាគស្មើ(មាត្រា ១៦៨ និងតទៅនៃច្បាប់ភូមិបាលថ្មីឆ្នាំ២០០១ ) ។

៥-បង្គាប់ឱ្យឈ្មោះនាងជ ន អ និង លោក ល សរ និងគ្រួសារព្រមទាំងអ្នកដទៃទៀត ចុះចេញពីផ្ទះលេខ៣៣AE1 ភូមិ១ សង្កាត់ផ្សារដើមគរ ។

៦-ទុកជាមោឃៈនូវលិខិតលក់ដី ផ្ទេរកម្មសិទ្ធិចុះថ្ងៃទី១២-៤-២០០១ នូវដីទំហំ ៤៧៥០ម² តំលៃ ២៨៥០$ និងលិខិតលក់ដីផ្ទេរកម្មសិទ្ធិចុះថ្ងៃទី១៨-១០-២០០១ ទំហំ ៧៨៨៥ម² តំលៃ ៤.៧៣១$ ដែលស្ថិតនៅភូមិព្រៃព្រាយក្របៅ២ ឃុំរកាអារ ស្រុកកងមាស ខេត្តកំពង់ចាមពីឈ្មោះអ្នកស្រី ជ គ ហ ឱ្យទៅឈ្មោះទ ច រ និងប្រពន្ធ ជ សផ (មាត្រា១៦៨ និង១៧១ នៃច្បាប់ភូមិបាលថ្មី និងមាត្រា ៣៥ នៃច្បាប់កិច្ចសន្យាលេខ ៣៨) ។

៧-បង្គាប់ឱ្យអ្នកស្រី ជ គ ហ ផ្ទេរសិទ្ធិឱ្យអ្នកស្រី ជ សផ មានមេធាវី ស ច ឧ និងក សរ ចំណាយក្តីផង ចែកដីទំហំ ៤៧៥០ម² តម្លៃ ២.៨៥០$ ដែល

ទិញពីអ្នកស្រីឈ គ ស តាមលិខិតលក់ដីផ្ទេរកម្មសិទ្ធិកាន់កាប់ចុះថ្ងៃទី១៤-៤-២០០១ ពាក់កណ្តាលឱ្យទៅទាយាទ នៃសពលោក ទ ថ និងដីទំហំ ៧៨៨៥ ម² ដែលទិញពីឈ្មោះឈ វ ប្រពន្ធឈ្មោះវ ស តំលៃ ៤.៧៣១$ ដែលទិញតាមលិខិតលក់ដីផ្ទេរសិទ្ធិកាន់កាប់ចុះថ្ងៃទី១២-៤-២០០១ ស្ថិតនៅភូមិជ្រោយក្របៅ២ ឃុំគារអារ ស្រុកកងមាស ខេត្តកំពង់ចាម ពាក់កណ្តាលឱ្យទៅទាយាទនៃសពលោក ទ ថ ។ បើចែកគ្នា មិនដាច់ស្រេចឱ្យលក់ឡាយឡុងយកប្រាក់ចែកគ្នាស្មើ ចាប់ពីពេលដែលសាលក្រមនេះ ស្ថាពរ (មាត្រា១៦៨-១៧១ នៃច្បាប់ភូមិបាលថ្មី) ។

៨-ឱ្យអ្នកស្រី ជ គ ហ បង់ប្រាក់ប្រដាប់ក្តី ២១.០០០៛ ដែលបានកាត់យកពីប្រាក់ប្រដាប់ក្តីរបស់ទាយាទនៃសពលោក ទ ថ ក្នុងសំណុំរឿងលេខ ១៥៣៣ ចុះថ្ងៃទី១៩-១២-២០០១ និងសំណុំរឿងលេខ ១២២ ចុះថ្ងៃទី២៣-០១-២០០២ ចំនួន ១៤.០០០៛ និងសំណុំរឿងលេខ ១៥២៥/១៨-១២-២០០១ ចំនួន ៧.០០០៛ របស់អ្នកស្រីជ គ ហ ដាក់ថវិការដ្ឋ និងចំណាយផ្សេងៗរួចហើយ និងឱ្យអ្នកស្រី ជ គ ហ មានអ្នកស្រីជ សផ ជាតំណាងបង់ពន្ធសមាមាត្រ១% នៃតម្លៃនៃរឿងក្តីនេះ តែត្រូវឱ្យអ្នកឈ្នះក្តីបង់ជាមុន ហើយតម្រូវឱ្យអ្នកស្រី ជ គ ហ សងប្រាក់ប្រដាប់ក្តីចំនួន ១៤.០០០៛ និងប្រាក់ពន្ធសមាមាត្រនេះទៅទាយាទនៃសពលោកទេព ថូ វិញ ។

៩-សាលក្រមនេះ សម្រេចសេចក្តី និងប្រកាសជាសាធារណៈ ចំពោះមុខជ - សផ មេធាវី ស ច ឩ លោក ទ ស ថា មេធាវីផ ព ស បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ ០២ខែ គិតពីថ្ងៃសម្រេចសេចក្តី ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១១ខែមិថុនា ឆ្នាំ២០០៣ របស់លោក ស ច ឩ តំណាងឱ្យអ្នកស្រី ជ គ ហ មិនសុខចិត្តនឹងសាលក្រមលេខ១៨"ក" ចុះថ្ងៃទី១២-៥-២០០៣ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១២៩"ឈ" ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១-៦-២០០៣ របស់លោកមេធាវី ស ច ឩ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះមូលដ្ឋានគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៨"ក" ចុះថ្ងៃទី១២-៥-២០០៣ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ ដែលឈ្មោះ ព យ បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០រៀល ។

កាលបើផុតកំណត់ប្តឹងសាទុក្ខ បង្គាប់ឱ្យឈ្មោះជិន គឹមហោ សងប្រាក់ ១៣.០០០៛នេះ ឱ្យទៅឈ្មោះ ព យ វិញ ។

៤-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៦-៨-២០០៣ ចំពោះមុខតំណាងចុងចម្លើយ និងមេធាវីចុងចម្លើយ កំបាំងមុខដើមចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៥-៩-២០០៣ កំបាំងមុខគូក្តី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ១១៥ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៣ របស់លោក ស ច ឧ មេធាវីថណាយក្តីឱ្យដើមចោទ ប្តឹងទាស់នឹងសាលដីការដ្ឋប្បវេណីលេខ១២៩"ឈ" ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី៣០-៩-២០០៣ របស់លោកមេធាវី ស ច ឧ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ១២៩"ឈ"ចុះថ្ងៃទី០៥-៩-២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣-សាលដីកានេះ ជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី២៨-១១-២០០៣ ចំពោះមុខមេធាវីតំណាងគូក្តី និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥-១២-២០០៣ ចំពោះមុខមេធាវីតំណាងចុងចម្លើយ កំបាំងមុខមេធាវីតំណាងដើមចោទ តែចាត់ទុកជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៤ របស់លោក ស ច ឧ ជាមេធាវីតំណាងឱ្យឈ្មោះជ គ ហ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះជ គ ហ

បានឃើញសារណាតបចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះ ព យ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ១៧៦ "ឈ" ចុះថ្ងៃទី០៥-១២-២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ និងគតិច្បាប់ហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ក្រឡាបញ្ជីអានសារណារបស់អ្នកស្រី ជិន គីមហោ នៅពេលសវនាការ ។

បានស្តាប់ចម្លើយរបស់លោក ទ ស ថ តំណាងឱ្យអ្នកស្រី ព យ ជាចុងបណ្តឹងសាទុក្ខ នៅពេលសវនាការថា : ចំពោះបណ្តាំមរតក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ ចំពោះខ្លួន និងក្រុមគ្រួសារ ខ្លួនគិតថា មិនត្រឹមត្រូវទេ ហើយក្រុមគ្រួសារទាំងមូលមិនមានអ្នកណាម្នាក់បានដឹងទាល់តែសោះ ។ ចំពោះខ្លួន អ្នកស្រីជ គ ហ មិនមែនជាប្រពន្ធរបស់ឪពុកខ្លួនទេ អ្នកស្រីជ គ ហ គាត់ទទួលប្រាក់ខែពីឪពុករបស់ខ្លួន ព្រោះថាជាកាតព្វកិច្ច ដូចជា ការបោកគ្គុកអាចម៍នោម គឺជាភារកិច្ចរបស់អ្នកស្រីជ គ ហ ព្រោះអ្នកស្រីជ គ ហ ជាអ្នកបំរើរបស់ឪពុកខ្លួន។ ម្យ៉ាងទៀត អ្នកស្រី ជ គ ហ គាត់បានទទួលចំណែកពាក់កណ្តាលហើយ នៅមានដីជាច្រើនកន្លែងទៀតដែលក្រុមគ្រួសារខ្លួនមិនទាន់បានរកឃើញ ។ ខ្លួនសូមតំកល់សាលដីកាសាលាឧទ្ធរណ៍ទាំងមូល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកសោម ច័ន្ទឌីណា ជាមេធាវីការពារ និងតំណាងឱ្យអ្នកស្រីជ គ ហ ជាម្ចាស់បណ្តឹងសាទុក្ខ បានធ្វើសេចក្តីសន្និដ្ឋានថា :បើពិនិត្យលើបណ្តាំមរតកមួយច្បាប់ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ គឺជាសំណេរអក្សរផ្ទាល់ដៃរបស់ឈ្មោះ ខ ថ ដែលជាម្ចាស់ទ្រព្យដោយបានសរសេរដោយផ្ទាល់ដៃ ក្នុងលិខិតបណ្តាំនេះ បានសរសេរយ៉ាងច្បាស់លាស់អំពីឈ្មោះរបស់ម្ចាស់ទ្រព្យ ហើយបានបញ្ជាក់ពីគោលបំណងដែលម្ចាស់បណ្តាំចង់ប្រគល់អោយ ។ លោកតា ខ ថ បានធ្វើការបែងចែកជាពីរចំណែកយ៉ាងច្បាស់លាស់ គឺទី១ លោកយាយ ព យ ទី២ គឺកូនក្តីខ្លួន តាមការបែងចែកលោកតា ខ ថ បានបញ្ជាក់ពីទីកន្លែង និងប្រវែងច្បាស់លាស់ ទី៣ ទៀតលិខិតបណ្តាំនេះ បានចុះថ្ងៃ ខែ ឆ្នាំ និងបានចុះហត្ថលេខា និងមានស្នាមមេដៃបញ្ជាក់យ៉ាងច្បាស់លាស់ ។ លិខិតបណ្តាំនេះ បានដាក់ក្នុងស្រោមត្រឹមត្រូវហើយ លោកតា ខ ថ បានប្រគល់ឱ្យចៅសង្កាត់ឈ្មោះ ឆ ធរ ដោយបានចុះលេខរដ្ឋបាលយ៉ាងត្រឹមត្រូវ ។ បើសិនជាពិនិត្យលើអត្ថបទច្បាប់វិញ បណ្តាំមរតក គឺជាសន្តតិកម្ម ដែលជាការផ្ទេរនូវបេតិកភ័ណ្ឌនៃបុគ្គលដែលស្លាប់ឱ្យជនម្នាក់ ឬច្រើននាក់ ដែលរស់នៅ ហៅថា សន្តតិជន ។ ការផ្ទេរនេះ គឺធ្វើទៅតាមឆន្ទៈរបស់ម្ចាស់ទ្រព្យ ។ ខ្លួនសំណូមពរ សូមឯកឧត្តមប្រធានតុលាការកំពូល លោកចៅក្រមមេត្តាផ្តល់ភាពយុត្តិធម៌ដល់កូនក្តីខ្លួន ដោយបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះសារជាថ្មីឡើងវិញ ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លោកផ  រ ស  ជាមេធាវីការពារឱ្យចុងចំលើយ បានធ្វើសេចក្ដីសន្និដ្ឋានថា : ខ្ញុំសូមជំរាបថា អ្នកស្រីជ  គ  ហ  មិនមែនជាប្រពន្ធរបស់សពលោកតា ទ  ថ ទេ គឺជាអ្នកបំរើក្នុងមួយខែ ១០០ដុល្លារអាមេរិក អ្នកស្រីជ  គ  ហ  គាត់បំរើតបស្នងទៅលោកតា ទ  ថ វិញ ព្រោះអ្នកស្រីជ  គ  ហ  ទទួលប្រាក់ ១០០ដុល្លារអាមេរិក ក្នុងឋានៈអ្នកស្រីជ  គ  ហ  បំរើមនុស្សចាស់ ។ ជុំវិញបណ្ដាំមរតកសរសេរនៅថ្ងៃទី១១ ខែតុលា ឆ្នាំ ២០០១ លោកតា ទ ថ មានសតិអារម្មណ៍មិនហ្នឹងនរ ។ តាមគតិច្បាប់ការបែងចែកមរតកសាស្ត្រសន្តតិជនជំបូងគេបង្អស់គឺកូន កូនមិនបានទទួលបែរជាអ្នកស្រីជ  គ  ហ  បានទទួលពាក់កណ្ដាលទៅវិញ គាត់មិនបែងចែកឱ្យទៅទាយាទ គឺជាមោឃភាពរបស់បណ្ដាំមរតក។បណ្ដាំមរតកសរសេរនៅក្នុងសតិវិលវល់ ។ ចំណែកផ្ទះលេខ៣៣AE, មានស្នាមមេដៃរបស់លោកតា ទ  ថ និងដីពីរកន្លែងទៀត ក៏ដាក់ឈ្មោះលោកតា  ទ  ថ ទៀត បើលោកតា  ទ  ថ មិនចេញប្រាក់ទេហេតុអ្វីបានដាក់ឈ្មោះលោកតា  ទ  ថ ។  ខ្ញុំសូមសំណូមពរក្រុមប្រឹក្សាជំនុំជំរះ មេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍លេខ១៧៦ "ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សារណាដើមចោទ ចម្លើយតំណាងចុងចម្លើយ និង សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីគូភាគី.
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០០៤ របស់លោកមេធាវី ស  ច ឱ  ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញថា : ការដែលមេធាវីដើមចោទ លើកឡើងនៅពេលសវនាការនេះថា មរតកសាសន៍ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ ធ្វើឡើងតាមគន្លងច្បាប់ជាលិខិតបណ្ដាំ ធ្វើក្រោយគេ ហើយជាប្រភេទលិខិតបណ្ដាំឯកជន សរសេរដោយដៃម្ចាស់ទ្រព្យផ្ទាល់ដែលគប្បីមានអានុភាពតាមផ្លូវច្បាប់ ហើយថា បើទោះបីជាអ្នកស្រីជ  គ  ហ  មិនមែនជាសហព័ទ្ធរបស់សពលោកតា ទ  ថ ក៏អ្នកស្រីអាចទទួលអច្ច័យទានបានដែរ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា បច្ចុប្បន្នយើងពុំទាន់មានច្បាប់ស្ដីពីមរតកទេ ហើយតាមលិខិត ចុះថ្ងៃទី១៤-០២-២០០១ របស់សព បាន

បញ្ជាក់ច្បាស់ថា បានប្រគល់ផ្ទះចែកកូន៧នាក់ ដោយមានតម្លៃតបស្នងផង ។ ម្យ៉ាងទៀត បណ្ដាំចុះថ្ងៃទី១១-១០-២០០១ ធ្វើឡើងពេលដែលលោកតា ខ ថ មានជំងឺធ្ងន់ ហើយខ្លឹមសារនៃលិខិតបណ្ដាំចុះថ្ងៃទី១១-១០-២០០១នេះ ពុំបានចែងថា ឱ្យលប់ចោលនូវបណ្ដាំមុនៗទេ ។

- យល់ឃើញថា តុលាការក្រុងភ្នំពេញ ក៏ដូចជាសាលាឧទ្ធរណ៍ដែរ ពុំបានទទួលស្គាល់អ្នកស្រីជ គ ហ ជាសហព័ទ្ធស្របច្បាប់របស់សពលោកតា ខ ថ ឡើយ តែបែរជាទទួលស្គាល់ផ្ទះលេខ ៣៣ AE1 ស្ថិតនៅផ្សារដើមគរ និងដីនៅស្រុកកងមាស ខេត្តកំពង់ចាម ដោយសំអាងលើលិខិតផ្ទេរសិទ្ធិមានឈ្មោះអ្នកស្រី ជ គ ហ និងសពលោកតា ខ ថ ជាទ្រព្យរួមនោះ គឺជាការភ័ន្តច្រឡំ ពីព្រោះថា បុគ្គលពីរនាក់ដែលមិនមែនជាសហព័ទ្ធនឹងគ្នា មានសិទ្ធិលើវត្ថុតែមួយ មិនអាចមានន័យថា ជាទ្រព្យរួមឡើយ ។

- យល់ឃើញថា ដើមចោទ បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះ កំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៧៦"ឈ"ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ហើយ លើកលែងតែចំណុចទី៤.៥.៦.៧ នៃសាលក្រមរបស់តុលាការក្រុងភ្នំពេញ ដែលសាលាឧទ្ធរណ៍តម្កល់ទុកជាបានការ ត្រូវទុកជាមោឃៈ ។

## ដោយហេតុនេះ

## វិនិច្ឆ័យសេចក្ដីចំពោះមុខតំណាងចុងចម្លើយ

## កំបាំងមុខដើមចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្ដឹងសាទុក្ខលេខ០៣ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៤ របស់លោកមេធាវី ស ច ឱ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ខ្លះ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែចំណុចទី៤.៥.៦. និងទី៧ នៃសាលក្រមរបស់តុលាការក្រុងភ្នំពេញ ដែលត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១២៤ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៤ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ត្រង់ចំណុចទី៤.៥.៦ និងទី៧ នៃសាលក្រមរបស់តុលាការក្រុងភ្នំពេញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដីដែលអ្នកស្រី ព យ បានបង់នៅតុលាការកំពូល ចំនួន

១៩.០០០រៀល គឺ :

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្វ៊ីងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០រៀល

៥-សាលដីកានេះជំនុំជំរះនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និង ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៤ ។